សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការជ្រើសតាំងសារការី និងការបង្កើតមន្ទីរសារការី
# (ប្រៀបធៀបកម្ពុជា-ជប៉ុន)

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៦

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ក.ជីវ រតនធិតា**

សាស្ត្រាចារ្យណែនាំ
លោក **គង់ សុភ័ក្ត្រ**

ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ
ជំនាន់ទី១៦

ឆ្នាំចូលសិក្សា ២០១២
ឆ្នាំសរសេរសារណា ២០១៦

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ជីវ រតនធិតា** ជានិស្សិតថ្នាក់បរិញ្ញាបត្រនិតិសាស្រ្ត បង់ថ្លៃ ជំនាន់ទី១៦ ថ្នាក់$L_4A_4$នៃឆ្នាំសិក្សា២០១២-២០១៦ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច សូមសម្តែងការគោរពដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖

លោកឪពុក **ជីវ លី** និងអ្នកម្តាយ **ថាច់ មុន្នា** ដែលបានផ្តល់ជីវិត ចិញ្ចឹមបីបាច់ និងផ្តល់នូវសេចក្តីស្រឡាញ់ មេត្តា ករុណា អប់រំទូន្មាន ប្រៀនប្រដៅ ឲ្យមានសេចក្តីព្យាយាម អំណត់ក្លាហាន ព្រមទាំងបានធ្វើពលិកម្មពុំអាចកាត់ថ្លៃបានដើម្បីឲ្យកូនទទួលបានការសិក្សាប្រកបដោយចំណេះដឹងដ៏ថ្លៃថ្លាបំផុត។

ជាមួយគ្នានេះដែរ នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងខ្ពង់ខ្ពស់ចំពោះឯកឧត្តមសាកលវិទ្យាធិការ **លុយ ចណ្ណា** និងសាកលវិទ្យាធិការរងព្រមទាំងសាស្រ្តាចារ្យ បុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចទាំងអស់ ដែលបានខិតខំបង្រៀន ដោយបានផ្តល់នូវចំណេះដឹង និងបង្កជាបរិយាកាសងាយស្រួលនានា ដើម្បីឲ្យយើងខ្ញុំបានទទួលយកចំណេះដឹងរហូតអាចបញ្ចប់ការសិក្សាបានដោយជោគជ័យ។

នាងខ្ញុំ **ជីវ រតនធិតា** ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះ **មជ្ឈមណ្ឌលស្រាវជ្រាវ និងអប់រំអំពីច្បាប់ជប៉ុន(CJL)** នៃសាកលវិទ្យាល័យណាហ្គោយ៉ា ដែលបានផ្តល់អាហារូបករណ៍មកឲ្យនាងខ្ញុំរយៈពេល៤ឆ្នាំ ដើម្បីទទួលបានការសិក្សាផ្នែកភាសា និងច្បាប់របស់ប្រទេសជប៉ុន។ ជាពិសេស សាស្រ្តាចារ្យ បុគ្គលិក សិស្សច្បង និងសិស្សប្អូនទាំងអស់ ដែលបានខិតខំប្រឹងប្រែងបង្រៀន ផ្តល់បទពិសោធន៍ចំណេះដឹងផ្នែកស្រាវជ្រាវ និងលើកទឹកចិត្តដល់រូបនាងខ្ញុំរហូតមក។

ជាពិសេសនាងខ្ញុំសូមថ្លែងអំណរគុណចំពោះ **លោកសាស្រ្តាចារ្យ គង់ សុភ័ក្រ្ត** ដែលជាសាស្រ្តាចារ្យណែនាំ ដោយលោកបានចំណាយពេលវេលាដ៏មានតម្លៃ លះបង់អស់ពីកម្លាំងកាយ និងកម្លាំងចិត្ត មិនខ្លាចនឿយហត់ ដើម្បីជួយដឹកនាំ និងជំរុញក្នុងការសរសេរជាស្នាដៃនេះតាំងពីចាប់ផ្តើមរហូតដល់ការបញ្ចប់ជាស្ថាពរ។

ជាចុងក្រោយ នាងខ្ញុំសូមបួងសួងអស់វត្ថុសក្តិសិទ្ធិទាំងឡាយ សូមប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខ គ្រប់ប្រការ ជូនដល់អស់លោកអ្នកមានគុណទាំងឡាយ និងសូមជួយបីបាច់ថែរក្សាលោកអ្នកមានគុណឲ្យមានសុខភាពល្អ ព្រមទាំងសូមជូនពរឲ្យលោក ជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

# អារម្ភកថា

សារណានេះត្រូវបានធ្វើឡើង ក្នុងឱកាសនៃការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី១៦ ឆ្នាំសិក្សា២០១២-២០១៦។ នេះគឺជាស្នាដៃមួយដែលផ្តល់នូវគុណប្រយោជន៍ដល់ការសិក្សា និងស្រាវជ្រាវសម្រាប់និស្សិតផ្នែកនិតិសាស្ត្រជំនាន់ក្រោយទាំងអស់ផងដែរ។ ម្យ៉ាងទៀត នេះក៏ជាឱកាសដ៏មានតម្លៃក្នុងការបង្ហាញសមត្ថភាព ចំណេះដឹងដែលកើតឡើងមកពីការខិតខំប្រឹងប្រែងសិក្សា និងស្រាវជ្រាវអស់រយៈពេល៤ឆ្នាំនៅ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ព្រមទាំង**មជ្ឈមណ្ឌលស្រាវជ្រាវ និងអប់រំអំពីច្បាប់ជប៉ុន** (CJL)នៃសាកលវិទ្យាល័យណាហ្គោយ៉ាផងដែរ។

ការផ្ទេរសិទ្ធិលើអចលនវត្ថុគ្រប់ប្រភេទ ការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន ការចុះកិច្ចសន្យា ការផ្តល់យថាភូតភាពលើលិខិតឯកជនមួយចំនួន មិនមានអានុភាពគតិយុត្តឡើយ បើមិនបានទទួលការបញ្ជាក់ពីសារការី។ សារការី ជាបុគ្គលដែលច្បាប់ប្រគល់សិទ្ធិក្នុងការធ្វើយថាភូតភាពលើលិខិតឯកជននានា ដើម្បីឲ្យលិខិតនោះមានអានុភាពគតិយុត្ត ឬ អាចទទួលបាននូវទំនុកចិត្តក្នុងប្រតិបត្តិការជំនួញ។ សារការី ដើរតួនាទីសំខាន់ នៅក្នុងទំនាក់ទំនងរវាងបុគ្គលឯកជន និងឯកជន ដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវទៅតាមទម្រង់ច្បាប់ និងធានាដល់សុវត្ថិភាពគតិយុត្តជូនចំពោះគូភាគីនៃប្រត្តិបត្តិការជំនួញក្នុងលិខិតឯកជនផងដែរ។ ក្រោយពីការអនុម័តក្រមនីតិវិធីរដ្ឋប្បវេណីនៅឆ្នាំ២០០៦ ក្រមរដ្ឋប្បវេណីនៅឆ្នាំ២០០៧ ក៏ដូចជាច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ ក្រោមជំនួយពី**ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ហៅកាត់ (JICA)**យើងឃើញថាពាក្យសារការីមានកាន់តែច្រើនឡើងនៅក្នុងលិខិតបទដ្ឋានគតិយុត្តិទាំងនោះ ដែលអាចឲ្យសន្និដ្ឋានបានថា វត្តមានសារការីនៃព្រះរាជាណាចក្រកម្ពុជាកាន់តែមានសារៈសំខាន់នៅក្នុងទំនាក់ទំនងគតិយុត្តផ្នែកឯកជន ។ ហេតុនេះហើយ ការស្វែងយល់អំពីលក្ខខណ្ឌដើម្បីក្លាយជាសារការី និងនីតិវិធីដើម្បីដំណើរការមន្ទីរសារការីពិតជាមានសារៈសំខាន់ ។ ម្យ៉ាងវិញទៀត ដោយសារតែក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីបានទទួលឥទ្ធិពលពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ទើបយើងខ្ញុំសម្រេចធ្វើការសិក្សាប្រៀបធៀបទាំង២ប្រទេសគឺ ព្រះរាជាណាចក្រកម្ពុជា និងប្រទេសជប៉ុន។

ទោះបីស្នាដៃនេះ ត្រូវបានស្រាវជ្រាវយ៉ាងខិតខំប្រឹងប្រែង និងអស់ពីសមត្ថភាពយ៉ាងណាក្តី ប៉ុន្តែដោយសារបទពិសោធន៍ និងចំណេះដឹងក្នុងការស្រាវជ្រាវនៅមានកម្រិត រួមផ្សំនឹងផ្នែកមួយចំនួននៃសារណានេះត្រូវបានដកស្រង់ និងសិក្សាស្រាវជ្រាវចេញពីឯកសារបរទេសដែលសរសេរជាភាសាជប៉ុនផងនោះ ដូចនេះកំហុសឆ្គងក្នុងការបកប្រែ ការប្រើប្រាស់ ពាក្យពេចន៍ ឃ្លា ប្រយោគ ប្រាកដជាមានកំហុសជាក់ជាមិនខាន។អាស្រ័យហេតុនេះ រាល់ការរិះគន់ ស្ថាបនា ផ្តល់អនុសាសន៍ថ្មីៗពីសំណាក់អ្នកអានទាំងអស់គឺជាការរួមចំណែកដែលមិនអាចខ្វះបាន ដើម្បីចូលរួមកែលម្អ និងអភិវឌ្ឍសមត្ថភាពក្នុងការស្រាវជ្រាវនាពេលអនាគតឲ្យកាន់តែប្រសើរឡើង។

# មាតិកា


**សេចក្តីផ្តើម** ........ ១

**ជំពូកទី១ ការជ្រើសតាំងសារការី និងការបង្កើតមន្ទីរសារការីនៃប្រទេសកម្ពុជា** ........ ៦

**ផ្នែកទី១ សញ្ញាណទូទៅទាក់ទងនឹងសារការី** ........ ៦

**១.១.ប្រវត្តិនៃការកកើតវិជ្ជាជីវៈសារការី** ........ ៧

១.១.១.វិជ្ជាជីវៈសារការីមុនឆ្នាំ១៩៧៥ ........ ៧

១.១.២.វិជ្ជាជីវៈសារការីក្រោយឆ្នាំ១៩៧៥ ........ ៨

**១.២.លិខិតដែលធ្វើឡើងដោយសារការី** ........ ៩

១.២.១.ប្រភេទលិខិតដែលធ្វើឡើងដោយសារការី ........ ១០

១.២.១.១.កិច្ចសន្យា ........ ១០

១.២.១.២.សកម្មភាពឯកតោភាគី ........ ១០

១.២.១.៣.លិខិតដែលត្រូវបញ្ជាក់ភាពពិត ........ ១០

១.២.២.លក្ខខណ្ឌនៃលិខិតដែលមានអានុភាពគតិយុត្ត ........ ១១

១.២.២.១.វត្តមានរបស់គូភាគីហត្ថលេខី ........ ១២

១.២.២.២.វត្តមានសារការី ........ ១២

១.២.២.៣.វត្តមានសាក្សី ........ ១៣

១.២.២.៤.ហត្ថលេខារបស់សារការី ........ ១៣

១.២.៣.តម្លៃប្រថាប់ត្រារបស់សារការី ........ ១៤

**ផ្នែកទី២ នីតិវិធីជ្រើសតាំងសារការី និងបែបបទបង្កើតមន្ទីរសារការី** ........ ១៤

**២.១.លក្ខខណ្ឌដើម្បីក្លាយជាសារការី** ........ ១៤

២.១.១.ការបណ្តុះបណ្តាលក្នុងសាលាភូមិន្ទវិជ្ជាជីវៈសារការី ........ ១៦

២.១.១.១.ការប្រឡងប្រជែង ........ ១៧

២.១.១.១.១.លក្ខខណ្ឌជាបេក្ខភាពប្រឡងប្រជែង ........ ១៧

២.១.១.១.២.វិញ្ញាសារប្រឡងប្រជែង ........ ១៧

២.១.១.២.វគ្គបណ្តុះបណ្តាល ........ ១៩

២.១.១.២.១.វគ្គបណ្តុះបណ្តាលបឋម ........ ១៩

ក.ត្រីមាសសិក្សាអំពីនីតិទូទៅ ........ ១៩

ខ.ត្រីមាសសិក្សាអំពីនីតិគ្រួសារ ........ ១៩

គ.ត្រីមាសសិក្សាអំពីនីតិអចលនទ្រព្យ ................ ១៩
ឃ.ត្រីមាសសិក្សាអំពីនីតិជំនួញ ................ ២០
២.១.១.២.២.កម្មសិក្សា និងការជួបជុំផ្លាស់ប្តូរបទពិសោធន៍ ................ ២០
ក.កម្មសិក្សា និងការបណ្តុះបណ្តាលផ្លាស់ ................ ២០
ខ.ការជួបជុំផ្លាស់ប្តូរបទពិសោធន៍ ................ ២១
២.១.២.ការតែងតាំងជាសារការី ................ ២២
២.១.២.១.ការតែងតាំងដោយប្រកាសក្រសួងយុត្តិធម៌ ................ ២២
២.១.២.២.ការទទួលបានមុខងារសារការីដោយអនុក្រឹត្យ ................ ២៨
**២.២.លក្ខខណ្ឌក្នុងការបង្កើតមន្ទីរសារការី** ................ ៣២
២.២.១.លក្ខណៈសម្បត្តិជាសារការី ................ ៣៣
២.២.២.ការតម្កល់ប្រាក់ធានានៅធនាគារជាតិនៃកម្ពុជា ................ ៣៤
**ផ្នែកទី៣ បច្ចុប្បន្នភាពនៃវិជ្ជាជីវៈសារការី(ឆ្នាំ២០១៦)** ................ ៣៦
**៣.១.លិខិតបទដ្ឋានពាក់ព័ន្ធនឹងសារការី** ................ ៣៦
**៣.២.ចំនួនសារការី និងចំនួននៃមន្ទីរសារការី** ................ ៣៧
**ជំពូកទី២ ការជ្រើសតាំងសារការី និងការបង្កើតមន្ទីរសារការីនៃប្រទេសជប៉ុន** ................ ៤០
**ផ្នែកទី១ សញ្ញាណទូទៅទាក់ទងនឹងសារការី** ................ ៤០
**១.១.ប្រវត្តិនៃការកកើតវិជ្ជាជីវៈសារការី** ................ ៤០
១.១.១.បទប្បញ្ញត្តិស្តីពីសារការី ................ ៤០
១.១.២.ច្បាប់ស្តីពីសារការី ................ ៤១
១.១.៣.ប្រព័ន្ធសារការីក្នុងអំឡុងពេលមានសង្គ្រាម ................ ៤២
១.១.៤.វិសោធនកម្មច្បាប់ស្តីពីសារការី ................ ៤២
**១.២. លិខិតដែលធ្វើឡើងដោយសារការី** ................ ៤៤
១.២.១.ប្រភេទលិខិតដែលធ្វើឡើងដោយសារការី ................ ៤៥
១.២.១.១.កិច្ចសន្យា ................ ៤៥
១.២.១.២.សកម្មភាពឯកតោភាគី ................ ៤៦
១.២.១.៣.លិខិតដែលត្រូវត្រួតពិនិត្យភាពពិត ................ ៤៨
១.២.២. ការបញ្ជាក់ពីសារការី ................ ៤៨
១.២.២.១.ការបញ្ជាក់លើលក្ខន្តិកៈក្រុមហ៊ុន ................ ៤៨

១.២.២.២.ការបញ្ជាក់លើលិខិតឯកជន ៤៩
១.២.៣. តម្លៃសេវារបស់សារការី ៤៩
១.២.៣.១.សញ្ញាណទូទៅនៃប្រព័ន្ធកម្រៃជើងសារ ៥០
១.២.៣.២.ប្រភេទនៃកម្រៃជើងសារ ៥០
១.២.៣.៣.ប្រាក់កម្រៃជើងសារមូលដ្ឋានក្នុងការធ្វើលិខិតពាក់ព័ន្ធនឹងកិច្ចសន្យា ៥០
១.២.៣.៤.វិធីគណនាប្រាក់កម្រៃជើងសារលើកិច្ចសន្យាមួយចំនួន ៥២
១.២.៣.៤.១.កិច្ចសន្យាលក់-ទិញ ៥២
១.២.៣.៤.២.ភតិសន្យាលើអាគារ ៥៣
១.២.៣.៤.៣.កិច្ចសន្យាខ្ចីបរិភោគ ៥៤
១.២.៣.៤.៤.កិច្ចសន្យាលែងលះ ៥៥
១.២.៣.៤.៥.មតកសាសន៍ ៥៥
**ផ្នែកទី២ នីតិវិធីជ្រើសតាំងសារការី និងបែបបទបង្កើតមន្ទីរសារការី** ៥៦
**២.១.លក្ខខណ្ឌដើម្បីក្លាយជាសារការី** ៥៦
២.១.១.ការប្រឡងប្រជែង ៥៦
២.១.២.ការជ្រើសតាំងពីក្នុងចំណោមអ្នកច្បាប់ ៥៧
២.១.៣.ការជ្រើសតាំងពីក្នុងចំណោមអ្នកមានបទពិសោធន៍ផ្នែកច្បាប់ ៥៩
**២.២.លក្ខខណ្ឌក្នុងការបង្កើតមន្ទីរសារការី** ៦០
២.២.១.លក្ខណៈសម្បត្តិជាសារការី ៦០
២.២.២.តែងតាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ៦០
**ផ្នែកទី៣ បច្ចុប្បន្នភាពនៃវិជ្ជាជីវៈសារការី(ឆ្នាំ២០១៦)** ៦៤
**៣.១.ចំនួនសារការី និងចំនួនមន្ទីរសារការី** ៦៤
**៣.២.ស្ថាប័នពង្រឹងប្រព័ន្ធសារការី** ៦៤
៣.២.១.សមាគមសារការីតាមតំបន់ និងតាមខេត្ត ៦៥
៣.២.២.សមាគមជាតិសារការីនៃប្រទេសជប៉ុន ៦៥
**សេចក្តីសន្និដ្ឋាន** ៦៨
**អនុសាសន៍** ៧១
**ឯកសារយោង**
**ឧបសម្ព័ន្ធទី១** ព្រះរាជក្រមលេខ៩១០ នស ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៤៥

**ឧបសម្ព័ន្ធទី២** អនុក្រឹត្យចំនួន១១ស្តីពីការបង្កើតមន្ទីរសារការីនៃព្រះរាជាណាចក្រកម្ពុជា

**ឧបសម្ព័ន្ធទី៣** ប្រកាសស្តីពីការកំណត់មន្ត្រីទទួលបន្ទុកកិច្ចការសារការី និងប្រកាសស្តីពីការតែងតាំងសារការីជំនាន់ទី១

**ឧបសម្ព័ន្ធទី៤** តារាងស្តីអំពី ឈ្មោះ លេខប្រៃសណីយ៍ អាសយដ្ឋាន លេខទូរស័ព្ទ និងលេខទូរសារនៃមន្ទីរសារការីទាំង២៨៦ក្នុងប្រទេសជប៉ុន

**ឧបសម្ព័ន្ធទី៥** តារាងស្តីអំពី ឈ្មោះសារការី ឈ្មោះមន្ទីរសារការី កាលបរិច្ឆេទដែលទទួលបានអានុភាពអនុវត្តការផ្តល់យថាភូតភាព និងការបញ្ជាក់តាមប្រព័ន្ធអេឡិចត្រូនិច ព្រមទាំងទីតាំងនៃការិយាល័យច្បាប់ដែលគ្រប់គ្រងមន្ទីរសារការីទាំងនោះ។

# សេចក្តីផ្តើម

សារការី (Notary Public)[1] គឺជាមន្ត្រីសាធារណៈ ដែលមានមុខងារធ្វើលិខិតយថាភូតបញ្ជាក់អំពីលក្ខណៈពិតប្រាកដត្រឹមត្រូវ ធានារ៉ាប់រងអំពីកាលបរិច្ឆេទតម្កល់ រក្សាទុក និងចេញសេចក្តីចម្លងយថាភូតនៃលិខិតទាំងឡាយដែលត្រូវតែឲ្យមានការបញ្ជាក់។ សារការី ត្រូវបានគេចាត់ទុកថាជា "ចៅក្រមសម្របសម្រួល ឬ ចៅក្រមស្ម័គ្រចិត្ត" ព្រោះសារការីត្រូវបានពឹងពាក់ដោយអតិថិជន (គូភាគីនៃកិច្ចសន្យា) ក្នុងការប្រឹក្សា តាក់តែង និងផ្តល់យថាភូតភាពលើលិខិតគតិយុត្តដោយស្របច្បាប់ និងស្របឆន្ទៈរបស់គូភាគី[2]។ សារការីគឺជាអ្នកវិជ្ជាជីវៈច្បាប់ ដែលមានមុខងារចម្បងក្នុងការធានាសុវត្ថិភាពគតិយុត្តនៃលិខិតគតិយុត្តតាមរយៈប្រសិទ្ធិភាពនៃការអនុវត្តលិខិត និងការទទួលខុសត្រូវខ្ពស់ផ្នែកវិជ្ជាជីវៈ។ ចំពោះការធានាសុវត្ថិភាពគតិយុត្តនៃលិខិតគតិយុត្តនេះផងដែរ គឺជាការធានានូវភាពស្របច្បាប់ និង ធ្វើឡើងតាមសេចក្តីពិតនៃលិខិត តាមរយៈការផ្តល់យថាភូតភាព ឬផ្តល់ការបញ្ជាក់លើលិខិតដោយសារការីវិជ្ជាជីវៈ។ ហេតុដូចនេះហើយ ទើបលិខិតដែលធ្វើឡើងដោយសារការីត្រូវបានគេលើកឡើងថាជាលិខិតយថាភូត[3]។ ទន្ទឹមនឹងមុខងារចម្បងដូចដែលបានលើកឡើងខាងលើ សារការីក៏មានតួនាទី និងភារកិច្ចដទៃផងដែរ ដែលមានដូចជា ប្រឹក្សាយោបល់, តាក់តែងលិខិត, ផ្តល់យថាភូតភាពលើលិខិត, ផ្តល់ការបញ្ជាក់នូវភាពពិតលើហត្ថលេខានិងសេចក្តីចម្លងច្បាប់ដើម ព្រមទាំងតម្កល់ឯកសារ ជាដើម។ ជារួម ការអនុវត្តមុខងាររបស់សារការីគឺពាក់ព័ន្ធនឹងនីតិ ក៏ដូចជាវិស័យសំខាន់ៗជាច្រើនដូចជា នីតិអចលនទ្រព្យ នីតិក្រុមហ៊ុន នីតិគ្រួសារ នីតិវិធីរដ្ឋប្បវេណី ច្បាប់ស្តីពីការអនុវត្តក្រម និងវិស័យមូលបត្រ ជាដើម។

វត្តមានសារការីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានកកើតឡើងនៅក្នុងក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩២០ ដែលក្នុងនោះយើងឃើញមានបញ្ញត្តិស្តីអំពីលិខិតយថាភូតរបស់សារការី(ទម្រង់ដូចលិខិតបញ្ជាក់)។ ក្រោយមកក្នុងអំឡុងសតវត្សទី១៩ ពោលគឺសម័យសង្គមរាស្ត្រនិយម ក៏គេឃើញមានប្បញ្ញត្តិអំពីសារការីផងដែរ ដោយមានព្រះរាជក្រមឆ្នាំ១៩៥៤ ដែលបានចែងអំពីតួនាទីរបស់សារការី ពោលគឺសារការីទទួលប្រតិភូកម្មអំណាចសាធារណៈ និងចេញលិខិតយថាភូតដោយការអនុវត្តនៅ

[1] លេខ១៥៩,សន្ទានុក្រមផ្នែករដ្ឋប្បវេណី ដកស្រង់ពី«សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី» ដែលត្រូវបានរៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រីនៅឆ្នាំ២០០៧។

[2] បទបង្ហាញស្តីពី "វិជ្ជាជីវៈសារការី" ដោយកញ្ញា ជឹង ស្រីទូច, សិស្សសារការីជំនាន់ទី១នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៦។

[3] មាត្រា ៩ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

មន្ទីរសារការី[4]។ ជាក់ស្តែង គេឃើញមានវត្តមានរបស់សារការីមួយរូបគឺ លោកសារការី ប៉ុក ធូន ដែលគាត់ត្រូវបានតែងតាំងជាសារការី ប៉ុន្តែគេមិនឃើញមានលិខិតបទដ្ឋានជាក់លាក់បញ្ញត្តិអំពីលក្ខខណ្ឌដើម្បីក្លាយជាសារការីនោះទេ។ ក្រោយមក ក្រសួងយុត្តិធម៌នៃប្រទេសកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការជប៉ុន ហៅកាត់ JICA បានសហការគ្នាដើម្បីធ្វើសេចក្តីព្រាងច្បាប់ស្តីអំពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ដោយក្នុងនោះខាងភាគីជប៉ុនបានបញ្ជូនជំនាញការរបស់ខ្លួនដើម្បីសិក្សា និង ផ្តល់នូវមតិយោបល់មួយចំនួនក្នុងការសម្រួលដើម្បីឲ្យខាងភាគីកម្ពុជាទទួលយកនូវលិខិតបទដ្ឋានទាំងនោះ មកអនុវត្តឲ្យស្របតាមបរិបទសង្គមកម្ពុជា។ ទន្ទឹមនឹងនោះជំនួយខាងផ្នែកច្បាប់ដែលបានលើកឡើងខាងលើ បើយើងមើលទៅលើអត្ថន័យ និងខ្លឹមសារមាត្រាមួយចំនួនដែលមាននៅក្នុងក្រមទាំងពីរខាងលើ គេឃើញមានវត្តមានសារការីជាថ្មី ដែលជាបុគ្គលមានសមត្ថកិច្ចក្នុងការផ្តល់យថាភូតភាពលើលិខិតឯកជន ក៏ដូចជាធ្វើសេចក្តីបញ្ជាក់ទៅលើលក្ខន្តិកៈនៃការកែប្រែលក្ខន្តិកៈនីតិបុគ្គលមួយចំនួនផងដែរ។ បន្ទាប់ពីក្រមរដ្ឋប្បវេណីត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រម នស / រកម /០៧០៦ / ០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ និងក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រម នស / រកម /១២០៧ / ០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ក្រសួងយុត្តិធម៌បានចេញប្រកាសចំនួន២គឺ ប្រកាសលេខ៤៧កយប្រក/១២ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ និង ប្រកាសលេខ៣២ ភយ ប្រក/១២ ចុះថ្ងៃទី២៣ ឧសភា ឆ្នាំ២០១២ ស្តីពីការកំណត់មន្ត្រីទទួលបន្ទុកសារការីទៅតាមដែនសមត្ថកិច្ចនៃសាលាដំបូង ពោលគឺនៅតាមបណ្តាខេត្តទនានាក្នុងព្រះរាជាណាចក្រកម្ពុជា។ ដើម្បីឲ្យសារការីបានទទួលការបណ្តុះបណ្តាលប្រកបដោយគុណភាព និងអនុវត្តមុខងាររបស់ខ្លួនក្នុងនាមបុគ្គលដែលមានវិជ្ជាជីវៈ សាលាភូមិន្ទសារការីនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការក៏ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ១១៧ អនក្រ បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨ ដោយមានភារកិច្ចទទួលបុគ្គលទាំងឡាយណាដែលមានបំណងក្លាយជាសារការីយកមកបណ្តុះបណ្តាល ប៉ុន្តែដើម្បីទទួលបានការបណ្តុះបណ្តាលគឺត្រូវគោរពនូវលក្ខខណ្ឌមួយចំនួន។

ចំណែកឯប្រទេសជប៉ុនវិញ វិជ្ជាជីវៈសារការីបានចាប់កកើតឡើងតាំងពីឆ្នាំ១៨៨៦ តាមរយៈការប្រកាសឲ្យប្រើនូវបទបញ្ញត្តិស្តីពីសារការី។ បទបញ្ញត្តិនេះអនុម័តឡើងដោយទទួលឥទ្ធិពលពីរបបសារការីនៃប្រទេសបារាំង ហើយនាពេលនោះសារការីនៃប្រទេសជប៉ុនត្រូវបានកម្រិតត្រឹមតែការបង្កើតលិខិតយថាភូតតែប៉ុណ្ណោះ។ ក្រោយមកក្នុងឆ្នាំ១៩០៨ ប្រទេសជប៉ុនក៏បានអនុម័តច្បាប់សារការីដែលទទួលឥទ្ធិពលនៃច្បាប់Prussiaហើយច្បាប់នេះត្រូវបានបន្តអនុវត្តរហូតមកដល់ពេលបច្ចុប្បន្ន។ ក្រោយមក ច្បាប់ស្តីពីសារការីក៏ត្រូវបានធ្វើវិសោធនកម្ម ដើម្បីពង្រីកនូវមុខងារសារការី ព្រមទាំង

[4] មាត្រា ៦ ព្រះរាជក្រមលេខ៩១០នស ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ ១៩៥៤។

សម្រួលដល់ការធ្វើទំនើបកម្មប្រព័ន្ធសារការីទាំងមូលដោយបានបង្កើតនូវប្រព័ន្ធអេឡិចត្រូនិច ដែលអាចឲ្យអតិថិជនដាក់ពាក្យសុំផ្តល់យថាភូតភាព ឬ ផ្តល់ការបញ្ជាក់លើលិខិតជាដើម។ ដើម្បីគ្រប់គ្រងសារការីនៃប្រទេសជប៉ុនទាំងមូល សមាគមសារការីក៏ត្រូវបានបង្កើតឡើង សមាគមនេះដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រង និងពង្រឹងប្រព័ន្ធសារការីទូទាំងប្រទេសជប៉ុន។

ប្រព័ន្ធសារការីនៃប្រទេសកម្ពុជាបានទទួលឥទ្ធិពលមុនដំបូងគេពីប្រទេសបារាំង ដោយមានព្រះរាជក្រមលេខ៩១០ ឆ្នាំ១៩៥៤ជាសំអាងស្រាប់ ទន្ទឹមនឹងនោះ រដ្ឋាភិបាលបារាំងក៏បានផ្តល់ជំនួយក្នុងការបណ្តុះបណ្តាលសារការីកម្ពុជាជំនាន់ទី១ផងដែរ។ ផ្ទុយទៅវិញ បើយើងក្រឡេកមកមើលនីតិវិជ្ជមានដែលពាក់ព័ន្ធនឹងសារការីនាពេលបច្ចុប្បន្ននេះ ជាពិសេសក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ដែលជាច្បាប់គ្រឹះនៃវិស័យឯកជន គឺទទួលឥទ្ធិពលពីប្រទេសជប៉ុន។ ចំណុចនេះបានសបញ្ជាក់ឲ្យឃើញថាប្រព័ន្ធសារការីកម្ពុជាបានទទួលរងនូវឥទ្ធិពលពីប្រព័ន្ធសារការីចំនួន២គឺសារការីប្រទេសបារាំង និងប្រទេសជប៉ុន។ ហេតុដូចនេះហើយការស្វែងយល់អំពីលក្ខខណ្ឌដើម្បីក្លាយជាសារការីនៃប្រទេសជប៉ុនគឺជាកត្តាចាំបាច់។

ប៉ុន្តែថាតើលក្ខខណ្ឌដើម្បីក្លាយជាសារការីនៅប្រទេសកម្ពុជានិងប្រទេសជប៉ុនមានលក្ខណៈដូចគ្នាដែរឬទេ? ហើយដើម្បីបើកដំណើរការមន្ទីរសារការីមួយ តើប្រទេសកម្ពុជា និងប្រទេសជប៉ុនមាននីតិវិធីយ៉ាងដូចម្តេចខ្លះ? តើប្រព័ន្ធសារការីនៃប្រទេសទាំងពីរនេះ កំពុងដំណើរការយ៉ាងដូចម្តេចនាពេលបច្ចុប្បន្ន? មកដល់ពេលនេះចម្លើយដែលទាក់ទងនឹងសំណួរទាំងនេះនៅមិនទាន់មានការបកស្រាយបានច្បាស់លាស់នៅឡើយទេ។ ដើម្បីឆ្លើយនឹងសំណួរខាងលើនេះ ទាមទារឲ្យមានការសិក្សាស្រាវជ្រាវដ៏ច្បាស់លាស់ និងជាក់លាក់មួយ។

សារណានេះមានគោលបំណងធ្វើការសិក្សាដើម្បីស្វែងយល់អំពីប្រវត្តិនៃការកកើតវិជ្ជាជីវៈសារការីក្នុងប្រទេសកម្ពុជា និងប្រទេសជប៉ុន ព្រមទាំងស្វែងយល់អំពីលក្ខខណ្ឌដើម្បីក្លាយជាសារការី និង នីតិវិធីក្នុងការបើកដំណើរការមន្ទីរសារការី ដោយបន្ថែមអំពីដំណើរវិវត្តន៍ចុងក្រោយនៃប្រព័ន្ធសារការីនៃប្រទេសទាំងពីរផងដែរ។

សារណានេះធ្វើការស្រាវជ្រាវប្រព័ន្ធច្បាប់ពាក់ព័ន្ធនឹងប្រព័ន្ធសារការីដោយផ្អែកលើលិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានានៅក្នុងប្រទេសកម្ពុជា។ ចំណែកឯការស្រាវជ្រាវអំពីប្រព័ន្ធសារការីនៃប្រទេសជប៉ុនវិញ គឺបានផ្អែកលើលិខិតបទដ្ឋានគតិយុត្តនានារបស់រដ្ឋាភិបាល ក្រសួងស្ថាប័ននានា សៀវភៅទ្រឹស្តី និងគេហទំព័រផ្លូវការមួយចំនួន ដែលឯកសារទាំងនោះភាគច្រើនគឺសរសេរជាភាសាជប៉ុន។ ម្យ៉ាងវិញទៀត ការស្រាវជ្រាវនេះគ្រាន់តែជាការរៀបរៀងបង្ហាញនូវឯកសារដែលមានស្រាប់ និងធ្វើការវិភាគវែកញែករកលទ្ធផលនានាដោយផ្អែកលើឯកសារ

ទាំងស្រុង។ ជាពិសេសការស្រាវជ្រាវមួយនេះ គ្រាន់តែចង់រំលេចឡើងឲ្យឃើញនូវបញ្ហាមួយចំនួនពាក់ព័ន្ធនឹងការវិវត្តរវាងប្រព័ន្ធសារការីនៃប្រទេសកម្ពុជា និងប្រទេសជប៉ុន ជាពិសេសធ្វើការប្រៀបធៀបចំណុចដូចគ្នា និងខុសគ្នានៃប្រព័ន្ធសារការីនៃប្រទេសទាំងពីរតែប៉ុណ្ណោះ។

ការស្រាវជ្រាវនេះបានធ្វើឡើងដោយការប្រមូលទិន្នន័យពិតមានតាមវិធីជាច្រើន។ ជាដំបូងគឺតាមរយៈការអាន និងស្រាវជ្រាវលើស្នាដៃស្រាវជ្រាវកន្លងមកទាក់ទងនឹងសារការី។ បន្ទាប់មកធ្វើការស្វែងយល់បន្ថែមតាមរយៈការអានកម្រងច្បាប់ និងបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងប្រព័ន្ធសារការីនៃប្រទេសកម្ពុជា និងប្រទេសជប៉ុន។ បន្ទាប់មកធ្វើការ ប្រមូលពត៌មានដែលមានបច្ចុប្បន្នភាពនានាតាមរយៈបណ្តាញសារពត៌មានផ្លូវការមួយចំនួនទាំងក្នុង និងក្រៅស្រុក។ ក្នុងដំណើរការនៃការប្រមូលទិន្នន័យខាងលើភាគច្រើនធ្វើតាមបណ្តាញអ៊ីនធើណេត និងបណ្ណាល័យច្បាប់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ចំពោះការប្រមូលទិន្នន័យជាឯកសារភាសាជប៉ុន ត្រូវបានធ្វើឡើងតាមរយៈបណ្ណាល័យច្បាប់នៃមជ្ឈមណ្ឌលអប់រំ និងស្រាវជ្រាវអំពីច្បាប់ជប៉ុន(CJL)នៃសាកលវិទ្យាល័យណាហ្គោយ៉ា។

សារណានេះ ផ្តល់អត្ថប្រយោជន៍ជាច្រើនដល់វិស័យស្រាវជ្រាវផ្ទាល់ ចំពោះសាធារណជន និងសង្គមជាតិទាំងមូលផងដែរ។ តាមរយៈការស្រាវជ្រាវនេះបានប្រមូលនូវពត៌មានជាច្រើន និងការវិភាគ បកស្រាយ រកលទ្ធផលថ្មីៗមួយចំនួន ដែលជាប្រយោជន៍សម្រាប់អ្នកសិក្សា សិស្ស និស្សិតដែលធ្វើការស្រាវជ្រាវក្រោយៗទៀត ដើម្បីធ្វើការស្វែងយល់ និងយកទៅពិចារណា។ បន្ថែមពីនេះទៀត សារណានេះក៏ជាប្រភពពត៌មានទូទៅសម្រាប់សារធារណជន ជាពិសេសនិស្សិតផ្នែកនីតិសាស្ត្រដែលមានបំណងចង់ក្លាយជាសារការី ឲ្យយល់កាន់តែច្បាស់ពីលក្ខខណ្ឌរបស់វិជ្ជាជីវៈមួយនេះផងដែរ។ ជាចុងក្រោយ សារណានេះបានផ្តល់នូវការប្រៀបធៀបដែលបង្ហាញឲ្យឃើញពីភាពដូចគ្នា និងខុសគ្នានៃប្រព័ន្ធសារការីប្រទេសកម្ពុជា និងប្រទេសជប៉ុន ព្រមទាំងផ្តល់អនុសាសន៍មួយចំនួនក្នុងការចូលរួមចំណែកមួយផ្នែកតូច ដើម្បីពង្រីកការយល់ដឹង និងផ្សព្វផ្សាយ ក៏ដូចជាពង្រឹងនូវប្រព័ន្ធសារការីនៃប្រទេសទាំងពីរ។

សារណានេះចែកចេញជាពីរជំពូកធំៗ គឺជំពូកទី១បង្ហាញអំពី**ការជ្រើសតាំងសារការី និងការបង្កើតមន្ទីរសារការីនៃប្រទេសកម្ពុជា** ដោយក្នុងនោះផ្តោតទៅលើចំណុច៣សំខាន់ៗគឺ សញ្ញាណទូទៅនៃវិជ្ជាជីវៈសារការី(ផ្នែកទី១) នីតិវិធីជ្រើសតាំង និងបែបបទនៃការបង្កើតមន្ទីរសារការី(ផ្នែកទី២) និងបច្ចុប្បន្នភាពនៃវិជ្ជាជីវៈសារការីក្នុងប្រទេសកម្ពុជា(ផ្នែកទី៣)។ នៅក្នុងជំពូកទី២បង្ហាញអំពី**ការជ្រើសតាំងសារការី និងការបង្កើតមន្ទីរសារការីនៃប្រទេសជប៉ុន** ដោយក្នុងនោះផ្តោតទៅលើចំណុច៣

សំខាន់ៗដូចគ្នាផងដែរគឺ សញ្ញាណទូទៅនៃវិជ្ជាជីវៈសារការី(ផ្នែកទី១) នីតិវិធីជ្រើសតាំង និងបែបបទនៃការបង្កើតមន្ទីរសារការី(ផ្នែកទី២) និងបច្ចុប្បន្នភាពនៃវិជ្ជាជីវៈសារការីក្នុងប្រទេសជប៉ុន(ផ្នែកទី៣)។

# ជំពូកទី១

# ការជ្រើសតាំងសារការី និងការបង្កើតមន្ទីរសារការីនៃប្រទេសកម្ពុជា

វិជ្ជាជីវៈសារការី គឺជាវិជ្ជាជីវៈមួយដែលបានកកើតតាំងពីអំឡុងសតវត្សទី១៩មកម្ល៉េះ ប៉ុន្តែបែរជាប្រជាពលរដ្ឋកម្ពុជាពុំសូវជាយល់ដឹងអំពីវិជ្ជាជីវៈមួយនេះ ឲ្យបានលម្អិតនៅឡើយនោះទេ បើប្រៀបធៀបទៅនឹងវិជ្ជាជីវៈច្បាប់ដទៃទៀត ដូចជា មេធាវី ក្រឡាបញ្ជី ចៅក្រម ព្រះរាជអាជ្ញា ជាដើម ដែលជាមូលហេតុមួយអាចឲ្យយើងសន្និដ្ឋានបានថាការយល់ដឹងអំពីវិជ្ជាជីវៈសារការី នៅមានកម្រិតទាបនៅឡើយ ។ យ៉ាងណាមិញ វត្តមានសារការី ក៏ចេះតែមានការកើនឡើងគួរឲ្យកត់សម្គាល់ក្រោយក្រមរដ្ឋប្បវេណីថ្មីចូលជាធរមាន នោះក៏ដោយសារតែមុខងារសារការីត្រូវបានពង្រីកវិសាលភាព ដោយក្រមបានប្បញ្ញត្តិអំពីភាពចាំបាច់ក្នុងទំនាក់ទំនងមួយចំនួន ដែលតម្រូវឲ្យមានវត្តមានសារការីចូលរួមជាដាច់ខាត[5]។បរិបទនៃប្រទេសកម្ពុជានាពេលបច្ចុប្បន្ន កំពុងត្រូវការជាចាំបាច់នូវវត្តមានរបស់សារការីដើម្បីបំពេញមុខងារ ដោយមូលហេតុនៃការកើតឡើងនូវប្រតិបត្តិការជំនួញផ្សេងៗក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ហេតុនេះហើយយើងនឹងបង្ហាញអំពីនីតិវិធី ដើម្បីឲ្យបុគ្គលមួយរូបអាចទទួលបានលក្ខណៈសម្បត្តិជាសារការីនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយស្របតាមបទប្បញ្ញត្តិច្បាប់។

តើដើម្បីទទួលបានលក្ខណៈសម្បត្តិជាសារការីត្រូវការនូវលក្ខខណ្ឌអ្វីខ្លះ?ហើយដើម្បីបង្កើតទីកន្លែងមួយដែលសារការីអាចអនុវត្តមុខងាររបស់ខ្លួនបាននោះ តើត្រូវបំពេញនូវលក្ខខណ្ឌអ្វីខ្លះ?(ផ្នែកទី២) ប៉ុន្តែមុននឹងឈានដល់ការឆ្លើយនឹងសំណួរទាំងអស់នេះ ជាបឋមសារណានេះនឹងបង្ហាញអំពីសញ្ញាណទូទៅខ្លះៗទាក់ទងនឹងសារការីនៃប្រទេសកម្ពុជា(ផ្នែកទី១) ហើយជាចុងក្រោយនឹងបង្ហាញអំពីបច្ចុប្បន្នភាពនៃវិជ្ជាជីវៈសារការីនៃប្រទេសកម្ពុជា(ផ្នែកទី៣)។

## ផ្នែកទី១ សញ្ញាណទូទៅទាក់ទងនឹងសារការី

នៅក្នុងផ្នែកនេះនឹងបង្ហាញនូវចំណុចពីរធំៗទាក់ទងនឹងសារការីគឺ ទីមួយស្តីអំពីប្រវត្តិនៃការកកើតវិជ្ជាជីវៈក្នុងប្រទេសកម្ពុជា(១.១)ដោយផ្តោតទៅលើវត្តមាននៃវិជ្ជាជីវៈសារការីមុន(១.១.១) និងក្រោយឆ្នាំ១៩៧៥(១.១.២) និងទីពីរស្តីអំពីលិខិតដែលធ្វើឡើងដោយសារការី(១.២) ដោយផ្តោតទៅលើប្រភេទលិខិតដែលធ្វើឡើងដោយសារការី(១.២.១) ព្រមទាំងលក្ខខណ្ឌដែលនាំឲ្យមានអានុភាពគតិយុត្តនៃលិខិតដែលធ្វើឡើងដោយសារការី(១.២.២)។

[5] មាត្រា ១១០ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ស្តីអំពីការបង្កើត និង លក្ខន្តិកៈនៃនីតិបុគ្គលមូលនិធិ៖ "លក្ខន្តិកៈពុំមានអានុភាព បើពុំបានទទួលបញ្ជាក់ពីសារការី"។

## ១.១. ប្រវត្តិនៃការកកើតវិជ្ជាជីវៈសារការី

ដើម្បីឲ្យងាយស្រួលក្នុងការស្វែងយល់អំពីវិជ្ជាជីវៈសារការីនៃប្រទេសកម្ពុជាដែលចាប់កំណើត តាំងពីសតវត្សទី១៩ យើងខ្ញុំសូមបង្ហាញដោយធ្វើការបែងចែកនូវប្រវត្តិរបស់សារការីជាពីរដំណាក់កាល គឺ វិជ្ជាជីវៈសារការីមុនឆ្នាំ១៩៧៥(១.១.១) និងក្រោយឆ្នាំ១៩៧៥(១.១.១) ។

### ១.១.១ វិជ្ជាជីវៈសារការីមុនឆ្នាំ១៩៧៥

មុនឆ្នាំ១៩៧៥ ទាក់ទងនឹងវិជ្ជាជីវៈសារការីនៃប្រទេសកម្ពុជាគេឃើញមានលិខិតបទដ្ឋានគតិយុត្ត ចំនួនពីរគឺ ទី១៖ក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩២០ និងទី២៖ព្រះរាជក្រមលេខ៩១០ ន.ស ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៥។ បើក្រឡេកទៅមើលក្នុងក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩២០ យើងនឹងឃើញមាន ពាក្យថា "**លិខិតយថាភូតរបស់សារការី**" ដែលលិខិតនេះត្រូវបានគេឲ្យនិយមន័យដោយយោងទៅ តាមក្រមរដ្ឋប្បវេណីចាស់ ច្បាប់ភូមិបាលឆ្នាំ១៩៩១ និងច្បាប់ភូមិបាលឆ្នាំ២០០១ ថាជាលិខិតដែល ធ្វើតាមរូបមន្តច្បាប់ ដូចជាលិខិតបញ្ជាក់ជាដើម។ តើអ្វីទៅជាលិខិតបញ្ជាក់? យោងតាមមាត្រា៩៤៥ នៃក្រមរដ្ឋប្បវេណីចាស់បានបញ្ញត្តិ " **លិខិតបញ្ជាក់ គឺជាសំបុត្រដែលគូភាគីបានចុះហត្ថលេខា ក្រោយ ដែលគេបានអានសេចក្តីសំបុត្រទាំងអស់យ៉ាងខ្លាំងៗ ដោយក្បោះក្បាយឲ្យភាគីស្តាប់ចំពោះមុខមន្ត្រី រាជការសាធារណៈ** " ។ ចំណែកឯសន្ធានុក្រមនៃក្រមរដ្ឋប្បវេណីចាស់បានឲ្យនិយមន័យនៃ "**លិខិត បញ្ជាក់ថា ជាលិខិតដែលមេឃុំ ឬ ចាហ្វាយស្រុកបានសូត្រខ្លាំង ច្បាស់ៗឲ្យគូភាគីស្តាប់ ហើយចុះហត្ថ លេខាខ្លួនជាមួយនឹងគូភាគីលើលិខិតនោះ**"។ ដូចនេះបើយើងសង្កេតទៅលើវត្តមាននៃវិជ្ជាជីវៈសារ ការីដែលត្រូវបានលេចឡើងក្នុងក្រមរដ្ឋប្បវេណីចាស់ ហាក់មិនសូវមានភាពច្បាស់លាស់ទាំងលិខិត ដែលធ្វើឡើងដោយសារការី និងមុខងាររបស់សារការី។

ចំណែកឯ វត្តមានព្រះរាជក្រមឆ្នាំ១៩៥៥ដែលបញ្ញត្តិទាក់ទងនឹងសារការី ហាក់ដូចមានភាព លម្អិតជាក្រមរដ្ឋប្បវេណីចាស់ ដោយនៅក្នុងមាត្រា ១ បានបញ្ញតិអំពីមុខងាររបស់សារការីថា៖

"សារការីជាមន្ត្រីសាធារណៈ ដែលតាំងឡើងតាមព្រះរាជក្រឹត្យនៃរាជរដ្ឋាភិបាល ដោយមាន វត្ថុបំណង"៖

១. ទទួល និងធ្វើតាមលិខិត ឬ កិច្ចសន្យាទាំងឡាយដែលគូសញ្ញា ត្រូវធ្វើឲ្យមាន ឬ ចូលចិត្តឲ្យ មានចារិកជាលក្ខណៈតាមផ្លូវច្បាប់ ដែលតែងតែមានដល់លិខិតរបស់រាជការកាន់អំណាចសាធារណៈ។

២. ធ្វើការបញ្ជាក់កាលបរិច្ឆេទនៃលិខិតនេះ ទទួលរក្សាលិខិតនេះទុក និងចេញឲ្យសេចក្តីដើម ឬ សេចក្តីចម្លងលិខិតនេះ។

៣. ករណីកិច្ចរបស់សារការី គឺបំភ្លឺ ឲ្យដំណឹង និងទន្ទានគូសញ្ញា ដើម្បីពិនិត្យឲ្យដឹងថាសេចក្តីកត់ចុះក្នុងលិខិតទាំងនោះត្រឹមត្រូវតាមការពិត"។

ទន្ទឹមនឹងមុខងាររបស់សារការីដូចដែលបានលើកឡើងខាងលើ ព្រះរាជក្រមដដែលក៏បានកំណត់អំពីនីតិវិធីនៃការអនុវត្តមុខងាររបស់ខ្លួនផងដែរ គឺមាត្រា៦ ដោយបានបញ្ញត្តិថា "សារការីទទួលប្រតិភូកម្មអំណាចសារធារណៈ និងចេញលិខិតយថាភូតភាពដោយអនុវត្តនៅមន្ទីរសារការី"។ ត្រង់ចំណុចយើងសន្និដ្ឋានបានថា នាពេលនោះសារការីអនុវត្តមុខងាររបស់ខ្លួនក្នុងនាមរដ្ឋ(មន្ត្រីសាធាណៈ) នៅក្នុងកន្លែងដែលមានឈ្មោះថា "មន្ទីរ" ។ គេឃើញមានវត្តមានរបស់សារការីមួយរូបគឺលោកសារការី ប៉ុក ធួន ដែលត្រូវបានតែងតាំងឲ្យអនុវត្តមុខងារជាសារការី ប៉ុន្តែមិនឃើញមាននូវលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងដែលបញ្ជាក់អំពីលក្ខខណ្ឌដើម្បីក្លាយជាសារការី និង នីតិវិធីនៃការបង្កើតមន្ទីរសារការីនោះទេ[6]។

### ១.១.២ វិជ្ជាជីវៈសារការីក្រោយឆ្នាំ១៩៧៥

ដូចដែលយើងបានដឹងមកហើយថា ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាស្ថិតក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ស្ទើរគ្រប់វិស័យទាំងអស់គឺត្រូវបានលប់បំបាត់ចោល ក្នុងនោះវិស័យយុត្តិធម៌ដែលប្រមូលផ្តុំទៅដោយអ្នកច្បាប់ ឬ បុគ្គលដែលមានចំណេះដឹងខ្ពង់ខ្ពស់ ត្រូវបាន ប៉ុល ពត ដែលជាមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យសន្មតថាជាបុគ្គលគ្រោះថ្នាក់បំផុតចំពោះរបបរបស់ខ្លួន ដូចនេះហើយអ្នកច្បាប់ និងអ្នកចេះដឹងទាំងអស់ត្រូវបានសម្លាប់ចោល ហើយគេក៏មិនឃើញមានវត្តមានរបស់សារការី ឬ មន្ទីរសារការីណាមួយឡើយ[7]។ បន្ទាប់មក នៅឆ្នាំ១៩៩៣គឺជាឆ្នាំដែលប្រទេសកម្ពុជារៀបចំបោះឆ្នោតបង្កើតសភាធម្មនុញ្ញដើម្បីធ្វើសេចក្តីព្រៀងរដ្ឋធម្មនុញ្ញ ក្រោមការជួយជ្រោមជ្រែងពីអង្គការសហប្រជាជាតិ (UNTAC) ជាលទ្ធផលរដ្ឋធម្មនុញ្ញថ្មីមួយក៏ត្រូវបាន អនុម័ត និងប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣[8]។ ក្រោយពេលមានរដ្ឋធម្មនុញ្ញសម្រាប់គ្រប់គ្រងប្រទេស កម្ពុជាត្រូវធ្វើទំនើបកម្ម និងអនុម័តលិខិតបទដ្ឋានគតិយុត្តជាច្រើនទៀត ដូចជាក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ និង ក្រមនីតិវិធីព្រហ្មទណ្ឌជាដើម។ ដោយមានកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជា និង រាជរដ្ឋាភិបាលជប៉ុនក្រោមកម្មវិធីសហប្រតិបត្តិការដើម្បី

[6] បទបង្ហាញស្តីពី "វិជ្ជាជីវៈសារការី" ដោយកញ្ញា ជឹង ស្រីទូច, សិស្សសារការីជំនាន់ទី១នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៦។

[7] បទបង្ហាញស្តីពី "វិជ្ជាជីវៈសារការី" ដោយកញ្ញា ជឹង ស្រីទូច, សិស្សសារការីជំនាន់ទី១នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៦។

[8] ជុំ អ៊ឹម,"ស្ថាប័ននយោបាយព្រះរាជាណាចក្រកម្ពុជា",បោះពុម្ពលើកទី១(ភ្នំពេញះជោគជ័យ,២០១២),១០៧។

អភិវឌ្ឍន៍ប្រព័ន្ធយុត្តិធម៌របស់ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ហៅកាត់ JICA ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់ពាក់ព័ន្ធនឹងផ្នែកឯកជនជាច្រើនត្រូវបានអនុម័ត ព្រមទាំងប្រកាសឲ្យប្រើ។ វត្តមានសារការីក៏បានលេចឡើងម្តងទៀតនៅក្នុងលិខិតបទដ្ឋានទាំងនោះ ដែលធ្វើឲ្យមុខងារសារការីកាន់តែមានភាពចាំបាច់។

ប៉ុន្តែបើយើងក្រឡេកមកមើលចំនួនរបស់សារការី និង មន្ទីរសារការីនៅក្នុងប្រទេសកម្ពុជា គិតត្រឹមឆ្នាំដែលក្រមទាំងពីរត្រូវបានអនុម័តគឺមានតែ៣ប៉ុណ្ណោះដែលត្រូវបានតែងតាំងដោយអនុក្រឹត្យ គឺលោកសារការី បែនសុន សម័យ[9] លោកសារការី លី តៃសេង និងលោកសារការី តាន់ហ៊ាន ដារ័ណ្ណ[10]។ ស្របពេលនឹងជំនួយផ្នែកច្បាប់របស់រាជរដ្ឋាភិបាលជប៉ុន រាជរដ្ឋាភិបាលកម្ពុជាបាន សហការជាមួយស្ថាប័នឧត្តមក្រុមប្រឹក្សាជាន់ខ្ពស់នៃសារការីប្រទេសបារាំង ដើម្បីបណ្តុះបណ្តាលសារការីកម្ពុជា ដោយខាងភាគីបារាំងបានបញ្ជូនសិស្សសារការីជំនាន់ទី១របស់ប្រទេសកម្ពុជាឲ្យទៅចុះកម្មសិក្សាជាក់ស្តែងនៅមន្ទីរសារការីប្រទេសបារាំងរយៈពេល៦ខែ។

គួរកត់សម្គាល់ថា សាលាភូមិន្ទវិជ្ជាជីវៈសារការីត្រូវបានបង្កើតនូវឆ្នាំ២០០៨ ដោយអនុក្រឹត្យ អនក្រ.បកចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨ ក្រោយពេលដែលមានការតែងតាំងសារការីទាំង៣រូបខាងលើ ដែលចំណុចនេះបានបង្ហាញនូវកង្វះខាតក្នុងការជំរុញ ក៏ដូចជាការជ្រោមជ្រែងពីសំណាក់ស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងយុត្តិធម៌ បើប្រៀបធៀបទៅនឹងវិជ្ជាជីវៈច្បាប់ដទៃទៀត (មេធាវី ក្រឡាបញ្ជី ចៅក្រម...)។

បន្ទាប់ពីបានសិក្សាអំពីប្រវត្តិទាក់ទងនឹងវិជ្ជាជីវៈសារការីរួចមក ចំណុចបន្តសារណានេះនឹងបង្ហាញអំពីលិខិតដែលធ្វើឡើងដោយសារការី។

## ១.២. លិខិតដែលធ្វើឡើងដោយសារការី

ចំណុចនេះនឹងបង្ហាញអំពីប្រភេទនៃលិខិតដែលធ្វើឡើងដោយសារការី(១.២.១) លក្ខខណ្ឌដែលនាំឲ្យលិខិតទាំងនោះមានអានុភាពគតិយុត្ត(១.២.២) និងតម្លៃប្រថាប់ត្រាដែលជាតម្លៃសេវារបស់សារការីក្នុងការធ្វើលិខិត(១.២.៣)។

---

[9] អនុក្រឹត្យលេខ ៥០៥ អនក្រ.តត. ស្តីពីការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, ០៩ ធ្នូ ២០០១។

[10] អនុក្រឹត្យលេខ ១៩៩ អនក្រ.បក ស្តីពីការទទួលស្គាល់មន្ទីសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា, ២៣ កញ្ញា ២០០៨។

### ១.២.១. ប្រភេទលិខិតដែលធ្វើឡើងដោយសារការី

លិខិតដែលធ្វើឡើងដោយសារការីជាគោលការណ៍មានចំនួន៣ប្រភេទគឺកិច្ចសន្យា (១.២.១.១) លិខិតឯកតោភាគី(១.២.១.២) និងលិខិតដែលត្រូវបញ្ជាក់ភាពពិត(១.២.១.៣)។

#### ១.២.១.១. កិច្ចសន្យា

កិច្ចសន្យា សំដៅទៅលើកិរិយាដែលបុគ្គលពីរនាក់ ឬ ច្រើននាក់មានឆន្ទៈត្រូវគ្នា ព្រមបង្កើត កែប្រែ ឬ រំលត់កាតព្វកិច្ច[11]។ នៅក្នុងក្រមរដ្ឋប្បវេណីបានបញ្ញត្តិអំពីកិច្ចសន្យាចំនួន១២ប្រភេទដែលមានដូចជា៖ កិច្ចសន្យាលក់-ទិញ, ការដូរ, ប្រទានកម្ម, កិច្ចសន្យាខ្ចីបរិភោគ, ភតិសន្យា(កិច្ចសន្យាជួល), កិច្ចសន្យាខ្ចីប្រើ, កិច្ចសន្យាអាណត្តិ, កិច្ចសន្យាម៉ៅការ, កិច្ចសន្យាការងារ, កិច្ចសន្យាបញ្ញើ, កិច្ចសន្យាក្រុមហ៊ុន, កិច្ចសន្យាធនលាភសាមយិកមួយជីវិត(កិច្ចសន្យាធានារ៉ាប់រង)។

#### ១.២.១.២. លិខិតឯកតោភាគី

ជាដំបូងយើងត្រូវដឹងអំពីនិយមន័យនៃពាក្យ"សកម្មភាពឯកតោភាគី"ជាមុនសិន។ សកម្មភាពឯកតោភាគី សំដៅទៅលើទៅលើសកម្មភាពដែលបង្កើត កែប្រែ ឬ រំលត់កាតព្វកិច្ចដោយការបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យ ដោយភាគីតែម្ខាង ឬ ដោយអនុវត្តសិទ្ធិដែលបានទទួលតាមកិច្ចសន្យា ឬ តាមបញ្ញត្តិនៃច្បាប់[12]។ ដូចនេះលិខិតឯកតោភាគី គឺមានជាអាទិ៍ មតកសាសន៍ អច្ច័យទានជាដើម។

#### ១.២.១.៣. លិខិតដែលត្រូវបញ្ជាក់ភាពពិត

ចំពោះលិខិតប្រភេទនេះ មិនមានបទបញ្ញត្តិពាក់ព័ន្ធណាមួយកំណត់អំពីនិយមន័យឲ្យបានច្បាស់លាស់នោះទេ ប៉ុន្តែយើងអាចរកឃើញពាក្យនេះនៅក្នុងមាត្រា៣នៃអនុក្រឹត្យស្តីពីការបង្កើតមន្ទីរសារការី នីតិនីវន្តន៍ និងអនុក្រឹត្យស្តីពីការបង្កើតមន្ទីរសារការីផ្សេងទៀត[13]ដែលនិយាយអំពីតួនាទី

[11] លេខ១១៥, សន្ទានុក្រមផ្នែករដ្ឋប្បវេណី ដកស្រង់ពី«សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី» ដែលត្រូវបានរៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រីនៅឆ្នាំ២០០៧។

[12] លេខ១៩១, សន្ទានុក្រមផ្នែករដ្ឋប្បវេណី ដកស្រង់ពី«សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី» ដែលត្រូវបានរៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រីនៅឆ្នាំ២០០៧។

[13] អាចរកមើលបានក្នុងឧបសម្ព័ន្ធទី២។

និង ភារកិច្ចរបស់សារការីដោយក្នុងនោះបានប្បញ្ញត្តិថា "**ធ្វើការបញ្ជាក់នូវភាពពិតប្រាកដនូវឯកសារថតចម្លងផ្សេងៗ**" [14]។

ក្រៅពីលិខិតខាងលើ សារការីក៏មានតួនាទីផ្តល់យថាភូតភាពលើលក្ខន្តិកៈក្រុមហ៊ុន ព្រមទាំងអនុវត្តកិច្ចការផ្សេងៗទៀតដែលស្ថិតនៅក្នុងវិសាលភាពនៃការប្រកបវិជ្ជាជីវៈសារការី ស្របទៅតាមក្រម ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ១.២.២. លក្ខខណ្ឌនៃលិខិតដែលមានអានុភាពគតិយុត្ត

តួនាទីចម្បងរបស់សារការី គឺតាក់តែងលិខិតយថាភូត។ **លិខិតយថាភូត** គឺជាលិខិតរបស់សារការី សម្រេចតាមការព្រមព្រៀងរបស់គូភាគីតាំងពីដំបូង។ ក្នុងចំណោមលិខិតដែលមានអានុភាពនេះ គូភាគីសច្ចាប្រណិធានថានឹងអនុវត្តតាមខ្លឹមសារនៃការព្រមព្រៀងគ្នា។ សំខាន់ជាងនេះទៅទៀតលិខិតយថាភូតមានតម្លៃស្មើនឹងសាលក្រម និងអាចអនុវត្តបាន [15] ។ ពោលគឺលិខិតយថាភូត ឬលិខិតដែលធ្វើឡើងដោយសារការីមានអានុភាពអនុវត្តភ្លាមដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីតុលាការនោះទេ ។ ដូចនេះ ចំពោះទម្រង់នៃលិខិតយថាភូតមិនត្រូវបានកំណត់យកគោលការណ៍រួមណាមួយដើម្បីយកមកអនុវត្តនោះទេ ប៉ុន្តែច្បាប់បានកំណត់ថា លិខិតយថាភូតត្រូវបំពេញនូវទម្រង់អតិបរមាសម្រាប់សកម្មភាពមួយចំនួន ដើម្បីឲ្យលិខិតនោះមានអានុភាពគតិយុត្តដូចជា មតកសាសន៍តាមទម្រង់យថាភូតជាដើម [16] ដូចនេះយើងសូមលើកយកមតកសាន៍ដែលបង្កើតជាលិខិតយថាភូតយកមកបង្ហាញ។

មាត្រា ១១៧៣. មតកសាសន៍ដោយលិខិតយថាភូត

១.មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើងដោយម្ចាស់បណ្តាំនៅចំពោះមុខសារការី តាមទម្រង់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ខាងក្រោមនេះ។

២.មតកសាសន៍ដោយលិខិតយថាភូតត្រូវធ្វើឡើងដោយយោងតាមទម្រង់ដូចខាងក្រោមនេះ ៖

ក.ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិច២(ពីរ)នាក់។

ខ.ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍ចំពោះសារការី។

គ.សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះជាលាយលក្ខណ៍អក្សរ ហើយត្រូវសូត្រឲ្យម្ចាស់បណ្តាំ និងសាក្សីនោះស្តាប់។

[14] អនុក្រឹត្យលេខ ៣៣ អនក្រ.បក ស្តីពីការបង្កើតមន្ទីរសារការី នីតិនិវន្តរ៍ នៃព្រះរាជាណាចក្រកម្ពុជា, ១២ មីនា ២០១៥។

[15] មាត្រា ២០១ នៃច្បាប់ភូមិបាលឆ្នាំ២០០១

[16] មាត្រា ១១៧០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

ឃ.បន្ទាប់ពីម្ចាស់បណ្ដាំ និងសាក្សី បានទទួលស្គាល់ថាកំណត់ជាលាយលក្ខណ៍អក្សរនោះត្រឹមត្រូវហើយ ជននីមួយៗត្រូវធ្វើឲ្យមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និងលំនៅឋាន ហើយត្រូវចុះហត្ថលេខារៀងខ្លួន។ ប៉ុន្តែបើម្ចាស់បណ្ដាំមិនអាចសរសេរអក្សរ ឬ មិនអាចចុះហត្ថលេខាបានទេ សារការីជំនួសការសរសេរ និងហត្ថលេខាដូចកំណត់ខាងលើនេះ ដោយសរសេរឈ្មោះ អាយុ និងលំនៅឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមនូវហេតុនោះផង។

ង.សារការីត្រូវសរសេរថ្ងៃខែឆ្នាំ ហើយត្រូវចុះហត្ថលេខា។

ក្រោយពីបានពិនិត្យទៅលើមាត្រា១១៧៣ ស្ដីអំពីមតកសាសន៍ដោយលិខិតយថាភូតរួចមក យើងអាចសន្និដ្ឋានអំពីចំណុចដែលចាំបាច់ក្នុងទម្រង់នៃលិខិតយថាភូតមានចំនួន៤ដូចខាងក្រោម៖

### ១.២.២.១. វត្តមានរបស់គូភាគីហត្ថលេខី

ដើម្បីផ្ទៀងផ្ទាត់ និងបញ្ជាក់ឲ្យបានច្បាស់លាស់អំពីអត្តន័យ ក៏ដូចជាខ្លឹមសារនៃលិខិតណាមួយដែលតម្រូវឲ្យសារការីផ្ដល់យថាភូតភាព ឬ ផ្ដល់ការបញ្ជាក់ ជាពិសេសដើម្បីឲ្យលិខិតនោះធ្វើឡើងដោយស្របតាមទម្រង់នៃលិខិតយថាភូត ព្រមទាំងដើម្បីផ្ទៀងផ្ទាត់ និង បញ្ជាក់អំពីអត្តសញ្ញាណរបស់គូភាគី វត្តមានរបស់គូភាគីគឺជាលក្ខខណ្ឌដែលមិនអាចខ្វះបាន។ គូភាគីត្រូវមានវត្តមានក្នុងពេលចុះហត្ថលេខាលើលិខិតនៅចំពោះមុខសារការី។ ប៉ុន្តែបើម្ចាស់បណ្ដាំមិនអាចសរសេរអក្សរ ឬ មិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និងហត្ថលេខាលើលិខិត ដោយសរសេរឈ្មោះ អាយុ និងលំនៅឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមនូវហេតុនោះផង[17]។

### ១.២.២.២. វត្តមានសារការី

សារការី គឺជាអ្នកវិជ្ជាជីវៈច្បាប់ដែលទទួលបានការបណ្ដុះបណ្ដាលយ៉ាងត្រឹមត្រូវ ឬ ជាបុគ្គលដែលមានសមត្ថភាពផ្នែកច្បាប់ដ៏ច្បាស់លាស់មួយ ដែលមានតួនាទីក្នុងការពិនិត្យភាពត្រឹមត្រូវ ឬ ភាពស្របច្បាប់នៃលិខិតដែលខ្លួនធ្វើឡើងឲ្យដល់គូភាគី តាមរយៈការពន្យល់អំពីចំណុចសំខាន់ដែលបានកំណត់ក្នុងលិខិត ដោយធានាថាលិខិតនោះនឹងមិនមានភាពមិនច្បាស់លាស់ណាមួយដែលអាចនាំឲ្យមានវិវាទនាពេលអនាគត ជាពិសេសគឺត្រូវពិចារណាអំពីតុល្យភាពនៃផលប្រយោជន៍របស់គូភាគីទាំងសងខាង។

ទាក់ទងនឹងចំណុចនេះ មាត្រា ១ នៃព្រះរាជក្រម នស ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ ក៏បានប្បញ្ញត្តិផងដែរថា សារការីមានករណីយកិច្ចត្រូវបំភ្លឺឲ្យដំណឹង និងទូន្មានគូសញ្ញាអំពីលិខិតដែលអ្នក

[17] មាត្រា ១១៧៣ ចំណុច ឃ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

នេះបានធ្វើ ឬ មានបំណងនឹងធ្វើ ហើយត្រូវពិនិត្យឲ្យដឹងថា សេចក្តីកត់ចុះក្នុងលិខិតនោះត្រឹមត្រូវតាមការពិត។ ជាក់ស្តែង ចំពោះមតកសាសន៍ សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍តាមរបស់ម្ចាស់បណ្តាំនោះជាលាយលក្ខណ៍អក្សរ ហើយត្រូវសូត្រឲ្យម្ចាស់បណ្តាំ និងសាក្សីនោះស្តាប់[18]។

### ១.២.២.៣. វត្តមានសាក្សី

សាក្សី គឺជាតតិយជនដែលចូលរួមដឹងឮក្នុងកិច្ចគតិយុត្តណាមួយ ឬ ចូលរួមអះអាងបញ្ជាក់កិច្ចគតិយុត្តណាមួយ។ យោងតាមមាត្រា ១១៧២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់អំពីបុគ្គលដែលមិនអាចក្លាយជាសាក្សី មានដូចជា៖

- អនីតិជន ឬ ជននៅក្រោមអាណាព្យាបាលធម្មតា
- ជនដែលត្រូវសន្មតថាជាសន្តតិជន អច្ច័យលាភី ហើយនិងសហព័ទ្ធ និងញាតិលោហិតខ្សែផ្ទាល់របស់ជនទាំងនោះ។
- បើសារការីជាអ្នកពាក់ព័ន្ធក្នុងការធ្វើមតកសាសន៍ជាលិខិតយថាភូត ឬ ជាលិខិតមតកសាសន៍សម្ងាត់ សហព័ន្ធរបស់សារការី ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី និងនិយោជិតរបស់សារការី។

នៅក្នុងការធ្វើមតកសាសន៍ជាលិខិតយថាភូត ចាំបាច់ត្រូវមានវត្តមានរបស់សាក្សីពីរនាក់នៅចំពោះមុខសារការី ដើម្បីបញ្ជាក់ឲ្យលិខិតនោះកាត់តែមានភាពរឹងមាំ។

### ១.២.២.៤.ហត្ថលេខារបស់សារការី

ហត្ថលេខារបស់សារការីដែលបានចុះលើលិខិត គឺជាការបញ្ជាក់អំពីភាពពិត ត្រឹមត្រូវ និងការបង្កើតឲ្យមាននូវអានុភាពគតិយុត្តលើលិខិតនោះ។ ដូចនេះ មុននឹងសារការីចុះហត្ថលេខា ក្នុងនាមជាមន្ត្រីសាធារណៈដែលទទួលអំណាចតាមរយៈប្រតិភូកម្មហត្ថលេខា សារការីត្រូវត្រួតពិនិត្យឲ្យបានលម្អិត និងម៉ត់ចត់អំពីអត្ថន័យនៃលិខិត លិខិតរដ្ឋបាលដែលពាក់ព័ន្ធដទៃទៀត ជៀសវាងការកើតឡើងនូវកំហុសណាមួយដែលនាំឲ្យខូចប្រយោជន៍ដល់គូភាគីណាម្ខាងនៃកិច្ចសន្យា ក៏ដូចជាភាគីពាក់ព័ន្ធដទៃទៀត។

[18] មាត្រា ១១៧៣ ចំណុច គ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

### ១.២.៣. តម្លៃប្រថាប់ត្រារបស់សារការី

ដើម្បីឲ្យលិខិតណាមួយដែលធ្វើឡើងដោយសារការីមានអានុភាពគតិយុត្ត នៅលើលិខិតនោះត្រូវមានហត្ថលេខា និងត្រា[19]របស់សារការី។ ដូចនេះ ត្រារបស់សារការី គឺជាសញ្ញាសម្រាប់សម្គាល់អំពីកិច្ចគតិយុត្តក្នុងការអនុវត្តតួនាទី និងមុខងាររបស់ខ្លួនផង ថែមទាំងជាសញ្ញាដែលបញ្ជាក់អំពីភាពត្រឹមត្រូវតាមច្បាប់ និងអត្ថិភាពនៃអានុភាពគតិយុត្តលើលិខិតមួយផងដែរ។ នាពេលបច្ចុប្បន្ននេះមិនទាន់មានលិខិតបទដ្ឋានគតិយុត្តណាមួយបញ្ញត្តិអំពីតម្លៃប្រថាប់ត្រា ឬ តម្លៃក្នុងការអនុវត្តមុខងាររបស់សារការីនៅឡើយទេ។

ជាបន្តទៅទៀត សារណានេះនឹងបង្ហាញអំពីនីតិវិធីជ្រើសតាំងសារការី និងបែបបទនៃការបង្កើតមន្ទីរសារការីនៃប្រទេសកម្ពុជា។

## ផ្នែកទី២ នីតិវិធីជ្រើសតាំងសារការី និងបែបបទនៃការបង្កើតមន្ទីរសារការី

នៅក្នុងផ្នែកនេះយើងនឹងបង្ហាញនូវពីរចំណុចធំៗគឺ លក្ខខណ្ឌដើម្បីក្លាយជាសារការី(២.១) និងលក្ខខណ្ឌក្នុងការបង្កើតមន្ទីរសារការីនៃព្រះរាជណាចក្រកម្ពុជា (២.២) ។

### ២.១. លក្ខខណ្ឌដើម្បីក្លាយជាសារការី

ចាប់តាំងពីការកកើតវត្តមានរបស់សារការី បើយើងនិយាយពីលក្ខខណ្ឌដើម្បីទទួលបានមុខងារជាសារការី គេពុំទាន់ឃើញមានបញ្ញត្តិណាចែងជាក់លាក់ អំពីលក្ខខណ្ឌដែលទទួលបានមុខងារជាសារការីឡើយ។ យើងអាចឃើញមាននៅក្នុងព្រះរាជក្រម លេខ ៩១០ ន.ស. ចុះថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ ត្រូវបានកំណត់ផងដែរអំពីលក្ខខណ្ឌដើម្បីទទួលបានមុខងារជាសារការី ប៉ុន្តែមិនសូវមានភាពច្បាស់លាស់នោះទេ ដែលលក្ខខណ្ឌមានកំណត់ដូចខាងក្រោម៖

បេក្ខជនដែលសមកាន់តំណែងជាសារការី ត្រូវមានអាយុចាប់ពី៣០ឆ្នាំយ៉ាងតិច មានសញ្ញាបត្រច្បាប់ ឬ ថ្នាក់បណ្ឌិតច្បាប់ និងមានបទពិសោធន៍ការងារយ៉ាងតិចពីរឆ្នាំនៅក្នុងមន្ទីសារការី ដែលតាំងនៅប្រទេសកម្ពុជា ឬ ប្រទេសណាមួយក្នុងសហភាពបារាំង[20]។ ចំពោះការកំណត់លក្ខខណ្ឌខាងលើនេះ ការតម្រូវឲ្យមានសញ្ជាតិខ្មែរ មានសិទ្ធិពលរដ្ឋ និងនយោបាយ វាជាលក្ខខណ្ឌធម្មតាទូទៅដែលបេក្ខជនត្រូវតែមាន មុននឹងទទួលបានមុខងារជាមន្ត្រីរាជការណាមួយ ដើម្បីបម្រើប្រយោជន៍ដល់

[19] ត្រា គឺជាប្រដាប់មានស្នាមចម្លាក់ ជាគ្រឿងសម្គាល់សម្រាប់សម្គាល់លើសំបុត្រ ចុតហ្មាយ ដីកា បញ្ជី សំបុត្រសន្យាផ្សេងៗ តាមមុខងារមុខក្រសួងបោះត្រា។ (សម្តេចសង្ឃរាជជួនណាត,"វចនានុក្រមខ្មែរ",បោះពុម្ពលើកទី១(ភ្នំពេញ៖ពុទ្ធសាសនបណ្ឌិត,១៩៦៧)។

[20]មាត្រា ៧ នៃរាជក្រមលេខ ៩១០ ន.ស. ចុះថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ ១៩៥៤ ។

ប្រជាជនខ្មែរ និងសង្គមជាតិទាំងមូល ។ ចំពោះការកំណត់អាយុវិញ គឺជាការកំណត់មួយឲ្យវាមានលក្ខណៈសមស្របទៅនឹងលក្ខខណ្ឌចម្បងផ្សេងៗ និង ស្របជាមួយស្ថានភាពសង្គមប៉ុណ្ណោះ។ ចំណុចដែលយើងគួរកត់សម្គាល់ គឺត្រង់លក្ខខណ្ឌដែលតម្រូវឲ្យបេក្ខជន មានសញ្ញាបត្រច្បាប់ ឬ ថ្នាក់បណ្ឌិតច្បាប់ នៅក្នុងមន្ទីរសារការី ដែលតាំងនៅប្រទេសខ្មែរ ឬ ប្រទេសណាមួយក្នុងសហភាពបារាំង។ លក្ខខណ្ឌដែលតម្រូវឲ្យមានបទពិសោធន៍នៅក្នុងមន្ទីរសារការី ដែលតាំងនៅប្រទេសខ្មែរ ជាលក្ខខណ្ឌទូទៅមួយតែប៉ុណ្ណោះ ប៉ុន្តែចំណុចដែលជាលក្ខខណ្ឌចម្បងនោះគឺថា ក្រៅពីមន្ទីរសារការីដែលតាំងនៅខ្មែរ បេក្ខជនដែលមានបទពិសោធន៍ពីមន្ទីរសារការីដែលតាំងនៅប្រទេសណាមួយក្នុងសហភាពបារាំងប៉ុណ្ណោះទើបអាចយកជាការបាន។

លើសពីនេះទៅទៀត ចំពោះបេក្ខជនដែលមានសមត្ថភាពច្បាប់ ឬ សញ្ញាបត្រសមមូល និងសមត្ថភាពច្បាប់ ព្រមទាំងបេក្ខជនដែលមានសញ្ញាបត្រវិទ្យាស្ថានយុត្តិធម្មសាស្ត្រ និងសេដ្ឋសាស្ត្ររបស់ជាតិ រយៈពេលនៃបទពិសោធន៍ ត្រូវមានយ៉ាងតិច ៥ ឆ្នាំ។ យោងតាមការកំណត់នេះ យើងអាចកំណត់នូវបេក្ខជនដែលអាចទទួលបានមុខងារជាសារការី មាន ៣ គឺៈ

- **បេក្ខជនទី១.** រាជរដ្ឋាភិបាល អាចតែងតាំងឲ្យកាន់តំណែងជាសារការី ដោយមិនគិតពីបទពិសោធន៍នូវបេក្ខជនណា ដែលបានបំពេញលក្ខខណ្ឌ អាយុ សញ្ជាតិ និងសីលធម៌ពេញបរិបូណ៌ ក្នុងរយៈពេល ៣ ឆ្នាំ គិតចាប់ពីថ្ងៃដែលព្រះរាជក្រមនេះចូលជាធរមាន ហើយក៏តម្រូវឲ្យបេក្ខជននោះត្រូវមានសញ្ញាបត្រផង[21]។

- **បេក្ខជនទី២.** បេក្ខជនណា ដែលមានត្រឹមសញ្ញាបត្រ សមត្ថភាពច្បាប់ ឬ សញ្ញាបត្រសមមូល និងសមត្ថភាពច្បាប់ អាចតែងតាំងក្នុងតំណែងសារការីក្នុងកំណត់ពេល៥ឆ្នាំ ហើយបេក្ខជននោះត្រូវបំពេញលក្ខណៈ អាយុ សញ្ជាតិ និងសីលធម៌ពេញបរិបូរណ៌ធម្មតា ។ លុះផុតរយៈពេល ៥ ឆ្នាំហើយ បេក្ខជននេះទុកជាបានបំពេញសមត្ថកិច្ច មានបទពិសោធន៍ដោយហាត់ធ្វើការហើយត្រូវតែងតាំងបេក្ខជននោះជាសារការីអស់មួយជីវិត ។

- **បេក្ខជនទី៣.** បេក្ខជនណា ដែលគ្មានសញ្ញាបត្រ តែត្រូវបានបញ្ជាក់ថាបានធ្វើការប្រកបវិជ្ជាជីវៈចំនួន១៥ឆ្នាំ ក្នុងក្របខណ្ឌជាន់ខ្ពស់ ក្នុងរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា អាចត្រូវតែងតាំងជាសារការីក្នុងរយៈពេល៥ឆ្នាំ។ លុះចប់រយៈពេល៥ឆ្នាំហើយ គឺអាចធ្វើការតែងតាំងជាថ្មីបាន ប្រសិនបើបេក្ខជននោះបានបំពេញលក្ខខណ្ឌ អាយុ សញ្ជាតិ និងសីលធម៌ពេញបរិបូណ៌ ។ បេក្ខជនជំពូកនេះ អាចតែងតាំងអស់មួយជីវិតបាន ប្រសិនបើជាខ្លួនមានសញ្ញាបត្រ សមត្ថភាពច្បាប់ ឬ សញ្ញាបត្រសមមូល និងសមត្ថភាពច្បាប់រយៈពេល៥ឆ្នាំ ដែលបានតែងតាំងខ្លួនបណ្តោះ

[21]មាត្រា ៨ អន្តរបញ្ញត្តិ ។

អាសន្ន។ ការតែងតាំងអស់មួយជីវិត មិនអាចធ្វើបានទេបើសាមីខ្លួនមិនទាន់ធ្វើជាមេមន្ទីរសារការី រយៈពេល៥ឆ្នាំនោះ ។ បន្ថែមពីលើលក្ខខណ្ឌខាងលើ ការតែងតាំងសារការីដែលត្រូវធ្វើតាមព្រះរាជក្រមនេះ ត្រូវកម្រិតប្រាក់ធានា ដោយមេមន្ទីរត្រូវបង់មុន និងទទួលសម្បថសច្ចាប្រណិធានផង[22]។

ទាំងនេះ គឺជាលក្ខខណ្ឌដែលតម្រូវឲ្យបេក្ខជនបំពេញដើម្បីក្លាយខ្លួនជាសារការី ប៉ុន្តែដោយព្រះរាជក្រមនេះមិនត្រូវបានគេយកមកអនុវត្តរហូតដល់បច្ចុប្បន្ន ហើយគ្មានលិខិតបទដ្ឋានណាមួយបញ្ញត្តិអំពីការនិរាករណ៍ព្រះរាជក្រមខាងលើ ទើបមានសំនួរចោទឡើងថា តើនៅពេលបច្ចុប្បន្ននេះ យើងត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះដើម្បីទទួលបានមុខងារជាសារការី?

ដើម្បីទទួលបានលក្ខណៈសម្បត្តិជាសារការីដែលអនុវត្តមុខងាររបស់ខ្លួនប្រកបដោយវិជ្ជាជីវៈស្របច្បាប់ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតឲ្យមានស្ថាប័ន ធ្វើការការបណ្តុះបណ្តាលបុគ្គលគ្រប់រូបដើម្បីក្លាយជាសារការី នោះគឺសាលាភូមិន្ទវិជ្ជាជីវៈសារការី។ ទន្ទឹមនឹងនេះ ដោយសារភាពចាំបាច់នូវវត្តមានរបស់សារការីនាពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជាក៏បានចេញអនុក្រឹត្យតែងតាំងបុគ្គលមួយចំនួន ដែលកំពុងបម្រើការងារទាក់ទងនឹងវិស័យច្បាប់ឲ្យមានមុខងារមួយទៀតបន្ថែមពីលើមុខងារបច្ចុប្បន្ន ជាឧទាហរណ៍តែងតាំងបន្ថែមលើមុខងារជាមេធាវី បន្ទាប់ពីការតែងតាំង បុគ្គលនោះនឹងក្លាយជាមេធាវីសារការី។ ជារួមដើម្បីក្លាយជាសារការី យើងអាចជ្រើសរើសនូវមធ្យោបាយពីរ ទី១គឺការទទួលបានការបណ្តុះបណ្តាលពីសាលាភូមិន្ទវិជ្ជាជីវៈសារការី(២.១.១) និងទី២ត្រូវបានតែងតាំងដោយពីរាជរដ្ឋាភិបាល (២.១.២)។

### ២.១.១. ការបណ្តុះបណ្តាលក្នុងសាលាភូមិន្ទវិជ្ជាជីវៈសារការី

សាលាភូមិន្ទវិជ្ជាជីវៈសារការី គឺជាស្ថាប័នមួយដែលបានបង្កើតឡើងក្រោមការគ្រប់គ្រងរបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ[23] ដែលមានឈ្មោះផ្លូវការ គឺសាលាភូមិន្ទសារការីនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។ ស្ថាប័នសម្រាប់ធ្វើការបណ្តុះបណ្តាលសារការីមួយនេះ ត្រូវបានបង្កើតឡើងតាមអនុក្រឹត្យលេខ ១១៧ អនក្របក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨ ។ ដើម្បីក្លាយជាសារការីតាមរយៈការទទួលបានការបណ្តុះបណ្តាលនៅសាលាភូមិន្ទវិជ្ជាជីវៈសារការី ដាច់ខាតត្រូវតែឆ្លងកាត់ការប្រឡងប្រជែង(២.១.១.១)។ បន្ទាប់ពីការប្រឡងចូលជាប់ជាស្ថាពរ បុគ្គលនោះត្រូវទទួលបានការបណ្តុះបណ្តាលស្របតាមកម្មវិធីសិក្សា ដែលសាលាភូមិន្ទវិជ្ជាជីវៈជាអ្នកដាក់ចេញ(២.១.១.២)។ជាគោលការណ៍

[22]មាត្រា ៩ នៃព្រះរាជក្រមលេខ ៩១០ ចុះថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ ១៩៥៤ ។

[23]រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ(រ.ប.វ.ត)ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/០១០៥/០១៩ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥ គឺជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានស្វ័យភាពខាងរដ្ឋបាល និងហិរញ្ញវត្ថុ។

សិស្សសារការីរបស់សាលាភូមិន្ទសារការីនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវឆ្លងកាត់ការបណ្តុះបណ្តាលរយៈពេល៣០ខែ បន្ទាប់ពីបានប្រលងជាប់នូវវិញ្ញាសារដែលបានដាក់ជូន។ការបណ្តុះបណ្តាលនេះចែកចេញជាពីរដំណាក់កាល៖

- ដំណាក់កាលធ្វើសិក្ខាគារិកមានរយៈពេល ១២ ខែ
- ដំណាក់កាលធ្វើកម្មសិក្សា មានរយៈពេល ១៨ ខែ ។

### ២.១.១.១.ការប្រឡងប្រជែង

ដើម្បីទទួលបានការប្រឡងប្រជែង បេក្ខជនទាំងអស់ត្រូវបំពេញតាមលក្ខខណ្ឌមួយចំនួនជាមុនសិន ដែលលក្ខខណ្ឌទាំងអស់នេះត្រូវបានបញ្ញត្តិក្នុងសេចក្តីព្រៀងច្បាប់ស្តីពីសារការី(២.១.១.១.១) ទន្ទឹមនឹងនេះនៅក្នុងគេហទំព័រផ្លូវការរបស់សាលាភូមិន្ទវិជ្ជាជីវៈសារការី [24] ក៏បានបង្ហាញផងដែរអំពីវិញ្ញាសារដែលបេក្ខជនត្រូវទទួលការប្រឡង(២.១.១.១.២)។

#### ២.១.១.១.១.លក្ខខណ្ឌជាបេក្ខភាពប្រឡងប្រជែង

ដើម្បីក្លាយជាបេក្ខភាពដែលអាចចូលរួមប្រឡងប្រជែងបាន បេក្ខជនទាំងអស់ត្រូវគោរពលក្ខខណ្ឌដូចខាងក្រោម៖

- បេក្ខជនទាំងពីរភេទត្រូវមានសញ្ជាតិខ្មែរ។ ចំពោះបេក្ខជនជានិស្សិត ត្រូវមានអាយុមិនលើសពី៣៥ឆ្នាំ រីឯបេក្ខជនជាមន្ត្រីរាជការ ត្រូវមានអាយុមិនលើសពី៥០ឆ្នាំ គិតមកត្រឹមថ្ងៃប្រឡង។
- ត្រូវមានសញ្ញាបត្រនីតិសាស្ត្រឡើងទៅ
- ត្រូវមានលិខិតថ្កោលទោសបញ្ជាក់ថាមិនធ្លាប់ជាប់ទោសពីបទមជ្ឈឹម ឬ បទឧក្រិដ្ឋ
- ត្រូវមានកាយសម្បទាគ្រប់គ្រាន់។

បុគ្គលដែលមានបំណងចង់ក្លាយជាសារការី តាមរយៈការបណ្តុះបណ្តាលនៅសាលាភូមិន្ទសារការីត្រូវតែជាបេក្ខជនដែលមានលក្ខណៈសម្បត្តិដូចបានរៀបរាប់ខាងលើជាដាច់ខាត។

#### ២.១.១.១.២.វិញ្ញាសាប្រឡងប្រជែង

ក្រោយពីបំពេញនូវលក្ខខណ្ឌដែលអាចជាបេក្ខភាពប្រឡងប្រជែងហើយ បេក្ខជនត្រូវឆ្លងកាត់ការប្រឡងទៅតាមវិញ្ញាសារដែលសាលាភូមិន្ទសារការីជាអ្នករៀបចំ ដោយវិញ្ញាសារប្រឡងប្រជែង

[24] រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ,សាលាភូមិន្ទសារការី, http://rajp.gov.kh/Notary.html (កាលបរិច្ឆេទចូលទស្សនា៖ ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦)។

នោះចែកចេញជា២ដំណាក់កាលគឺ ដំណាក់កាលទី១ជា**វិញ្ញាសារសរសេរ (ឬវិញ្ញាសារបង្ខំ)** និង ដំណាក់កាលទី២ជា**វិញ្ញាសារផ្ទាល់មាត់ (ឬវិញ្ញាសារជ្រើសរើស)**។ មូលហេតុដែលគេកំណត់ថា វិញ្ញាសារសរសេរគឺជាវិញ្ញាសារបង្ខំ ក៏ដោយសារតែក្នុងវិញ្ញាសារនេះកំណតឲ្យបេក្ខជនត្រូវតែទទួល ការប្រឡងប្រជែង លើវិញ្ញាសារដែលសាលាភូមិន្ទសារការីដាក់មក ចំណែកឯវិញ្ញាសារផ្ទាល់មាត់ វិញ គឺអាចអនុញ្ញាតឲ្យបេក្ខជនជ្រើសរើសយកវិញ្ញាសារលើមុខវិជ្ជាណាមួយ ដែលខ្លួនគិតថាមាន ចំណេះដឹងច្បាស់លាស់ សម្រាប់ឆ្លើយទៅនឹងសំណួររបស់គណៈមេប្រយោគ។ ប៉ុន្តែក្នុងករណី ចាំបាច់ គណៈមេប្រយោគអាចសួរសំណួរបន្ថែមទៅបេក្ខជនលើមុខវិជ្ជាផ្សេងទៀតដែលនៅសល់។

- ខាងក្រោមនេះគឺជាមុខវិជ្ជាទាំង៤ដែលមានកំណត់ក្នុងវិញ្ញាសារសរសេរ(វិញ្ញាសារបង្ខំ)

| ល.រ | មុខវិជ្ជា | រយៈពេល | មេគុណ | ពិន្ទុចម្រុះ |
|---|---|---|---|---|
| ១ | នីតិកាតព្វកិច្ច និងកិច្ចសន្យា | ៣ម៉ោង | ២ | តិចជាង៦/២០ |
| ២ | នីតិអចលនទ្រព្យ | | | |
| ៣ | នីតិជំនួញ | | | |
| ៤ | ភាសាបារាំង | ១ម៉ោង | | |

គួរកត់សម្គាល់ផងដែរថា ប្រសិនបើបេក្ខជនទទួលបានពិន្ទុតិចជាង(៦/២០)នៃមុខវិជ្ជាណាមួយ ក្នុងចំណោមមុខវិជ្ជាទាំង៤ខាងលើ គឺត្រូវកំណត់ឲ្យធ្លាក់។

- ខាងក្រោមនេះគឺជាមុខវិជ្ជាទាំង៤ដែលមានកំណត់ក្នុងវិញ្ញាសារផ្ទាល់មាត់ (វិញ្ញាសាជ្រើសរើស)

| ល.រ | សម្ភាសន៍អំពីចំណេះដឹងទូទៅផ្នែកច្បាប់ | រយៈពេល | មេគុណ |
|---|---|---|---|
| ១ | នីតិគ្រួសារ | ៤០នាទី | ២ |
| ២ | នីតិពាណិជ្ជកម្ម | | |
| ៣ | នីតិអចលនទ្រព្យ | | |
| ៤ | នីតិរដ្ឋបាល | | |

បន្ទាប់ពីបានទទួលបានលទ្ធផលប្រឡងជាប់ហើយនោះ សិស្សសារការីនឹងត្រូវបានទទួល ការតែងតាំងដោយប្រកាសរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាសិស្សសារការី[25]។

[25]ប្រការ ១ នៃប្រកាសលេខ ១៧ ប្រកចុះថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០១៣ ស្តីពីការតែងតាំងសិស្សសារការី ជំនាន់ទី ១ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

### ២.១.១.២.វគ្គបណ្តុះបណ្តាល

សិស្សសារការី ត្រូវទទួលការបណ្តុះបណ្តាលរយៈពេល២ឆ្នាំ និង៦ខែ ដែលដំណាក់កាលនៃការបណ្តុះបណ្តាលនេះមានពីរដំណាក់កាល ហើយមានចំនួនម៉ោងសរុប១ត្រីមាសស្មើ២៧០ម៉ោង៖

- ដំណាក់កាលបណ្តុះបណ្តាលបឋម (១ ឆ្នាំស្មើនឹង ៤ ត្រីមាស) (២.១.១.២.១)
- ដំណាក់កាលបណ្តុះបណ្តាលកម្មសិក្សា និងការជួបជុំប្តូរបទពិសោធន៍នានា (២.១.១.២.២)។

#### ២.១.១.២.១.វគ្គបណ្តុបណ្តាលបឋម

**ក. ត្រីមាសសិក្សាអំពីនីតិទូទៅ**

- នីតិកាតព្វកិច្ច និងកិច្ចសន្យាពិសេស ៦០ ម៉ោង
- ស្ថាប័នតុលាការ និងស្ថាប័នរដ្ឋបាល ៤០ ម៉ោង
- សញ្ញាណនានាស្តីពីបច្ចេកទេសអនុវត្តក្នុងវិជ្ជាជីវៈសារការី ៥៥ ម៉ោង
  (សិក្សាអំពីលិខិតរបស់សារការី ក្រមសីលធម៌ ការទទួលខុសត្រូវរបស់សារការី)
- នីតិវិធីអនុវត្តសេចក្តីសម្រេច ៥០ ម៉ោង
- ភាសាបារាំង ១៥ ម៉ោង
- សិក្ខាសាលា

**ខ. ត្រីមាសសិក្សាអំពីនីតិគ្រួសារ**

- នីតិបាតិបុគ្គល និងអសមត្ថជន ៤០ ម៉ោង
- នីតិរបបមាតិកភ័ណ្ឌ ៥០ ម៉ោង
- នីតិសន្តតិកម្ម និងសទ្ធាទាន ៦០ ម៉ោង
- នីតិគ្រួសារ ៧០ ម៉ោង
  (សិក្សាអំពីទិដ្ឋភាពជម្រៈបញ្ជីមាតិកភ័ណ្ឌ និងមរតក)
- ភាសាបារាំង

**គ. ត្រីមាសសិក្សាអំពីនីតិអចលនៈទ្រព្យ**

- នីតិអចលនៈទ្រព្យ និងកម្មសិទ្ធិលើអចលនៈទ្រព្យ ៧០ ម៉ោង
- នីតិឥណទានអចលនៈវត្ថុ ៤០ ម៉ោង
- នីតិប្រាតិភោគ ៦០ ម៉ោង
- នីតិសាងសង់ និងនគរូបណីយកម្ម ៥០ ម៉ោង

- ភាសាបារាំង

### ឃ. ត្រីមាសសិក្សាអំពីនីតិជំនួញ

- នីតិពាណិជ្ជកម្ម ៦០ ម៉ោង

(សិក្សាអំពីមូលនិធិពាណិជ្ជកម្ម និង ប្រតិបត្តិការពាក់ព័ន្ធនឹងភតិសន្យាពាណិជ្ជកម្ម)

- នីតិក្រុមហ៊ុន ៥៥ ម៉ោង
- នីតិព្រហ្មទណ្ឌនៃជំនួញ ៤០ ម៉ោង
- ទម្រង់បែបបទ និងពន្ធដារសារការី ៥០ ម៉ោង
- ភាសាបារាំង ៥០ ម៉ោង
- សិក្ខាសាលា ១៥ ម៉ោង

## ២.១.១.២.២.កម្មសិក្សា និងការជួបជុំផ្លាស់ប្តូរបទពិសោធន៍

ដើម្បីអាចឲ្យសិស្សសារការីយល់ដឹងអំពីការអនុវត្តជាក់ស្តែងទាក់ទិននឹងមុខងាររបស់ខ្លួន សាលាភូមិន្ទវិជ្ជាជីវៈសារការីបានតម្រូវឲ្យសិស្សសារការីចុះកម្មសិក្សា ដើម្បីស្វែងយល់អំពីការងារជាក់ស្តែងក្នុងស្ថាប័នមួយចំនួនដែលទាក់ទងនឹងមុខវិជ្ជារបស់ខ្លួនដែលបានសិក្សារួចហើយ ព្រមទាំងមានបន្ថែមការបណ្តុះបណ្តាលលើមុខវិជ្ជាផ្សេងៗមួយចំនួនទៀតផងដែរ(ក) ហើយបន្ទាប់ពីបញ្ចប់កម្មសិក្សា សិស្សសារការីទាំងអស់ត្រូវជួបជុំផ្លាស់ប្តូរបទពិសោធន៍គ្នា(ខ)។

### ក. កម្មសិក្សា និងការបណ្តុះបណ្តាលឆ្លាស់

វគ្គបណ្តុះបណ្តាលនេះត្រូវបានបែងចែកជាពីរ គឺកម្មសិក្សារយៈពេល ៦ខែ នៅតាមបណ្តាមន្ទីសារការីនៅប្រទេសបារាំង[26] និងការបណ្តុះបណ្តាលឆ្លាស់រយៈពេល ៩ ខែនៅប្រទេសកម្ពុជា។

---

[26] ចំពោះសិស្សសារការីជំនាន់ទី១គឺតម្រូវឲ្យចុះកម្មសិក្សារយៈពេល៦ខែនៅតាមបណ្តាមន្ទីរសារការីក្នុងប្រទេសបារាំងដោយមូលហេតុពួកគេនឹងអាចក្លាយទៅជាគ្រូបង្គោលសម្រាប់សិស្សសារការីជំនាន់ក្រោយៗទៀត ដូចនេះសិស្សសារការីជំនាន់ក្រោយៗមិនប្រាកដថានឹងត្រូវចុះកម្មសិក្សានៅប្រទេសបារាំងនោះទេ។ ម្យ៉ាងវិញទៀតបើយោងតាមលោក Jean Dealge អ្នកតំណាងក្រុមប្រឹក្សាសារការីរបស់ប្រទេសបារាំង ដើម្បីបណ្តុះបណ្តាលសាការីនៅអាស៊ីដែលមាន កម្ពុជា ឡាវ និងវៀតណាម បានលើកឡើងថា "ក្រុមប្រឹក្សាជាន់ខ្ពស់របស់បារាំងកំពុងរង់ចាំមើលលទ្ធផលនៃច្បាប់ស្តីពីលក្ខន្តិកៈសារការីរបស់ប្រទេសកម្ពុជា ដើម្បីសម្រេចថា នឹងបន្តឲ្យមានកម្មសិក្សាសាការី ជំនាន់ទីពីរ នៅប្រទេសបារាំង ដែរឬទេ។ សម្រាប់ភាគីបារាំង គឺចង់ឲ្យសារការីនៃប្រទេសកម្ពុជាប្រកបវិជ្ជាជីវៈដោយសេរី ឯករាជ្យ និងមិនស្ថិតក្រោមក្របខ័ណ្ឌរដ្ឋាភិបាល ដូចនេះកម្មសិក្សានឹងអាចមានជាថ្មី បើសិនជារដ្ឋាភិបាលកម្ពុជាអនុញ្ញាតឲ្យសាការីអាចប្រកបវិជ្ជាជីវៈ សេរី ព្រោះថាក្រុមប្រឹក្សាសាការីមិនចង់ទេបណ្តុះបណ្តាលសាការីខ្មែរ ដែលនឹងធ្វើការជាមន្ត្រីរាជការនោះ។"

❖ **កម្មសិក្សា**

បន្ថែមពីលើការចុះកម្មសិក្សានៅប្រទេសបារាំង[27] សិស្សសារការីត្រូវចុះកម្មសិក្សាចំនួន ៨៦៤ ម៉ោង នៅតាមបណ្ដាស្ថាប័ននានា ដែលមានដូចជា រដ្ឋបាលសុរិយោដី រដ្ឋបាលពន្ធដា ជាដើម។

❖ **ការបណ្ដុះបណ្ដាលឆ្លាស់**

ចំពោះមុខវិជ្ជាក្នុងការបណ្ដុះបណ្ដាលឆ្លាស់គឺមានដូចជា៖

- ច្បាប់ភូមិបាល ៤៦ ម៉ោង
  (រដ្ឋបាលសុរិយោដី ជាដើម)
- នីតិសាងសង់ និងនីតិនគរូបនីយកម្ម ៤០ ម៉ោង
  (ឯកសារពាក់ព័ន្ធនឹងនគររូបនីយកម្ម លិខិតអនុញ្ញាតសាងសង់ ជាដើម)
- នីតិសារពើពន្ធ ៤០ ម៉ោង
  (សារពើពន្ធអចលនវត្ថុ ពន្ធប្រថាប់ត្រាក្នុងការចុះបញ្ជី ជាដើម)
- ឯកសាររដ្ឋបាល ៤០ ម៉ោង
- ភាសាបារាំង

## ខ. ការជួបជុំឆ្លាស់ប្តូរបទពិសោធន៍

- នៅពេលចាប់ផ្ដើមវគ្គបណ្ដុះបណ្ដាលការណែនាំឲ្យស្វែងយល់ពីច្បាប់ថ្មីៗ
- នៅពេលត្រឡប់ពីកម្មសិក្សានៅប្រទេសបារាំង៖ វិភាគសិក្សាអំពីការអនុវត្តជាក់ស្ដែងខាងផ្នែកសារការីដោយភ្ជាប់ទៅនឹងកាលបរិច្ឆេទក្នុងស្រុក ។

ក្រោយពីបានបញ្ចប់ការបណ្ដុះបណ្ដាលខាងលើបានយ៉ាងជោគជ័យហើយ សារការីទាំងនោះត្រូវទទួលការប្រឡងបញ្ចប់មួយទៀត រួមជាមួយនឹងការតាក់តែងរបាយការណ៍កម្មសិក្សា រួចដាក់ទៅសាលាភូមិន្ទវិជ្ជាជីវៈសារការី។ បន្ទាប់ពីបានបំពេញទាំងស្រុងនូវលក្ខខណ្ឌនានាដែលបានតម្រូវដោយសាលា សិស្សសារការីនោះនឹងត្រូវបានតែងតាំងដោយប្រកាសរបស់ក្រសួងយុត្តិធម៌ ដើម្បីទទួលបានមុខងារជាសារការី។ ហើយសារការីនោះអាចអនុវត្តមុខងាររបស់ខ្លួនបានបន្ទាប់ពីទទួលបានការតែងតាំង[28]។

[27] ឈាង បុប្ផា, "សារការីខ្មែរជំនាន់ទីមួយបញ្ចប់កម្មសិក្សានៅប្រទេសបារាំង", http://km.rfi.fr/cambodia/notaires-khmers-form%C3%A9s-en-france-20150226 (កាលបរិច្ឆេទចូលទស្សនា៖ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៦)។

[28] មាត្រា៦ នៃសេចក្ដីព្រាងច្បាប់ស្ដីពីសារការីឆ្នាំ២០០៧

ជាក់ស្តែងក្នុងពេលថ្មីៗនេះ សិស្សសារការីជំនាន់ទី១ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវបានទីស្តីការគណៈរដ្ឋមន្ត្រីតែងតាំងដោយប្រកាសលេខ ១៧ ប្រក ចុះថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០១៣ ដែលមានចំនួន ១៥ នាក់ ដូចមានរាយនាមខាងក្រោម[29] ៖

| ល.រ | គោត្តនាម និងនាម | អក្សរឡាតាំង | ភេទ | ថ្ងៃខែឆ្នាំកំណើត |
|---|---|---|---|---|
| ០១ | ប៊ួន សារៈមុនី | Buon Srakmony | ប្រុស | ១៤/០៦/១៩៨៦ |
| ០២ | ស៊ិន សុពុទ្ធិ | Sin Soputhi | ប្រុស | ១១/១២/១៩៨៥ |
| ០៣ | លី រ៉ានាថ | Ly Raneath | ស្រី | ៣១/១២/១៩៨៦ |
| ០៤ | សែន សេងថៃ | Sen Sengthai | ប្រុស | ០៨/០២/១៩៨៥ |
| ០៥ | អេង គីមសួគ៌ | Eng Kimsour | ស្រី | ០៣/០៧/១៩៨៦ |
| ០៦ | ផង់ វិចិត្រ | Phang Vichet | ប្រុស | ១៣/០១/១៩៨២ |
| ០៧ | កាំង ផេង | Kaing Pheng | ប្រុស | ០៧/០៨/១៩៨២ |
| ០៨ | កាន់ សុទ្ធប៉ូលីន | Kan Sothpolin | ប្រុស | ១៥/០៣/១៩៨៤ |
| ០៩ | យន់ សុវណ្ណារ៉ា | Yun Sovannara | ប្រុស | ២០/០៨/១៩៨៦ |
| ១០ | ជឹង ស្រីតូច | Ching Sreytouch | ស្រី | ១៤/០៤/១៩៨៨ |
| ១១ | ចាំង ស្រីពៅ | Chaing Sreypeou | ស្រី | ១៧/១១/១៩៨៥ |
| ១២ | ប៉ាន់ វាសនា | Pann Veasna | ប្រុស | ០៧/០៧/១៩៨៣ |
| ១៣ | សៀង ធារី | Sieng Theary | ស្រី | ២១/០៤/១៩៨៦ |
| ១៤ | ហ៊ី ថុនា | Hy Thona | ប្រុស | ០៧/០៦/១៩៨៨ |
| ១៥ | សៅ នឿន | Sao Noeun | ប្រុស | ០៩/០៥/១៩៨០ |

### ២.១.២. ការតែងតាំងជាសារការី

ក្រៅពីការទទួលបានមុខងារជាសារការីតាមរយៈការបណ្តុះបណ្តាល មន្ត្រីមួយចំនួនក៏អាចទទួលបានទទួលមុខងារជាសារការីផងដែរ គឺតាមរយៈការតែងតាំងដោយប្រកាសរបស់ក្រសួងយុត្តិធម៌(២.១.២. ១) និងការតែងតាំងដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល(២.១.២.២)។

#### ២.១.២.១. ការតែងតាំងដោយប្រកាសក្រសួងយុត្តិធម៌

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានចេញប្រកាសលេខ ៤៧ កយ. ប្រក/១២ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០១២ ដើម្បីតែងតាំងមន្ត្រីជាច្រើនទៀត ដើម្បីទទួលបន្ទុកអនុវត្តជាបណ្តោះអាសន្ននូវកិច្ចការសារ

[29]ប្រការ ១ ប្រកាសស្តីពី ការតែងតាំងសិស្សសារការី ជំនាន់ទី ១ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

ការីរហូតដល់មានសារការីដែលមានវិជ្ជាជីវៈចេញមកពីការបណ្តុះបណ្តាល ឬ មានបទប្បញ្ញត្តិផ្ទុយពីប្រកាសនេះទើបមន្ត្រីទទួលបន្ទុកនោះត្រូវចប់ភារកិច្ចរបស់ខ្លួន។ ការតែងតាំងនេះត្រូវបានធ្វើឡើងដោយយោងតាមមាត្រា១០នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ដែលតម្រូវឲ្យមានសារការីដើម្បីអនុវត្តមុខងារដូចមានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

មាត្រា១០. ការកំណត់មន្ត្រីទទួលបន្ទុកកិច្ចការសារការី

១.រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវកំណត់មន្ត្រីទទួលបន្ទុកកិច្ចការសារការី ដែលត្រូវទទួលបន្ទុកកិច្ចការសារការីជាបណ្តោះអាសន្នតាមតម្រូវការចាំបាច់ នៅក្នុងអំឡុងពេលរហូតដល់មានការកំណត់ផ្សេងនៅក្នុងច្បាប់មិនលើសពី២(ពីរ)នាក់ នៅក្នុងដែនសមត្ថកិច្ចនៃសាលាដំបូងក្នុងចំណោមចៅក្រម ព្រះរាជអាជ្ញា ឬ ឥស្សរជនជាមន្ត្រីសាធារណៈ ដែលមានបទពិសោធន៍ការងារក្នុងវិស័យច្បាប់ និង មានសញ្ញាបត្រនីតិសាស្ត្រចាប់ពីបរិញ្ញាបត្រឡើងទៅ។

២.ចៅក្រមដែលត្រូវបានកំណត់ថាជាមន្ត្រីទទួលបន្ទុកកិច្ចការសារការី ត្រូវបានចាត់ទុកថា មានហេតុនៃការដកហូតសមត្ថកិច្ចដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា២៧ (ការដកហូតចៅក្រមពីសមត្ថកិច្ចជំនុំជម្រះ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះរឿងក្តីដែលចាត់ចែងកិច្ចការសារការី។

៣.ចំពោះសារការី និងមន្ទីរសារការីដែលបានតែងតាំង និងបង្កើតឡើងមុនបច្បាប់នេះ ត្រូវបន្តមានសមត្ថកិច្ចបំពេញកិច្ចការសារការីស្របតាមក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់ជាធរមាន។

ឈ្មោះរបស់មន្ត្រីទទួលបន្ទុកសារការីដែលបានកំណត់ដោយប្រកាសនេះត្រូវបានកំណត់ក្នុងប្រការ១ [30] ៖

ប្រកាសនេះបានកំណត់ជាមន្ត្រីទទួលបន្ទុកកិច្ចការសារការីនៅតាមដែនសមត្ថកិច្ចនៃសាលាដំបូងនៃសាមីខ្លួនៈ

ក. រាជធានីភ្នំពេញ

១. ឯកឧត្តម ផូវ សំភី

២. ឯកឧត្តម ហួត ហាក់

ខ. ខេត្តកណ្តាល

១. ឯកឧត្តម កើត រិទ្ធ

២. ឯកឧត្តម វង្ស ប៊ុនវិសុទ្ធ

គ. ខេត្តកំពង់ចាម

[30] ប្រការ ១ នៃប្រកាសរបស់ក្រសួងយុត្តិធម៌លេខ ៤៧ កយ.ប្រក/១២ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០១២ ។

១. លោក ផាន់ សុភក្ត្រ័

២. លោក សម ប៊ុនថុន

ឃ. ខេត្តព្រៃវែង

១. លោក កើត វណ្ណារ៉េត

២. លោក គី ម៉ានេវ៉ា

ង. ខេត្តសៀមរាប

១. លោក អ៊ិត សុធា

២. លោក ស្រ៊ា រតនៈ

ច. ខេត្តបន្ទាយមានជ័យ

១. លោក ផាន់ វណ្ណរ័ត្ន

២. លោក ផាន់ ភីរម្យ

ឆ. ខេត្តបាត់ដំបង

១. លោក សាអឿន កោសល្យមុន្នី

២. លោក ហ៊ឹង ប៊ុនថន

ជ. ខេត្តពោធិ៍សាត់

១. លោក កុល កំពូល

២. លោក ប៉ង់ ចាន់សុយុទ្ធារា

មន្ត្រីទទួលបន្ទុកកិច្ចការសារការី ដែលបានរាយនាមខាងលើត្រូវអនុវត្តកិច្ចការនានានៅក្នុងដែនសមត្ថកិច្ចសាលាដំបូងនៃខេត្តនីមួយៗ ដែលខ្លួនទទួលបន្ទុក និងស្ថិតនៅក្នុងកំឡុងពេលរហូតដល់កាលបរិច្ឆេទនៃការអនុវត្តច្បាប់ស្តីពីលក្ខន្តិកៈនៃសារការី ឬ បទប្បញ្ញត្តិផ្សេងដែលចែងនិរាករណ៍ប្រកាសនេះ ។

មន្ត្រីទទួលបន្ទុកកិច្ចការសារការី[31] ត្រូវធ្វើការរបស់សារការីដែលមានកំណត់ ក្នុងក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី និងធ្វើការចាត់ចែងផ្សេងទៀតដូចដែលមានកំណត់ក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌។

ក្រោយពីបានអនុវត្តមួយរយៈរួចមក ប្រកាសលេខ ៤៧ កយ. ប្រក/១២ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០១២ ក៏បានត្រូវនិរាករណ៍ ដោយប្រកាសរបស់ក្រសួងយុត្តិធម៌លេខ ៣២ កយ.ប្រក/ ចុះថ្ងៃទី

[31] ប្រការ ២ នៃប្រកាសរបស់ក្រសួងយុត្តិធម៌លេខ ៤៧ កយ.ប្រក/១២ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០១២ ។

២៣ ខែឧសភា ឆ្នាំ២០១២ ដែលបានចែងថា ប្រកាសលេខ ៤៧ កយ. ប្រក/ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០១២ របស់ក្រសួងយុត្តិធម៌ត្រូវទុកជានិរាករណ៍[32]។ ហើយការតែងតាំងមន្ត្រីទទួលបន្ទុកសារការី ត្រូវបានបន្ថែមច្រើនជាងមុន ដូចដែលមានចែងក្នុងប្រការ១[33]៖

មន្ត្រីទទួលបន្ទុកសារការីនៅតាមដែនសមត្ថកិច្ចនៃសាលាដំបូងនៃសាមីខ្លួនដែលមានរាយនាមដូចខាងក្រោម៖

ក. រាជធានីភ្នំពេញ

១. ឯកឧត្តម ផូវ សំភី

២. ឯកឧត្តម ហួត ហាក់

ខ. ខេត្តកណ្ដាល

១. ឯកឧត្តម កើត រិទ្ធ

២. ឯកឧត្តម វង្ស ប៊ុនវិសុទ្ធ

គ. ខេត្តកំពង់ឆ្នាំង

១. ឯកឧត្តម ហ៊ែល ចំរើន

២. លោក កុល កំពូល

ឃ. ខេត្តកំពង់ស្ពឺ

១. ឯកឧត្តម ស៊ូ សុជាតិ

២. លោក ងួន ណារ៉ា

ង. ខេត្តកំពត

១. ឯឧត្តម កាន ច័ន្ទមេត្តា

២. លោក អ៊ុំវ ត្រាយ

ច. ខេត្តព្រះសីហនុ

១. ឯកឧត្តម ឡាំ ជា

២. លោក វៀម ច័ន្ទម៉ី

ឆ. ខេត្តកោះកុង

១. លោក តុប ឈុនហេង

២. លោក ហុង សុគុណវឌ្ឍនា

[32]ប្រការ ៣ នៃប្រកាសរបស់ក្រសួងយុត្តិធម៌លេខ ៣២ កយ.ប្រក/១២ ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០១២។

[33]ប្រការ ១ នៃប្រកាសរបស់ក្រសួងយុត្តិធម៌លេខ ៣២ កយ.ប្រក/១២ ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០១២។

ជ. ខេត្តតាកែវ

១. លោក មាស សុភក្តិ

២. ឯកឧត្តម អ៊ឹង លេរិវិសុទ្ធ

ឈ. ខេត្តស្វាយរៀង

១. ឯកឧត្តម គឹម សន្តិភាព

២. លោក យក់ ប៊ុនណា

ញ. ខេត្តព្រៃវែង

១. លោក សាយ ណូរ៉ា

២. លោក សម ប៊ុនថុន

ត. ខេត្តកំពុងចាម

១. លោក ផាន់ សុភ័ក្រ្ត

២. លោក ប៊ុន យ៉ៃណារិន

ថ. ខេត្តកំពង់ធំ

១. លោក អ៊ិត សុអា

២. លោក សារឿន កោសល្យមុនី

ទ. ខេត្តក្រចេះ

១. លោកស្រី ចាត សុរស្មី

២. ឯកឧត្តម សំ រិទ្ធី

ធ. ខេត្តពោធិ៍សាត់

១. លោក ប៉ង់ ចាន់សុយុទ្ធារា

២. លោក សៀង ធីរិទ្ធ

ន. ខេត្តបាត់ដំបង

១. លោក ហ៊ីងប៊ុនថន

២. លោក ផាន់ ភីរម្យ

ដ. ខេត្តប៉ៃលិន

១. លោក ជុំ សែនសទ្ធា

២. លោក អ៊ី សារិញ

ឋ. ខេត្តបន្ទាយមានជ័យ

១. លោក ផាន់ វណ្ណារ័ត្ន

២. លោក គី ម៉ានេវ៉ា

ឌ. ខេត្តសៀមរាប

១. លោក កើត វណ្ណារ៉េត

២. លោក ស្រ៊ា រតនៈ

ឍ. ខេត្តឧត្តមានជ័យ

១. លោក កួយ កាន់យ៉ា

២. ឯកឧត្តម បួន សុមុនី

ណ. ខេត្តព្រះវិហារ

១. លោក ជុំ ស

២. ឯកឧត្តម កៅ ថាច

ប. ខេត្តរតនៈគិរី

១. លោក លាវ ស្រេង

មន្ត្រីទទួលបន្ទុកសារការីទាំងអស់ខាងលើ ត្រូវបានតែងតាំងឲ្យអនុវត្តកិច្ចការសារការីក្នុងអំឡុងពេលនេះរហូតដល់កាលបរិច្ឆេទនៃការអនុវត្តច្បាប់ស្តីពីលក្ខន្តិកៈនៃសារការី។

មន្ត្រីទទួលបន្ទុកសារការី ត្រូវធ្វើកិច្ចការសារការី ដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណីច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី និងធ្វើការចាត់ចែងផ្សេងទៀត ដែលមានកំណត់ក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌[34]។មូលហេតុដែលបង្កើតប្រកាសនេះឡើង គឺដើម្បីនិរាករណ៍ប្រកាសលេខ ៤៧ កយ. ប្រក/១២ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០១២ ដោយសារតែតម្រូវការជាចាំបាច់នូវមុខងារសារការីបន្ថែមក្នុងការបំពេញមុខងារនាពេលបច្ចុប្បន្ន។

ចំណែកឯសមត្ថកិច្ចរបស់មន្ត្រីទទួលបន្ទុកកិច្ចការសារការីវិញគឺមានបញ្ញត្តិក្នុងមាត្រា១១នៃច្បាប់ស្តីពីការអនុវត្តក្រមដែលមានខ្លឹមសារដូចខាងក្រោម៖

មាត្រា១១.សិទ្ធិអំណាចរបស់មន្ត្រីទទួលបន្ទុកសារការី ជាអាទិ៍

១.មន្ត្រីទទួលបន្ទុកកិច្ចការសារការី ត្រូវធ្វើកិច្ចការរបស់សារការី ដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី និងច្បាប់នេះ ដូចជាការផ្តល់សេចក្តីបញ្ជាក់លើលក្ខន្តិកៈ ការធ្វើលិខិតយថាភូត ជាអាទិ៍ ជាបណ្តោះអាសន្ន។

[34]ប្រកា ២ នៃប្រកាសរបស់ក្រសួងយុត្តិធម៌លេខ ៣២ កយ.ប្រក/១២ ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០១២។

២.ដើម្បីធ្វើលិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៩ (អត្ថន័យនៃលិខិតយថាភូត) នៃច្បាប់នេះ មន្ត្រីទទួលបន្ទុកសារការីត្រូវត្រួតពិនិត្យ និងបញ្ជាក់អត្តសញ្ញាណរបស់ភាគីដោយសាក្សី ឬ សំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើត ហើយក្រៅពីនេះត្រូវធ្វើការចាត់ចែងដែលកំណត់ក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌។

៣.បុគ្គលដែលប្រើប្រាស់សេវារបស់មន្ត្រីទទួលបន្ទុកកិច្ចការសារការីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបង់ពន្ធ។ ចំណូលពន្ធនេះត្រូវបង្វែរចូលទៅថវិការដ្ឋ។

៤.ការបង្កើតលិខិតយថាភូតដែលបានធ្វើឡើងដោយមន្ត្រីទទួលបន្ទុកកិច្ចការសារការី ការប្រគល់ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ដែលមានអានុភាពដូចគ្នានឹងច្បាប់ដើមនៃលិខិតយថាភូត និងចំណុចចាំបាច់ផ្សេងទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

៥.ប្រាក់ពន្ធ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

មាត្រា១១ខាងលើនេះ គ្រាន់តែចង់បញ្ជាក់ឲ្យច្បាស់លាស់អំពីសមត្ថកិច្ចដែលមន្ត្រីទទួលបន្ទុកសារការីត្រូវបំពេញក្នុងអំឡុងពេលនៃការអនុវត្តមុខងាររបស់ខ្លួន។ ប៉ុន្តែចំណុចដែលយើងគួរចោទជាសំណួរនោះគឺថា ក្នុងករណីដែលមន្ត្រីទទួលបន្ទុកកិច្ចការសារការីណាម្នាក់ត្រូវបានផ្លាស់ប្តូរទីតាំងបម្រើការងារ ពីទីតាំងដែលបានកំណត់ក្នុងប្រកាសទៅទីតាំងផ្សេងមួយទៀត ថាតើក្រសួងយុត្តិធម៌ត្រូវចេញប្រកាសដើម្បីផ្លាស់ប្តូរតាមទីតាំងដែលគាត់បម្រើការងារដែរឬទេ?។

**<u>ឧទាហរណ៍៖</u>** លោក **ក** មានមុខងារជាចៅក្រមសាលាដំបូងខេត្តកោះកុង ក្នុងអាណត្តិជាចៅក្រមក្នុងខេត្តនោះ ក្រសួងយុត្តិធម៌បានចេញប្រកាសមួយដើម្បីតែងតាំងលោកជាមន្ត្រីទទួលបន្ទុកកិច្ចការសារការី ចុះបើសិនជាគាត់ត្រូវបានផ្លាស់ប្តូរពីសាលាដំបូងខេត្តកោះកុង មកសាលាដំបូងរាជធានីភ្នំពេញ តើត្រូវមានប្រកាសមួយទៀតដើម្បីនិរាករណ៍ប្រកាសទីមួយដែលបានចេញឬយ៉ាងណា? ឬគាត់នៅតែមានសមត្ថកិច្ចអនុវត្តមុខងារជាមន្ត្រីទទួលបន្ទុកសារការីក្នុងខេត្តកោះកុងដដែល?។ដោយសារតែនៅក្នុងប្រកាសមិនមានបញ្ញត្តិអំពីបញ្ហានេះ ដូចនេះសំណួរដែលបានលើកឡើងខាងលើនៅតែមានភាពមិនច្បាស់លាស់ ព្រោះមិនអាចរកចម្លើយដ៏សមស្របណាមួយ។

## ២.១.២.២. ការទទួលបានមុខងារសារការីដោយអនុក្រឹត្យ

ដោយមានតម្រូវការចាំបាច់នូវមុខងារសារការី ក្នុងប្រតិបត្តិការនានាលើវិស័យអចលនវត្ថុ ក៏ដូចជាវិស័យដែលពាក់ព័ន្ធដែលតម្រូវឲ្យមាន ការចុះបញ្ជី ដើម្បីឲ្យការផ្ទេរកម្មសិទ្ធិ នោះមានសុពលភាព ហើយដោយសព្វថ្ងៃនេះ ពុំទាន់មានសារការីគ្រប់គ្រាន់នៅក្នុងប្រតិបត្តិការនោះផង រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យ ៥០៥ អនក្រ/តតចុះថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ ២០០១ តែងតាំង លោក **បៃនសុន សម័យ** ដែល

ជាសមាជិកមេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានូវមុខងារបន្ថែមជាមេធាវីសារការី។ មេធាវីសារការីជាមន្ត្រីសាធារណៈ មានសមត្ថកិច្ចការងារទូទៅក្នុងវិស័យផ្នែកគ្រួសារ ចលនវត្ថុ និងអចលនវត្ថុ មានជាអាទ៍៖

ក. ទទួល និងធ្វើ ឬ ចារឹកបញ្ជាក់ និង ប្រថាប់ត្រា នូវលិខិតស្នាមគតិយុត្តិ ឬ កិច្ចសន្យាទាំងឡាយ ដើម្បីជាបន្ទាល់ពេញលក្ខណៈតាមផ្លូវច្បាប់ ដែលតែងតែមានលិខិតរបស់រាជការអំណាចសាធារណៈ។

ខ. ធ្វើការបញ្ជាក់លើការិយបរិច្ឆេទ ទទួលតំកល់ទុកឯកសារ និងចេញឲ្យនូវសេចក្តីដើម ឬ សេចក្តីចម្លងលិខិត ឬ កិច្ចសន្យាទាំងឡាយនោះតាមមុខការ ។

គ. កិច្ចការនេះត្រូវពិនិត្យ អានឲ្យសេចក្តី និងចុះហត្ថលេខានៃគូភាគីនៅចំពោះមុខទើបមេធាវីសារការី ចុះហត្ថលេខាប្រថាប់ត្រាចារឹកនាពេលនោះជាចុងក្រោយ[35]។

មួយវិញទៀត តម្រូវឲ្យតម្កល់ប្រាក់ធានាសំណងមួយចំនួនធំ នៅធនាគារជាតិនៃកម្ពុជា ។

ដោយមិនអាចបំពេញតម្រូវការបានគ្រប់គ្រាន់ ដោយសារការីនៅតែមានចំនួនមួយតិចនៅឡើយ ទោះបីជាមានការតែងតាំងខាងលើនេះ រដ្ឋាភិបាលក៏បានចេញអនុក្រឹត្យមួយទៀតលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០០៨ ទទួលស្គាល់មន្ទីសារការី **អេច ប៊ី អេស** នៃព្រះរាជាណាចក្រកម្ពុជា[36] ដោយអនុក្រឹត្យនេះ បានតែងតាំងសារការីចំនួនពីររូបទៀត។

មន្ទីរសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជាមានតួនាទី និងភារកិច្ចដូចតទៅ៖

- ទទួលធ្វើរាល់លិខិតស្នាមគតិយុត្ត ឬ កិច្ចសន្យាទាំងឡាយ ដែលរូបវន្តបុគ្គល ឬ នីតិបុគ្គលនៃនីតិឯកជន ឬ និតិបុគ្គលនៃនីតិសាធារណៈមានកាតព្វកិច្ចផ្តល់យថាភូតភាពតាមច្បាប់កំណត់ ឬ មានបំណងផ្តល់យថាភូតភាពដោយខ្លួនឯង
- ទទួលបញ្ជាក់រាល់លិខិតស្នាមគតិយុត្ត ឬ កិច្ចសន្យាទាំងឡាយ ដែលរូបវន្តបុគ្គល ឬ នីតិបុគ្គលនៃនីតិឯកជន ឬ នីតិបុគ្គលនៃនីតិសាធារណៈ មានកាតព្វកិច្ចតាមច្បាប់កំណត់ ឬ ឆន្ទៈខ្លួនឯង
- បញ្ជាក់ធានាហត្ថលេខា និងកាលបរិច្ឆេទ នៃលិខិតស្នាមគតិយុត្ត ឬកិច្ចសន្យា
- ផ្តល់យថាភូតភាពលើឯកសារបកប្រែពីភាសាបរទេសមកភាសាខ្មែរ និង ពីភាសាខ្មែរទៅភាសាបរទេស

[35]មាត្រា ២ នៃអនុក្រឹត្យលេខ ៥០៥ អនក្រ.តត. ស្តីពីការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។

[36]មាត្រា ១ នៃអនុក្រឹត្យលេខ ១៥៥ អនក្រ.បកស្តីពីការទទួលស្គាល់មន្ទីសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា

- ធ្វើការចុះបញ្ជី និងលេខចារឹកទៅស្ថាប័នមានសមត្ថកិច្ច
- ធ្វើការរក្សាទុកច្បាប់ដើមនៃលិខិតស្នាមគតិយុត្ត និង កិច្ចសន្យា
- ធ្វើការរក្សាទុកច្បាប់ដើមនៃមតកសាសន៍
- ចេញច្បាប់ចម្លងនៃលិខិតយថាភូត និង
- ទទួលធ្វើ និងបញ្ជាក់រាល់លិខិតស្នាមគតិយុត្តផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់[37]។

មន្ទីរសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជាមានទីតាំងដើមស្ថិតនៅអាគារពាណិជ្ជកម្មសូម៉ា ផ្លូវលេខ ១២០ សង្កាត់ ផ្សារថ្មីទី ១ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ[38] មន្ទីសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា ត្រូវគ្រប់គ្រងដោយសារការី លី តៃសេង ជាប្រធាន និង សារការី តាន់ហ៊ាន ជាវ័ណ្ណ[39]។

នៅក្នុងឆ្នាំ ២០១៦ ថ្មីៗនេះ រដ្ឋាភិបាលបានប្រកាសតែងតាំងមន្ទីសារការីមួយចំនួនទៀត ដើម្បីបំពេញតម្រូវការបន្ថែមលើភាពខ្វះខាតដែល រួមមានដូចជាៈ

អនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០១៦ ទទួលសស្គាល់មន្ទីសារការី **អេស ខេ វ៉ាយ** នៃព្រះរាជាណាចក្រកម្ពុជា[40] ត្រូវបានតែងតាំងជាសារការីនូវបុគ្គលដែលមានរាយនាមដូចខាងក្រោមៈ

១. លោកស្រី **អេង គីមសួគ៌** ដើម្បីបំពេញមុខងារជាប្រធាននៃមន្ទីរសារការី អេស ខេ វ៉ាយ

២. លោក **សែន សេងថៃ** ដើម្បីបំពេញមុខងារជាអនុប្រធាននៃមន្ទីរសារការី អេស ខេ វ៉ាយ

៣. លោក **អ៊ី ម៉ាណោ** ដើម្បីបំពេញមុខងារជាសមាជិកនៃមន្ទីរសារការី អេស ខេ វ៉ាយ ។[41]

មន្ទីសារការី អេស ខេ វ៉ាយ នៃព្រះរាជាណាចក្រកម្ពុជា មានទីស្នាក់ការនៅផ្ទះលេខ ៣៧ អា ផ្លូវលេ ២៨៨ សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ[42]។

អនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី ០២ ខែកុម្ភៈឆ្នាំ ២០១៦ ស្តីពីការបង្កើតមន្ទីសារការី **លុច ស៊ីអេចឌី** នៃព្រះរាជាណាចក្រកម្ពុជា ។ អនុក្រឹត្យនេះ បានតែងតាំងលោក **ទូត លុច** ជាសារការី

[37]មាត្រា ៣ នៃអនុក្រឹត្យលេខ១៨៨អនក្រ.បកស្តីពីការទទួលស្គាល់មន្ទីរសារការី អេច ប៊ី អេសនៃព្រះរាជាណាចក្រកម្ពុជា។
[38]មាត្រា ២ នៃអនុក្រឹត្យលេខ ១៨៨អនក្រ.បក ស្តីពីការទទួលស្គាល់មន្ទីរសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា។
[39]មាត្រា ៤ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ស្តីពីការទទួលស្គាល់មន្ទីរសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា។
[40]មាត្រា ១ នៃអនុក្រឹត្យលេខ០៩ អនក្រ.បក ស្តីពីការបង្កើតមន្ទីរសារការី អេស ខេ វ៉ាយ នៃព្រះរាជាណាចក្រកម្ពុជា ។
[41]មាត្រា ២ នៃអនុក្រឹត្យលេខ០៩ អនក្រ.បក ស្តីពីការបង្កើតមន្ទីរសារការី អេស ខេ វ៉ាយ នៃព្រះរាជាណាចក្រកម្ពុជា ។
[42]មាត្រា ៣ នៃអនុក្រឹត្យលេខ០៩ អនក្រ.បក ស្តីពីការបង្កើតមន្ទីរសារការី អេស ខេ វ៉ាយ នៃព្រះរាជាណាចក្រកម្ពុជា ។

ដើម្បីដឹកនាំមន្ទីរសារការី លុច ស៊ីអេចឌី។[43] មន្ទីរសារការី លុច ស៊ីអេចឌី មានទីស្នាក់ការ ស្ថិតនៅអាគារលេខ១៣៥ សេដស ផ្លូវលេខ១៩៩សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ[44]។

អនុក្រឹត្យ លេខ ៤២ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០១៦ ស្តីពីការបង្កើតមន្ទីរសារការី អង្គរ នៃព្រះរាជាណាចក្រកម្ពុជា ដែលមានតួនាទី ចេញច្បាប់ចម្លងនៃលិខិតយថាភូត និង ទទួលធ្វើកិច្ចការផ្សេងៗទៀត ដែលអនុញ្ញាតដោយច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន[45]។

ទាំងអស់នេះជាការទទួលបានមុខងារជាសារការីដោយអនុក្រឹត្យតែងតាំង ពីសំណាក់រាជរដ្ឋាភិបាលដើម្បីទទួលបានមុខងារ ក៏ដូចជាបង្កើតមន្ទីរសារការីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សរុបមកដោយសារតែយើងពុំទាន់មានបទប្បញ្ញត្តិជាក់លាក់ ដើម្បីកំណត់អំពីការទទួលបានមុខងារជាសារការីដូច្នេះហើយបានជាយើងឃើញថា ការទទួលបានមុខងារជាសារការីមានលក្ខណៈមិនច្បាស់លាស់ ហើយបើយើងក្រឡេកទៅមើលសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈសារការីឆ្នាំ២០០៧វិញ គេបានកំណត់យ៉ាងច្បាស់លាស់នៅមាត្រា ៥ គឺដើម្បីទទួលបានមុខងារសារការី ឬ ចូលប្រកបវិជ្ជាជីវៈសារការីបានលុះត្រាតែ៖

- មានសញ្ជាតិជាខ្មែរ
- មានបរិញ្ញាបត្រច្បាប់
- បានបំពេញយ៉ាងពេញលេញរាល់ការទាមទារនូវការបណ្តុះបណ្តាល កម្មសិក្សា និងសញ្ញាបត្រដែលកំណត់ក្នុងច្បាប់នេះ
- មិនដែលជាកម្មវត្ថុនៃការផ្តន្ទាទោស ថ្នាក់មជ្ឈឹម ឬឧក្រិដ្ឋ និងមិនដែលត្រូវប្រកាសក្ស័យធនផ្ទាល់ខ្លួនដោយសេចក្តីសម្រេចរបស់តុលាការ។

ចំណែកមាត្រា ៦ នៃច្បាប់ដដែល បានចែងថា សារការីត្រូវបានតែងតាំង ដោយប្រកាសរបស់ក្រសួងយុត្តិធម៌ ក្រោយពីបានបញ្ចប់ការបណ្តុះបណ្តាលនៅសាលាភូមិន្ទសារការី និងកម្មសិក្សាដោយបង្ខំ បើសិនជាសារការីទាំងអស់នោះបានបំពេញយ៉ាងពេញលេញនូវរាល់ លក្ខខណ្ឌនៃការប្រលងចេញ របស់លសាលាភូមិន្ទសារការី។ សារការីអាចប្រកបមុខងាររបស់ខ្លួន ចាប់តាំងពីថ្ងៃដែលបានតែងតាំង ដោយប្រកាសរបស់ក្រសួងយុត្តិធម៌ ។

នេះគឺជាលក្ខខណ្ឌដែលបានចែងនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈសារការីឆ្នាំ២០០៧ ដែលបានចែងអំពីការទទួលបាននូវមុខងារសារការី។ ប៉ុន្តែដោយហេតុថាវានៅតែជាសេចក្តីព្រាងច្បាប់

[43]មាត្រា ១ នៃអនុក្រឹត្យលេខ ១៨ អនក្រ.បក ស្តីពីការបង្កើតមន្ទីរសារការី លុច ស៊ីអេចឌី នៃព្រះរាជាណាចក្រកម្ពុជា ។
[44]មាត្រា ២ នៃអនុក្រឹត្យលេខ ១៨ អនក្រ.បក ស្តីពីការបង្កើតមន្ទីរសារការី លុច ស៊ីអេចឌី នៃព្រះរាជាណាចក្រកម្ពុជា ។
[45]មាត្រា ១ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការបង្កើតមន្ទីរសារការី អង្គរ នៃព្រះរាជាណាចក្រកម្ពុជា ។

នៅឡើយ ដូចនេះយើងពុំអាចយកវាជាសំអាងក្នុងការបកស្រាយអំពីលក្ខខណ្ឌដើម្បីទទួលបានមុខងារជាសារការីនៅពេលបច្ចុប្បន្នបានទេ ។

ទាក់ទងនឹងលក្ខខណ្ឌដែលសារការីត្រូវបានតែងតាំងដោយអនុក្រឹត្យនេះផងដែរ គឺមានចំណុចដែលគួរឲ្យចោទជាបញ្ហាក្នុងករណីដែលសារការីណាម្នាក់មិនបានបំពេញមុខងារជាសារការីឲ្យបានពេញលេញ។

<u>**ឧទាហរណ៍**</u>៖ សារការី ក អវត្តមានដោយមិនបានបំពេញកិច្ចការទាក់ទងនឹងមុខងាររបស់ខ្លួននៅក្នុងមន្ទីរសារការីដោយមូលហេតុមិនសមរម្យណាមួយ ដែលធ្វើឲ្យប៉ះពាល់ដល់ដំណើរការក្នុងមន្ទីរសារការី សំណួរដែលចោទឡើងនោះគឺថា តើប្រធាននៃមន្ទីរសារការីដែលសារការី ក កំពុងបម្រើការនោះអាចបញ្ឈប់ ឬ បណ្តេញសារការី ក ពីមន្ទីរសារការីបានដែរឬទេ? បើយើងក្រឡេកទៅមើលនីតិវិធីរដ្ឋបាល បើសិនជាបុគ្គលណាម្នាក់ទទួលបានមុខងារណាមួយដោយលិខិតបទដ្ឋានដែលស្ថិតក្នុងឋានានុក្រមអ្វី ការដកហូតមុខងារ ឬ តំណែងបុគ្គលនោះក៏ត្រូវធ្វើតាមលិខិតបទដ្ឋាននោះ ឬលិខិតបទដ្ឋានដែលមានឋានានុក្រមខ្ពស់ជាង? ដូចនេះ បើយោងតាមគោលការណ៍ខាងលើ ប្រធានមន្ទីរសារការីមិនអាចដកហូតតំណែង ឬ បណ្តេញសារការី ក ចេញបានទេ លុះត្រាតែមានអនុក្រឹត្យមួយទៀតដែលចេញដោយរាជរដ្ឋាភិបាល ទើបអាចដកមុខងាររបស់គាត់បាន។

យោងតាមការលើកឡើងខាងលើយើងឃើញថា ដើម្បីទទួលបានតួនាទីក៏ដូចជាមុខងារជាសារការី គឺលុះត្រាតែបុគ្គលនោះបានទទួលការតែងតាំងដោយអនុក្រឹត្យ ប្រកាស ឬ តាមរយៈការបណ្តុះបណ្តាលចេញពីសាលាភូមិន្ទវិជ្ជាជីវៈសារការី ។

នៅពេលដែលបានទទួលមុខងារជាសារការីហើយ តើលក្ខខណ្ឌអ្វីខ្លះ ដែលសារការីអាចបង្កើតមន្ទីរសារការីបាន? ចំណុចបន្ទាប់យើងសូមលើកយកលក្ខខណ្ឌដើម្បីបង្កើតមន្ទីរសារការីមកធ្វើការបកស្រាយ ។

## ២.២. លក្ខខណ្ឌក្នុងការបង្កើតសារការី

បើយើងនិយាយអំពីលក្ខខណ្ឌក្នុងការបង្កើតមន្ទីរសារការី វាហាក់ដូចជាមានភាពមិនច្បាស់លាស់ឡើយក្នុងការកំណត់ ព្រោះលក្ខខណ្ឌទាំងនោះមិនមានកំណត់ឡើយនៅក្នុងច្បាប់សព្វថ្ងៃ។ ប៉ុន្តែបើយើងយោងទៅតាម ព្រះរាជក្រមលេខ ៩១០ ន.ស ចុះថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ និងយោងតាមអនុក្រឹត្យស្តីពីការតែងតាំង និងការបង្កើតមន្ទីរសារការីដែលរាជរដ្ឋាភិបាលបានចេញជាបន្តបន្ទាប់ យើងអាចទាញនូវលក្ខខណ្ឌ២យ៉ាងធំៗជាចម្បងក្នុងការបង្កើតមន្ទីរសារការីគឺ ត្រូវមាន

លក្ខណៈសម្បត្តិជាសារការី(២.២.១) និង ត្រូវមានប្រាក់តម្កល់ធានាក្នុងធនាគារជាតិនៃកម្ពុជា(២.២.២) សម្រាប់ធានាការទទួលខុសត្រូវក្នុងការបំពេញមុខងាររបស់ខ្លួន ។

### ២.២.១.លក្ខណៈសម្បត្តិជាសារការី

យើងដឹងហើយថាមានតែបុគ្គល ដែលទទួលបានមុខងារសារការីប៉ុណ្ណោះ ទើបមានសិទ្ធិក្នុងការស្នើសុំបង្កើតមន្ទីរសារការី។ ចំពោះលក្ខខណ្ឌដើម្បីក្លាយទទួលបានមុខងារជាសារការី យើងបានរៀបរាប់រួចហើយនៅក្នុងចំណុច២.១(លក្ខខណ្ឌដើម្បីក្លាយជាសារការី)។ ចំពោះលក្ខខណ្ឌទី១ដែលតម្រូវឲ្យបុគ្គលដែលចង់ង្កើតជាមន្ទីរសារការី ត្រូវតែជាបុគ្គលដែលទទួលបានមុខងារជាសារការីនេះ គឺជាលក្ខខណ្ឌដាច់ខាត។

ការទទួលបានមុខងារជាសារការីមានន័យថា បុគ្គលមួយរូបបានបំពេញនូវលក្ខខណ្ឌក្នុងការក្លាយខ្លួនជាសារការីយ៉ាងពេញលេញ ដោយមានទាំងចំណេះដឹង និង បទពិសោធន៍យ៉ាងច្បាស់លាស់ក្នុងការបំពេញមុខងារ ក៏ដូចជាភារកិច្ចរបស់ខ្លួន ក្នុងគោលដៅធានាដល់ការអនុវត្តមុខងារឲ្យមានប្រសិទ្ធិភាព និងបម្រើផលប្រយោជន៍ដល់បុគ្គលឯកជន ព្រមទាំងសង្គមជាតិទាំងមូល។

ជាក់ស្តែង រាជរដ្ឋាភិបាលបានចេញនូវអនុក្រឹត្យដើម្បីតែងតាំងបុគ្គលមួយចំនួនជាសារការីដែលមានដូចជា៖

-អនុក្រឹត្យ លេខ ១៩៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០០៨ បានទទួលស្គាល់មន្ទីរសារការី **អេច ប៊ី អេស** នៃព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតនៅក្រោមការដឹកនាំរបស់សារការីចំនួន ២ រូបគឺ លោក លី តែសេង និងលោក តាន់ហ៊ាង ដារ័ណ្ណ។

- អនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០១៦ ទទួលស្គាល់មន្ទីរសារការី **អេស ខេ វ៉ាយ** នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានតែងតាំងជាសារការីនូវបុគ្គលដែលមានរាយនាមដូចខាងក្រោម៖

១. លោកស្រី **អេង គីមសួគ៌** ដើម្បីបំពេញមុខងារជាប្រធាននៃមន្ទីរសារការី អេស ខេ វ៉ាយ

២. លោក **សែន សេងថៃ** ដើម្បីបំពេញមុខងារជាអនុប្រធាននៃមន្ទីរសារការី អេស ខេ វ៉ាយ

៣. លោក **អ៊ី ម៉ាណោ** ដើម្បីបំពេញមុខងារជាសមាជិកនៃមន្ទីរសារការី អេស ខេ វ៉ាយ ។

- អនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី ០២ ខែកុម្ភៈឆ្នាំ ២០១៦ ស្តីពីការបង្កើតមន្ទីរសារការី **លុច ស៊ីអេចឌី** នៃព្រះរាជាណាចក្រកម្ពុជា ។ អនុក្រឹត្យនេះ បានតែងតាំងលោក **ទូត លុច** ជាសារការីដើម្បីដឹកនាំមន្ទីរសារការី លុច ស៊ីអេចឌី។

យោងតាមមាត្រា៣[46] នៃអនុក្រឹត្យស្តីពីការបង្កើតសារការីដូចបានលើកឡើងខាងលើនេះបាន កំណត់យ៉ាងច្បាស់ថា មានតែសារការីប៉ុណ្ណោះដែលអាចបង្កើត និង ដឹកនាំមន្ទីរសារការីបាន។ ចំពោះការកំណត់នូវអាស័យដ្ឋានយ៉ាងជាក់លាក់នៃមន្ទីរសារការីនីមួយៗ គ្រាន់តែជាលក្ខខណ្ឌទម្រង់បន្ទាប់បន្សំប៉ុណ្ណោះ ពោលគឺជាការបំពេញបន្ថែមដើម្បីឲ្យនីតិបុគ្គល(មន្ទីរសារការី)នោះមានភាពកាន់តែច្បាស់លាស់។

ក្រៅពីលក្ខខណ្ឌចម្បងខាងលើ លក្ខខណ្ឌចម្បងទី ២ ដែលត្រូវតែបំពេញតាមការកំណត់ដោយច្បាប់ គឺបុគ្គលដែលជាសារការីត្រូវមានធនធាន និងតម្កល់ប្រាក់មួយចំនួនធំក្នុងធនាគារជាតិនៃកម្ពុជា។

## ២.២.២.ការតម្កល់ប្រាក់ធានានៅធនាគារជាតិនៃកម្ពុជា

បើយើងក្រឡេកទៅមើល តាមមាត្រា ៩ នៃព្រះរាជក្រមលេខ ៩១០ ន.ស ចុះថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ ការតែងតាំងសារការីត្រូវធ្វើតាមព្រះរាជក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានកម្រិតប្រាក់ធានាដូចខាងក្រោមនេះ៖

១. ដាក់ប្រាក់ធានា ៥០០.០០០ រៀល ក្នុងគណនីឃ្លាំងធនាគារ ឬ គ្រឹះស្ថានចងការប្រាក់ ដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានអនុញ្ញាត

២. បញ្ជាក់ថា ខ្លួនមានអសង្ហារឹមទ្រព្យនៅប្រទេសខ្មែរ ផុតចាកពីការដាក់ធានាបញ្ចាំ និងការបញ្ចាំទាំងអស់ អាចបញ្ចាំជាតម្លៃតាមក្បួនប្រថាប់ត្រាបានយ៉ាងតិច ១.០០០.០០០ រៀល មុននឹងទទួលសម្បថសច្ចាប្រណិធាន សាមីខ្លួនត្រូវដាក់បញ្ចាំអសង្ហារឹមទ្រព្យនេះ ជាប្រយោជន៍ឃ្លាំងប្រាក់ក្នុងតម្លៃ ១.០០០.០០០ រៀល ។

យោងតាមមាត្រា ៩ នេះបានបង្ហាញយ៉ាងច្បាស់ថា សារការីត្រូវមានធនធានក្នុងការធានារ៉ាប់រងមុខងារ និងមន្ទីររបស់ខ្លួនចំពោះមុខរដ្ឋ ដើម្បីជាប្រយោជន៍ដល់ប្រទេសជាតិ។ ប៉ុន្តែដូចដែលយើងបានដឹងហើយថា ព្រះរាជក្រមនេះមិនត្រូវបានយកមកអនុវត្តក្នុងសង្គមបច្ចុប្បន្នឡើយ ដោយមូលហេតុនិរាករណ៍ដោយតុល្យភាព ហេតុដូចនេះ ក្នុងការចេញនូវអនុក្រឹត្យស្តីពីការបង្កើតមន្ទីសារការីនីមួយៗដោយរាជរដ្ឋាភិបាល ត្រូវកំណត់ឲ្យបានច្បាស់នៅក្នុងមាត្រាតែម្តងស្តីពីចំនួនប្រាក់ដែលសារការីត្រូវតម្កល់ក្នុងធនាគាជាតិសម្រាប់ធានានូវមុខងារផ្សេងៗ ដែលច្បាប់បានកំណត់ ។

[46] អនុក្រឹត្យខ្លះបញ្ញត្តិក្នុងមាត្រា២។

**<u>ជាឧទាហរណ៍៖</u>** មាត្រា ៥ នៃអនុក្រឹត្យលេខ ១៤៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០០៨ ដែលស្តីពីការបង្កើតមន្ទីសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា បានតម្រូវនូវការបង់ប្រាក់តម្កល់ចំនួន ៦០០.០០០.០០០ រៀល នៅធនាគារជាតិនៃកម្ពុជា។

មាត្រា ៥ នៃអនុក្រឹត្យលេខ ០៩ អនក្រ.បក ស្តីពីការបង្កើតមន្ទីសារការី **អេស ខេ វ៉ាយ** នៃព្រះរាជាណាចក្រកម្ពុជា និង មាត្រា ៤ នៃអនុក្រឹត្យលេខ ១៨ អនក្រ.បក ស្តីពីការបង្កើតមន្ទីសារការី **លុច ស៊ីអេចឌី** ក៏បានកំណត់យ៉ាងច្បាស់លាស់នូវការបង់ប្រាក់តម្កល់ចំនួន ៦០០.០០០.០០០ រៀល នៅធនាគារជាតិនៃកម្ពុជា នៅពេលចាប់ផ្តើមប្រតិបត្តិការសកម្មភាពរបស់ខ្លួន ដើម្បីធានាការទទួលខុសត្រូវក្នុងការបំពេញមុខងារ។

សរុបមក ទោះបីជាមិនមានការកំណត់ពីលក្ខខណ្ឌច្បាស់លាស់ក្នុងការបង្កើតមន្ទីរសារការីក៏ដោយ ក៏យើងអាចសន្មតអំពីលក្ខខណ្ឌក្នុងការទទួលបាននូវមុខងារជាសារការី ដែលបេក្ខជនត្រូវតែបំពេញដូចបានរៀបរាប់ខាងលើ ហើយមានតែសារការីដែលមានធនធាន ក្នុងការបង់ប្រាក់តម្កល់ធានាប៉ុណ្ណោះទេទើបអាចធ្វើការស្នើសុំបង្កើត និងដឹកនាំមន្ទីរសារការី ដើម្បីអនុវត្តមុខងាររបស់ខ្លួនបាន។ ទាក់ទងនឹងការតែងតាំងសារការីដោយអនុក្រឹត្យនេះផងដែរ មានចំណុចដែលគួរតែលើកយកមកពិចារណាក្នុងករណីដែលសមាជិកនៃមន្ទីរសារការីណាម្នាក់បានប្រព្រឹត្តកំហុសក្នុងពេលអនុវត្តមុខងារ។

**<u>ឧទាហរណ៍៖</u>** សារការី **ក** បានប្រព្រឹត្តកំហុសដែលត្រូវសងសំណងការខូចខាតទៅអតិថិជនចំនួន ៨០០.០០០.០០០លានរៀល ក្នុងករណីនេះថាតើសារការី **ក** ត្រូវទទួលខុសត្រូវក្នុងនាមបុគ្គល ឬ ទទួលខុសត្រូវក្នុងនាមមន្ទីរសារការីទាំងមូល? បើសិនជាយើងពិចារណាអំពីមូលហេតុនៃការដាក់ប្រាក់តម្កល់ក្នុងធនាគារនៃកម្ពុជាចំនួន៦០០លានរៀល គឺដើម្បីធានាដល់ការទទួលខុសត្រូវក្នុងការអនុវត្តមុខងាររបស់សារការីក្នុងពេលមានកំហុស ដូចនេះយើងអាចសន្និដ្ឋានបានថា កំហុសរបស់សារការី **ក** ត្រូវទទួលខុសត្រូវក្នុងមានមន្ទីរ ពោលគឺត្រូវយកលុយតម្កល់ចំនួន៦០០លានរៀលនោះ ទៅបង់ជាសំណងការខូចខាតដល់អតិថិជន។ រីឯសំណងចំនួន២០០លានរៀលត្រូវជាការទទួលខុសត្រូវរបស់មន្ទីរ ឬ របស់សារការី **ក**? ម្យ៉ាងវិញទៀត ករណីដែលមន្ទីរសារការីនោះត្រូវបាត់បង់ប្រាក់តម្កល់ចំនួន៦០០លានរៀល តើរាជរដ្ឋាភិបាលត្រូវចេញអនុក្រឹត្យលុបចោលអនុក្រឹត្យស្តីពីការបង្កើតមន្ទីរសារការីនោះ ឬ មន្ទីរសារការីនោះត្រូវប្រកាសក្ស័យធន? ដោយសារតែនាពេលបច្ចុប្បន្នមិនទាន់មានច្បាប់ស្តីពីលក្ខន្តិក:សារការី ចំពោះចំណោទសំណួរខាងលើមិនទាន់មានចម្លើយនៅឡើយទេ។ ប៉ុន្តែបើយើងមើលទៅលើឋានៈដោយផ្អែកតាមច្បាប់ ដោយផ្អែកតាមនិយមន័យដែលផ្តល់ឲ្យដល់សារការីវិញ គេបានបញ្ញត្តិថា "សារការី ជា**មន្ត្រីសាធារណៈ** .....។" ដូចនេះយើងអាចសន្និដានបានថា សារការីនៃប្រទេសកម្ពុជាមានឋានៈដោយផ្អែកតាមច្បាប់ ជាមន្ត្រីដែលបម្រើការងារឲ្យរដ្ឋផង និង

បម្រើផលប្រយោជន៍របស់ខ្លួនផងដោយមូលហេតុសារការីទទួលបានកម្រៃតាមរយៈសេវាក្នុងការផ្ដល់យថាភូតភាព ឬ ផ្ដល់ការបញ្ជាក់លើលិខិតណាមួយ។ ត្រង់ចំណុចនេះ តើកំហុសរបស់សារការីអាចបែងចែកការទទួលខុសត្រូវមួយផ្នែកឲ្យដល់រដ្ឋដែរឬទេ? ព្រោះថាសារការីបំពេញមុខងាររបស់ខ្លួនក្នុងនាមមន្ត្រីសាធារណៈ។ យោងតាមមាត្រា ៧៤៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ស្ដីអំពី **"អំពើអនីត្យានុកូលរបស់មន្ត្រីរាជការសាធារណៈ"** នឹងអាចយកមកអនុវត្តក្នុងករណីខាងលើនេះបាន។

**<u>បញ្ហាក់៖</u>** នៅក្នុងមន្ទីរសារការីមួយ មិនបានកំណត់អំពីចំនួនសារការីដែលត្រូវតែងតាំងដើម្បីអនុវត្តមុខងាររបស់ខ្លួននោះទេ ហេតុដូចនេះហើយ ទើបយើងឃើញនៅក្នុងអនុក្រឹត្យស្ដីពីការបង្កើតមន្ទីរសារការីមួយចំនួន នៅក្នុងមន្ទីរសារការីខ្លះមានសារការីត្រឹមតែ១រូប(មន្ទីរសារការី សុក ស៊ីផាន់ណា) ឯមន្ទីរសារការីខ្លះមានសារការីដល់ទៅ៦រូប(មន្ទីរសារការីអង្គរ)។

បន្តទៅទៀតនេះ យើងនឹងបង្ហាញអំពីបច្ចុប្បន្នភាពនៃវិជ្ជាជីវៈសារការីនៃព្រះរាជាណាចក្រកម្ពុជា(ផ្នែកទី៣)។

## ផ្នែកទី៣ បច្ចុប្បន្នភាពនៃវិជ្ជាជីវៈសារការី(ឆ្នាំ២០១៦)

នៅក្នុងផ្នែកនេះ យើងនឹងសិក្សាបង្ហាញអំពីបច្ចុប្បន្នភាពនៃវិជ្ជាជីវៈសារការីផ្ដោតទៅលើអត្ថិភាពនៃលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិជ្ជាជីវៈសារការី(៣.១) ព្រមទាំងចំនួនសារការី និងមន្ទីរសារការីនាពេលបច្ចុប្បន្ន(៣.២)។

### ៣.១.លិខិតបទដ្ឋានពាក់ព័ន្ធនឹងសារការី

ចំពោះលិខិតបទដ្ឋានដែលពាក់ព័ន្ធទៅនឹងមុខងាររបស់សារការី យើងឃើញមានព្រះរាជក្រមលេខ៩១០ នស ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ និងសេចក្ដីព្រាងច្បាប់ស្ដីអំពីលក្ខន្តិកៈនៃសារការី។ ចំពោះព្រះរាជក្រមលេខ៩១០ត្រូវបានគេលើកឡើងអំពីភាពនៅជាធរមានរបស់វា ពោលគឺថាតើព្រះរាជក្រមខាងលើអាចយកមកគ្រប់គ្រងសារការីនាពេលបច្ចុប្បន្នបានដែរឬ? មូលហេតុដែលនាំឲ្យមានការលើកឡើងបែបនេះ ក៏ដោយសារតែព្រះរាជក្រមលេខ៩១០មិនត្រូវបានយកប្រើប្រាស់នៅក្នុងសម័យនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយបន្តដល់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសម័យរដ្ឋកម្ពុជាដែលមិនមានវត្តមានសារការី។ ទើបតែនៅឆ្នាំ២០០១ រាជរដ្ឋាភិបាលចេញអនុក្រឹត្យមួយស្ដីពីការបន្ថែមសមត្ថកិច្ចដល់លោកមេធាវី បែនសុន សម័យ ឲ្យក្លាយជាមេធាវីសារការី។ ប៉ុន្តែនៅតែមានចម្ងល់ថាតើសារការីរូបនេះត្រូវបានគ្រប់គ្រងដោយព្រះរាជក្រមលេខ៩១០ដែរឬទេ? ហេតុនេះហើយទើបត្រូវបានសន្មតថាព្រះរាជក្រមលេខ៩១០ នស ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ បាននិរាករណ៍ដោយតុណ្ហីភាព។

ចំណែកឯសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិក:នៃសារការី ដែលធ្វើឡើងនៅឆ្នាំ២០០៧ ត្រូវបានក្រសួងយុត្តិធម៌នាព្រឹកថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦ លើកយកទៅប្រជុំពិភាក្សាជាលើកដំបូងអមជាមួយនឹងសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិក:នៃក្រឡាបញ្ជី និងសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិក:នៃអាជ្ញាសាលា ហើយឯកឧត្តម អង្គ វង្សវឌ្ឍានា រដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌បានលើកឡើងថា នឹងព្យាយាមឲ្យសេចក្តីព្រាងច្បាប់នេះក្លាយទៅជាច្បាប់ពេញលេញនៅចុងឆ្នាំ២០១៦នេះ ព្រោះសេចក្តីព្រាងច្បាប់ទាំងបីនេះ មានគោលដៅគ្រប់គ្រង លើកតម្កើងវិជ្ជាជីវ:ច្បាប់ និងតុលាការ ពង្រឹងសុវត្ថិភាពគតិយុត្តជូនសាធារណជន ជាពិសេសវិនិយោគិន បង្កើនប្រសិទ្ធិភាព និងវិសាលភាពនៃសេវាច្បាប់ និងយុត្តិធម៌រួមចំណែកក្នុងការបង្ការ និងកាត់បន្ថយជម្លោះ និងបណ្តឹងនៅតាមសាលាជម្រះក្តី ជាពិសេសចំពោះវិវាទដីធ្លី ព្រមទាំងលើកកម្ពស់ទំនុកចិត្តរបស់ប្រជាពលរដ្ឋលើវិស័យច្បាប់ និងយុត្តិធម៌[47]។

អវត្តមាននូវច្បាប់ស្តីពីលក្ខន្តិក:សារការី គឺជាមូលហេតុដ៏ចម្បងមួយដែលនាំឲ្យវិជ្ជាជីវ:នៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ដែលមានបញ្ហាដែលមិនទាន់ដោះស្រាយបានដូចដែលបានលើកឡើងខាងលើ ហើយវាក៏ជាហេតុដែលនាំឲ្យដំណើរវិវត្តន៍នៃប្រព័ន្ធសារការី នៅក្នុងប្រទេសកម្ពុជាហាក់នៅមានកម្រិត។

### ៣.២.ចំនួនសារការី និងចំនួននៃមន្ទីរសារការី

គិតត្រឹមខែមិថុនា ឆ្នាំ២០១៦ សារការីដែលត្រូវបានតែងតាំងដោយអនុក្រឹត្យក្នុងប្រទេសកម្ពុជាមានចំនួន៤៨រូប និងមន្ទីរសារការីចំនួន១១។

ខាងក្រោមនេះគឺជាឈ្មោះនៃមន្ទីរសារការី និងឈ្មោះរបស់សារការីដែលកំពុងអនុវត្តមុខងារក្នុងមន្ទីរនោះ៖

| មន្ទីរសារការី | ឈ្មោះសារការី | កាលបរិច្ឆេទបង្កើត |
|---|---|---|
| បែន សុនសម័យ | បែនសុន សម័យ[48] | ០៤ ធ្នូ ២០០១ |
| អេច ប៊ី អេស | លី តៃសេង<br>តាន់ហ៊ា ដាវ័ណ្ណ | ២៣ កញ្ញា ២០០៨ |
| | ឈុន ព្រលឹង | |

[47]គេហទំព័រផ្លូវការរបស់ក្រសួងយុត្តិធម៌, https://www.facebook.com/%E1%9E%80%E1%9F%92%E1%9E%9A%E1%9E%9F%E1%9E%BD%E1%9E%84%E1%9E%99%E1%9E%BB%E1%9E%8F%E1%9F%92%E1%9E%8F%E1%9E%B7%E1%9E%92%E1%9E%98%E1%9F%8C-Ministry-of-Justice-367835473349148/?fref=ts (ចូលទស្សនាថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦)។

[48] ចំពោះលោកបែន សុនសម័យ គឺទទួលបានការតែងតាំងបន្ថែមលើមុខងារមេធាវី ដូចនេះលោកគឺជាមេធាវីសារការី។

| | | |
|---|---|---|
| វាណិជ្ជ និងសហភាគា | ថោង ចិន្តា<br>នៅ សុជាតា | ០១ សីហា ២០១៤ |
| សេដ្ឋាវិទូ | នាក់ សេរីគិរីន<br>ដាវ អានសាន<br>ប៊ូន សារៈមុនី<br>ទី ហ្សានិត | ២៥ កញ្ញា ២០១៤ |
| ខេមរា | ហ្វូត ហាក់<br>ផូវ សំភី<br>សេង សត្យា | ១២ មីនា ២០១៥ |
| នីតិនិវន្តន៍ | ស៊ុន សំណាង<br>គួន លីនណា<br>ផូ សុធាផល | ១២ មីនា ២០១៥ |
| ស៊ុក ស៊ីផាន់ណា | ស៊ុក ស៊ីផាន់ណា | ១១ កញ្ញា ២០១៥ |
| ភ្នំពេញ | ហេង ឆាយ<br>ស៊ុន តុលា<br>កាន់ សុទ្ធប៉ូលីន<br>ម៉ុក ចាន់សុធា<br>មិន្ទស៊ុំ សូលីដា<br>ស៊ុន ដានី<br>តាន់ ទេពីកាណ្ណិកា<br>បែល សក្តិភក្តី | ០១ តុលា ២០១៥ |
| អេស ខេ វ៉ាយ | អេង គីមសួគ<br>សែន សេងថៃ<br>អ៊ី ម៉ានោ | ១៨ មករា ២០១៦ |
| លុច ស៊ីអេចឌី | ទូត លុច | ០២ កុម្ភៈ ២០១៦ |
| អង្គរ | សាំង វណ្ណៈ<br>ប៉ា ងួនគា<br>អ៊ាង សូរសែន<br>សេង សុខឃីម<br>ជា ហុងរី<br>ហ៊ី ថុនា | ១០ មីនា ២០១៦ |

ជំពូកបន្ទាប់ សារណានេះនឹងបង្ហាញអំពី**ការជ្រើសតាំងសារការី និងការបង្កើតមន្ទីរសារការី នៃប្រទេសជប៉ុន**។

# ជំពូកទី២

# ការជ្រើសតាំងសារការី និងការបង្កើតមន្ទីរសារការីនៃប្រទេសជប៉ុន

មុននឹងបង្ហាញអំពីនីតិវិធីនៃការជ្រើសតាំងសារការី និងបែបបទនៃការបង្កើតមន្ទីរសារការី (ផ្នែកទី២) ជាដំបូងសារណានេះនឹងបង្ហាញនូវសញ្ញាណទូទៅខ្លះៗទាក់ទងនឹងសារការីនៃប្រទេសជប៉ុន(ផ្នែកទី១) ហើយចំណុចចុងក្រោយនឹងបង្ហាញអំពីបច្ចុប្បន្នភាពនៃសារការីរបស់ប្រទេសជប៉ុន (ផ្នែកទី៣)។

## ផ្នែកទី១ សញ្ញាណទូទៅទាក់ទងនឹងសារការី

នៅក្នុងផ្នែកនេះ យើងនឹងបង្ហាញនូវចំណុចពីរធំៗគឺ ចំណុចទី១ស្តីអំពីប្រវត្តិនៃការកកើតនូវវិជ្ជាជីវៈសារការី(១.១) ដោយបានលើកយកនូវបទបញ្ញត្តិស្តីពីសារការី(១.១.១) និងច្បាប់ស្តីពីសារការី(១.១.២) ដែលជាលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិជ្ជាជីវៈសារការីដំបូងគេក្នុងប្រទេសជប៉ុន។ បន្ថែមពីលើនេះយើងនឹងបង្ហាញអំពីដំណើរវិវត្តន៍នូវរបបសារការីក្នុងអំឡុងពេលដែលប្រទេសជប៉ុនឆ្លងកាត់សង្គ្រាម(១.១.៣) ថាតើមុខងាររបស់សារការីមានការប្រែប្រួលបែបណា? ទើបឈានទៅដល់ការធ្វើវិសោធនកម្មច្បាប់ស្តីពីសារការី(១.១.៣)។ រីឯចំណុចទី២គឺស្តីអំពីលិខិតដែលធ្វើឡើងដោយសារការី (១.២) ដោយបានលើកយកនូវ ប្រភេទលិខិតដែលធ្វើឡើងដោយសារការី(១.២.១) និងរបៀបនៃការបញ្ជាក់របស់សារការីនៃប្រទេសជប៉ុន ថាតើមុននឹងផ្តល់យថាភូតភាព ឬ ផ្តល់ការបញ្ជាក់លើលិខិតណាមួយនោះ សារការីត្រូវត្រូវពិនិត្យលើចំណុចអ្វីខ្លះ?(១.២.២)។

### ១.១.ប្រវត្តិនៃការកកើតវិជ្ជាជីវៈសារការីនៃប្រទេសជប៉ុន

ប្រព័ន្ធសារការីនៃប្រទេសជប៉ុន ចាប់កកើតជាលើកដំបូងក្នុងអំឡុងសតវត្សទី១៨ ហើយដើម្បីរៀបចំប្រព័ន្ធនេះឲ្យមានភាពល្អប្រសើរ នាពេលនោះលិខិតបទដ្ឋានមួយចំនួនត្រូវបានអនុម័តជាបន្តបន្ទាប់ ក្នុងនោះមានដូចជាបទបញ្ញត្តិស្តីពីសារការី(១.១.១)ច្បាប់ស្តីពីសារការី(១.១.២) ហើយដោយសារតែប្រទេសជប៉ុនបានឆ្លងកាត់នូវសង្គ្រាម(១.១.៣) ដែលធ្វើឲ្យប្រព័ន្ធសារការីបានទទួលរងឥទ្ធិពលផងដែរ ជាលទ្ធផលច្បាប់ស្តីពីប្រព័ន្ធសារការីក៏ត្រូវបានធ្វើវិសោធនកម្ម(១.១.៤) ។

#### ១.១.១.បទបញ្ញត្តិស្តីពីសារការី

ប្រព័ន្ធសារការីនៃប្រទេសជប៉ុន ចាប់កកើតជាលើកដំបូងក្នុងអំឡុងសតវត្សទី១៨ នាពេលនោះបទបញ្ញត្តិស្តីពីសារការីត្រូវបានអនុម័តនៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៨៦ ដោយទទួលឥទ្ធិពលពី

ប្រព័ន្ធច្បាប់នៃប្រទេសបារាំង[49]។ អនុលោមតាមបទបញ្ញត្តិខាងលើ ការប្រឡងជ្រើសរើសសារការីត្រូវបានរៀបចំឡើងជាលើកដំបូងនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៨៨៧ ហើយការតែងតាំងសិស្សសារការីជាសារការីពេញសិទ្ធិជាលើកដំបូងក៏ត្រូវបានរៀបចំឡើងនៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៨៨៩ ដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌[50]។ នាថ្ងៃទី២៤ ខែសីហា ក្នុងឆ្នាំដដែល ចំនួនសារការីនៅក្នុងប្រទេសជប៉ុនទាំងមូលមានចំនួន១២៣នាក់ ក្នុងនោះ១២នាក់ជាអតីតចៅក្រម ២៨នាក់ជាអតីតជំនួយការចៅក្រម និងអគ្គព្រះរាជអាជ្ញា ៣០នាក់ជាអតីតមេធាវី ព្រមទាំងបេក្ខភាពដែលឆ្លងកាត់ការបណ្តុះបណ្តាលចំនួន៥៣នាក់[51]។

ចាប់ពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៨៨៧ រហូតដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩០ ការប្រឡងជ្រើសរើសសារការីបានធ្វើឡើងចំនួន៥លើក[52]។ ចំណែកឯការបំពេញភារកិច្ចរបស់សារការីនាអំឡុងពេលនោះ គឺត្រូវបានច្បាប់កម្រិតដែនសមត្ថកិច្ច ដោយសារការីអាចបំពេញមុខងារត្រឹមតែធ្វើការបញ្ជាក់ពីភាពត្រឹមត្រូវនៃកិច្ចសន្យាតែប៉ុណ្ណោះ មិនរួមបញ្ចូលនូវការផ្តល់យថាភូតភាពលើលិខិតផ្សេងៗនោះទេ។ ចំពោះគោលបំណងនៃការបង្កើតប្រព័ន្ធសារការីរបស់ប្រទេសជប៉ុននាពេលនោះ គឺដើម្បីបញ្ជាក់ពីការរៀបចំប្រព័ន្ធច្បាប់ក្នុងប្រទេសមួយយ៉ាងត្រឹមត្រូវ ដោយមានការប្រគល់អំណាចពីរដ្ឋក្នុងការបំពេញមុខងារដល់សារការី មិនមែនបង្កើតឡើងក្នុងភាពចាំបាច់ជាក់ស្តែង ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនផ្នែកសេដ្ឋកិច្ចរបស់ប្រទេសជប៉ុននាពេលនោះទេ។ ដោយសារតែមូលហេតុនេះហើយ ទើបមុខងារសារការីនាពេលនោះត្រូវបានកម្រិត[53]។

## ១.១.២. ច្បាប់ស្តីពីសារការី

ច្បាប់ស្តីពីសារការីនៃប្រទេសជប៉ុនត្រូវបានអនុម័តឡើងនៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩០៨ ដោយទទួលឥទ្ធិពលពីប្រព័ន្ធច្បាប់នៃប្រទេសអាល្លឺម៉ង់។ ស្របពេលនោះដែរ សារការីទូទាំងប្រទេសជប៉ុនមានការកើនឡើងរហូតដល់៣០៥នាក់[54]។ ច្បាប់ថ្មីនេះ បានពង្រីកវិសាលភាពមុខងារដល់សារការីយ៉ាងទូលាយ ដោយក្នុងនោះ សារការីមានអំណាចក្នុងការបញ្ជាក់ភាពត្រឹមត្រូវនៃលិខិតឯកជន ផ្តល់យថាភូតភាពលើលិខិតឯកជន ជាដើម។ បន្ថែមពីលើលក្ខខណ្ឌដែលអាចត្រូវបានជ្រើសតាំងជា

---

[49] 日本公証人連合会, *公証制度百年史* [ប្រវត្តិមួយរយឆ្នាំនៃប្រព័ន្ធសារការី] , ទំព័រទី១៥-១៦។
[50] 日本公証人連合会, *公証制度百年史* [ប្រវត្តិមួយរយឆ្នាំនៃប្រព័ន្ធសារការី] , ទំព័រទី១៩។
[51] 日本公証人連合会, *公証制度百年史* [ប្រវត្តិមួយរយឆ្នាំនៃប្រព័ន្ធសារការី] , ទំព័រទី៣៣។
[52] 日本公証人連合会, *公証制度百年史* [ប្រវត្តិមួយរយឆ្នាំនៃប្រព័ន្ធសារការី] , ទំព័រទី៥២៦-៥២៧។
[53] 日本公証人連合会, *公証制度百年史* [ប្រវត្តិមួយរយឆ្នាំនៃប្រព័ន្ធសារការី] , ទំព័រទី៣៩-៤០,៥៤៣។
[54] 日本公証人連合会, *公証制度百年史* [ប្រវត្តិមួយរយឆ្នាំនៃប្រព័ន្ធសារការី] , ទំព័រទី៤៩,៥៩។

សារការីតាមរយៈការប្រឡងប្រជែង និងការចុះកម្មសិក្សារបស់សិស្សសារការី ច្បាប់ថ្មីនេះក៏បានអនុញ្ញាតដល់ចៅក្រម ព្រះរាជអាជ្ញា ឬ មេធាវី នឹងអាចត្រូវបានជ្រើសតាំងជាសារការី ដោយមិនចាំបាច់ឆ្លងកាត់ការប្រឡងផងដែរ[55]។

### ១.១.៣. ប្រព័ន្ធសារការីក្នុងអំឡុងពេលមានសង្គ្រាម

ចាប់ពីថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩៣៧ ស្ថានភាពប្រទេសជប៉ុនបានផ្លាស់ប្តូរដោយសារតែសង្គ្រាម ហើយប្រព័ន្ធសេដ្ឋកិច្ចនាសម័យនោះ ក៏ត្រូវបានផ្លាស់ប្តូរទៅតាមបរិបទប្រទេសដែលមានសង្គ្រាមផងដែរ[56]។ នាពេលនោះ បើយើងក្រឡេកទៅមើលប្រព័ន្ធសារការីក៏ទទួលរងឥទ្ធិពលផងដែរ ដោយកិច្ចការដែលសារការីត្រូវធ្វើមានការធ្លាក់ចុះ កម្រិតជីវភាពរបស់សារការីនីមួយៗ ជួបប្រទះការលំបាកដូចជាប្រជាពលរដ្ឋសាមញ្ញដទៃទៀតដែរ[57]។ ប៉ុន្តែ ដោយនៅឆ្នាំ១៩៤០ ប្រទេសជប៉ុនបានធ្វើការបង្កើតឲ្យមាន ប្រព័ន្ធត្រួតពិនិត្យលក្ខន្តិកៈក្រុមហ៊ុន ហើយដោយយោងតាមច្បាប់ស្តីពីក្រុមហ៊ុនដែលត្រូវបានធ្វើវិសោធនកម្ម និងប្រកាសឲ្យប្រើនៅថ្ងៃទី០១ ខែមករា ឆ្នាំដដែលនោះ លក្ខន្តិកៈក្រុមហ៊ុនមូលធន ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត តម្រូវឲ្យមានការបញ្ជាក់ភាពត្រឹមត្រូវ និងពិនិត្យឲ្យបានលម្អិតពីសំណាក់សារការី[58] ដែលជាមូលហេតុធ្វើឲ្យមុខងាររបស់សារការីកាន់តែដើរតួនាទីយ៉ាងសំខាន់ក្នុងវិស័យឯកជន ជាពិសេសចំពោះការផ្តល់ការបញ្ជាក់ភាពពិតទៅលើលិខិតឯកជន និងលក្ខន្តិកៈរបស់នីតិបុគ្គល។

### ១.១.៤. វិសោធនកម្មច្បាប់ស្តីពីសារការី

ក្រោយពីប្រទេសជប៉ុនបានចាញ់សង្គ្រាមនៅថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៤៥ ហើយនៅថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៤៧ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រជប៉ុនក៏ត្រូវបានប្រកាសឲ្យប្រើប្រាស់។ យោងតាមរដ្ឋធម្មនុញ្ញថ្មីនេះ គេធ្វើការបែងចែកក្រសួងយុត្តិធម៌ និងតុលាការ ជាពីរស្ថាប័នដាច់ដោយឡែកពីគ្នា ហើយសារការី បានស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌ ដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាបុគ្គលតែមួយគត់ មានអំណាចក្នុងការតែងតាំងបុគ្គលណាម្នាក់ជាសារការី និងត្រួតពិនិត្យដោយមានការិយាល័យកិច្ចការច្បាប់ក្នុងតំបន់ (法務局/Regional Legal Affair Bureau) ជំនួយការ

[55] 日本公証人連合会, *公証制度百年史* [ប្រវត្តិមួយរយឆ្នាំនៃប្រព័ន្ធសារការី] , ទំព័រទី៥២៦-៥២៧។

[56] 日本公証人連合会, *日本公証人制度の概要と問題点* [សង្ខេបអំពីប្រព័ន្ធសារការីជប៉ុន និងចំនុចបញ្ហា] , ទំព័រទី២, http://yuigon.usdatashohisha_a_7.pdf (ចូលទស្សនាថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦)។

[57] 日本公証人連合会, *公証制度百年史* [ប្រវត្តិមួយរយឆ្នាំនៃប្រព័ន្ធសារការី] , ទំព័រទី៨៤-៨៥។

[58] 日本公証人連合会, *公証制度百年史* [ប្រវត្តិមួយរយឆ្នាំនៃប្រព័ន្ធសារការី] , ទំព័រទី៨៦។

របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្នុងកិច្ចការខាងលើនេះ។ បន្ទាប់មក នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៤៩ ច្បាប់ស្តីពីសារការីត្រូវបានធ្វើវិសោធនកម្ម ហើយនៅថ្ងៃទី១ ខែមិថុនា ឆ្នាំដដែល ច្បាប់ស្តីពីវិសោធនកម្មច្បាប់សារការីត្រូវបានប្រកាសឲ្យប្រើជាសាធារណៈ។ ក្រោយពីច្បាប់ស្តីពីសារការីត្រូវបានធ្វើវិសោធនកម្ម មុខងារសារការី ដូចជាមានការយកចិត្តទុកដាក់យ៉ាងខ្លាំង ពីសំណាក់រាជរដ្ឋាភិបាលនៃប្រទេសជប៉ុន។ ជាក់ស្តែង លិខិតបទដ្ឋានពាក់ព័ន្ធមួយចំនួនត្រូវបានអនុម័តជាបន្តបន្ទាប់មាន ជាអាទិ៍ បទវិន័យក្នុងការអនុវត្តច្បាប់ស្តីពីសារការី（公証人法施行規則）បទបញ្ជាស្តីអំពីគណៈកម្មការត្រួតពិនិត្យសារការី（公証人審査会令）បទបញ្ជាស្តីអំពីប្រាក់ធានានូវប្រវត្តិរបស់សារការី（公証人身元保証金令）បទបញ្ជាស្តីអំពីសារការីពេញសិទ្ធិ（公証人定員規則）បទវិន័យស្តីអំពីប្រាក់កម្រៃជើងសាររបស់សារការី（公証人手数料）ដែលលិខិតបទដ្ឋានទាំងនេះត្រូវបានប្រកាសឲ្យប្រើប្រាស់រួចហើយ[59]។ ទន្ទឹមនឹងការធ្វើវិសោធនកម្មប្រព័ន្ធសារការីយ៉ាងខ្លាំងបែបនេះ វិជ្ជាជីវៈសារការីត្រូវបានគេលើកឡើងថាជាវិជ្ជាជីវៈមួយដែលតម្រូវឲ្យមាននូវបទពិសោធន៍ការងារពាក់ព័ន្ធនឹងច្បាប់ជាច្រើន ជាហេតុធ្វើឲ្យគណៈកម្មការត្រួតពិនិត្យសារការី បានសម្រេចជ្រើសរើសបុគ្គលមួយចំនួនជាសារការីតាមរយៈការតែងតាំង ដោយមិនតម្រូវឲ្យពួកគេឆ្លងកាត់ការប្រឡង និងចុះកម្មសិក្សាអ្វីទាំងអស់ ។ ករណីនេះគេហៅថា "**បុគ្គលដែលត្រូវបានតែងតាំងជាពិសេស**(特別任用者)"។ ដោយពួកគេមានអតីតភាពការងារ ជាបុគ្គលិកនៃការិយាល័យកិច្ចការច្បាប់ក្នុងតំបន់ ជាចៅក្រម និងជាជំនួយការព្រះរាជអាជ្ញា ជាដើម។ ចំពោះចំនួនសារការីនៃប្រទេសជប៉ុនវិញ មានការកើនឡើងគួរឲ្យកត់សម្គាល់ ដោយនៅឆ្នាំ១៩៥៥ មានចំនួន២៤៣នាក់ ឆ្នាំ១៩៦៥ មានចំនួន៣៤៧នាក់ ឆ្នាំ១៩៧៥ មានចំនួន៣៩៩នាក់ ឆ្នាំ១៩៨៥ មានចំនួន៤៨៦នាក់ ឆ្នាំ១៩៩០ មានចំនួន៥៣០នាក់ រហូតមកដល់ខែកក្កដាឆ្នាំ២០០៣ មានចំនួន៥២០នាក់។ ក្នុងចំណោមសារការីចំនួន៥២០នាក់នេះ ១៥៤នាក់ជាសារការីដែលត្រូវបានតែងតាំងជាពិសេស ៣៦៦នាក់ជាសារការីដែលមានអតីតភាពការងារជាចៅក្រម ព្រះរាជអាជ្ញា និងមេធាវី[60]។

ក្រោយពីបានស្វែងយល់អំពីប្រវត្តិនៃការកកើតវិជ្ជាជីវៈសារការីរួចមក ជាបន្ទាប់យើងនឹងបង្ហាញអំពីលិខិតដែលធ្វើឡើងដោយសារការី ដោយផ្តោតទៅលើអានុភាពនៃលិខិតដែលធ្វើឡើងដោយសារការី មុននឹងឈានទៅដល់ប្រភេទនៃលិខិត ការបញ្ជាក់លើលិខិតពីសំណាក់សារការី និងតម្លៃសេវារបស់សារការី។

[59] 日本公証人連合会, *日本公証人制度の概要と問題点* [សង្ខេបអំពីប្រព័ន្ធសារការីជប៉ុន និងចំនុចបញ្ហា] , ទំព័រទី២, http://yuigon.usdatashohisha_a_7.pdf (ចូលទស្សនាថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦)។

[60] 日本公証人連合会, *公証制度百年史* [ប្រវត្តិមួយរយឆ្នាំនៃប្រព័ន្ធសារការី] , ទំព័រទី២៣៤។

## ១.២. លិខិតដែលធ្វើឡើងដោយសារការី

លិខិតដែលមានការបញ្ជាក់ (公正証書/Notarized Document) សំដៅទៅលើលិខិតដែលធ្វើឡើងដោយសារការី ដែលទទួលអំណាចក្នុងការធ្វើការបញ្ជាក់តាមបញ្ញត្តិច្បាប់ ដោយមានការពឹងពាក់ពីបុគ្គលឯកជន។ ជាទូទៅ លិខិតដែលធ្វើឡើងដោយមន្ត្រីសាធារណៈត្រូវបានគេហៅថា "**លិខិតសាធារណៈ**" រីឯលិខិតដែលធ្វើឡើងដោយបុគ្គលឯកជន ត្រូវបានគេហៅថា "**លិខិតឯកជន**"។ លិខិតសាធារណៈ ជាលិខិតដែលធ្វើឡើងដោយមន្ត្រីរាជការសារធារណៈ ក្នុងនាមជាតតិយជនអព្យាក្រឹត្យដោយអនុលោមតាមបញ្ញត្តិច្បាប់ និងជាលិខិតដែលគេជឿជាក់ខ្លាំង ដែលគេហៅថា "**លិខិតដែលមានអានុភាពបញ្ជាក់ភាពពិតតាមលក្ខណៈទម្រង់** (形式的証明力)" ។ ក្នុងករណីមានវិវាទអំពីភាពពិតនៃលិខិត ហើយបើលិខិតនោះជាលិខិតសាធារណៈ នោះត្រូវបានគេសន្មតថាជាលិខិតដែលមានភាពពិតខ្លាំងជាងលិខិតឯកជន។ ចំពោះលិខិតដែលមានទម្រង់ដូចជាកិច្ចសន្យាអញ្ញមញ្ញ ដែលតម្រូវឲ្យមានការអនុវត្តកាតព្វកិច្ចទៅវិញទៅមក ហើយត្រូវបានផ្តល់ការបញ្ជាក់ដោយសារការី ព្រមទាំងមានកំណត់អំពីបញ្ញត្តិនៃការអនុវត្តដោយបង្ខំ ករណីមិនអនុវត្តកាតព្វកិច្ច នោះម្ចាស់បំណុលនឹងអាចអនុវត្តដោយបង្ខំដោយផ្ទាល់បានពោលគឺមិនចាំបាច់ត្រូវដាក់ពាក្យសុំទៅតុលាការនោះទេ។ ចំណែកឯពាក្យថា "**អានុភាពអនុវត្ត**" សំដៅទៅលើអនុភាពដែលម្ចាស់បំណុលមានសិទ្ធិអនុវត្តដោយបង្ខំ ក្នុងករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដូចដែលមានបញ្ញត្តិក្នុងកិច្ចសន្យា ហើយលិខិតដែលត្រូវបានបញ្ជាក់ដោយសារការី ហើយមានអនុភាពអនុវត្តដោយបង្ខំនោះគេហៅថា "**លិខិតអនុវត្ត** (執行証書)"។ ជាគោលការណ៍ លិខិតណាមួយត្រូវមានអនុភាពអនុវត្ត លុះត្រាតែត្រូវបានឆ្លងកាត់នីតិវិធីតុលាការ ដោយមានការដាក់ពាក្យសុំដោយដើមបណ្ដឹង។ ករណីដែល**លិខិតអនុវត្ត**អាចយកទៅប្រើប្រាស់បាន ប៉ុន្តែកូនបំណុលមិនមានលទ្ធភាពសងបំណុលនោះ គឺមានចំនួនច្រើនក្នុងប្រទេសជប៉ុន។ ចំពោះសេចក្តីសម្រេចរបស់អាជ្ញាកណ្តាល ឬ មជ្ឈត្តវិនិច្ឆ័យដែលចេញដោយមជ្ឈត្តករក៏មានអនុភាពអនុវត្តដូចទៅនឹងលិខិតដែលធ្វើឡើងដោយសារការីផងដែរ ប៉ុន្តែដាច់ខាតត្រូវតែឆ្លងកាត់នូវនីតិវិធីតុលាការជាមុនសិន ទើបយកទៅអនុវត្តបាន។ ដោយសារតែមូលហេតុនេះហើយ ទើបបានជាលិខិតដែលធ្វើឡើងដោយសារការីត្រូវបានគេឲ្យតម្លៃអំពីភាពពិតនៃលិខិត និងការធានាសុវត្ថិភាពជំនួញក៏ដូចជាសិទ្ធិរបស់ភាគីនីមួយៗខ្លាំងជាលិខិតដែលធ្វើឡើងដោយបុគ្គលដទៃទៀត។

បន្តទៅនេះ យើងនឹងសិក្សាអំពីចំណុចបីសំខាន់ៗគឺៈ ប្រភេទលិខិតដែលធ្វើឡើងដោយសារការី (១.២.១) ការបញ្ជាក់ពីសារការី(១.២.២) និងតម្លៃសេវារបស់សារការី(១.២.៣)។

### ១.២.១.ប្រភេទលិខិតដែលធ្វើឡើងដោយសារការី

សារការីនៃប្រទេសជប៉ុន ផ្តល់ការបញ្ជាក់ ឬ ផ្តល់យថាភូតភាពលើលិខិតចំនួន៣ប្រភេទ គឺ កិច្ចសន្យា(១.២.១.១) សកម្មភាពឯកតោភាគី(១.២.១.២) និងលិខិតដែលត្រូវត្រួតពិនិត្យភាពពិត (១.២.១.៣)។

#### ១.២.១.១.កិច្ចសន្យា (契約に関する公正証書)

ជាគោលការណ៍ លិខិតដែលអាចឲ្យសារការីផ្តល់ការបញ្ជាក់បាននោះមានដូចជា កិច្ចសន្យាលក់-ទិញអចលនវត្ថុ ភតិសន្យា កិច្ចសន្យាខ្ចីបរិភោគ ដែលជាប្រភេទកិច្ចសន្យាអញ្ញមញ្ញ។ បន្ថែមពីលើនេះមានជាអាទិ៍ប្រទានកម្ម ការតំណាង កិច្ចសន្យាម៉ៅការ ដែលសុទ្ធសឹងតែជាកិច្ចសន្យាដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណី ប៉ុន្តែសារការីក៏មានតួនាទីធ្វើលិខិត ដែលមិនមានកំណត់ក្នុងក្រមរដ្ឋប្បវេណីផងដែរ។ នោះគឺកិច្ចសន្យាគ្រប់គ្រងហាងជាលក្ខណៈសាខា (チェーン店経営に関する契約/ Chain Store Management Contract) ។ ទន្ទឹមនឹងផ្តល់ការបញ្ជាក់ភាពត្រឹមត្រូវ និងផ្តល់យថាភូតភាពទៅលើលិខិតតួនាទីដែលសំខាន់បំផុតរបស់សារការីនោះគឺ ត្រួតពិនិត្យមើលអត្ថន័យនៃកិច្ចសន្យានីមួយៗ ដាច់ខាតត្រូវតែជាប្រការដែល គោរពទៅតាមច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា មិនត្រូវផ្ទុយទៅនឹងសណ្តាប់ធ្នាប់សាធារណៈ និងមិនត្រូវធ្វើឡើងដោយជន ដែលខ្វះសមត្ថភាពក្នុងការធ្វើអំពើ។ ពោលគឺធ្វើយ៉ាងណាមិនឲ្យលិខិតនោះប្រឈមនឹងការលុបចោល ឬ មោឃភាពជាច់ខាត។ នៅប្រទេសជប៉ុន ច្បាប់ដែលបញ្ញត្តិផ្តល់អានុភាពដល់លិខិត ដែលធ្វើឡើងដោយសារការីមានការកើតឡើងគួរឲ្យកត់សម្គាល់ ជាក់ស្តែងច្បាប់ស្តីពីភតិសន្យាលើដី និងផ្ទះ ដែលត្រូវបានប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០០០ បានបង្កើតនូវប្រព័ន្ធថ្មីមួយគឺ“ប្រព័ន្ធភតិសន្យាលើអាគារដោយមានកាលកំណត់។ ដោយច្បាប់ខាងលើអនុញ្ញាតតែចំពោះលិខិតដែលធ្វើឡើងដោយសារការីមួយគត់ ដែលអាចកំណត់អំពីការបញ្ចប់ភតិសន្យាដោយយោងទៅតាមពេលវេលាដែលកំណត់ក្នុងកិច្ចសន្យា ហើយមិនអាចបន្តរយៈពេលនៃកិច្ចសន្យាបានទេ។

មួយវិញទៀត នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០០០ របបថ្មីមួយបានប្រកាសឲ្យប្រើប្រាស់គឺ “**របបអាណាព្យាបាលសម្រាប់នីតិជន** (成年後見人)” ។ មូលហេតុដែលបង្កើតរបបនេះឡើង គឺដោយសារតែនៅប្រទេសជប៉ុន កំពុងប្រឈមនឹងសង្គមដែលមានមនុស្សចាស់កើនឡើង ហើយចំនួនកំណើតមានការថយចុះ ដូចនេះដើម្បីផ្តល់ឲ្យប្រជាពលរដ្ឋជប៉ុន ជាពិសេសជនចាស់ជរាទាំងអស់ឲ្យទទួលបាននូវការមើលថែទាំយ៉ាងយកចិត្តទុកដាក់ ពោលវាគឺជាផ្នែកមួយនៃ “**សុខមាលភាពសង្គមចំពោះជនពិការ ឬ ជនចាស់ជរា**”។ បន្ថែមពីនេះ ក៏មានរបបមួយទៀតផងដែរគឺ “**របបអាណាព្យាបាលតាមការព្រមព្រៀង** (任意後見)” ។ របបនេះបង្កើតឡើងសម្រាប់បុគ្គលស្ថិតក្នុងស្ថានភាពដែលមានសមត្ថភាពក្នុងការ វិនិច្ឆ័យ

មិនគ្រប់គ្រាន់ និងសម្រាប់បុគ្គលដែលមានស្មារតីវង្វេងវង្វាន់ ដែលមុននឹងស្ថិតក្នុងស្ថានភាពបែបនេះ ពួកគេត្រូវជ្រើសរើសអ្នកអាណាព្យាបាល ដើម្បីមើលថែរក្សាសុខភាព ផ្គត់ផ្គង់ជីវភាព គ្រប់គ្រងហិរញ្ញវត្ថុ និងធ្វើកិច្ចការដែលចាំបាច់ដទៃផ្សេងទៀត។ ដូចនេះ ដើម្បីឲ្យអ្នកអាណាព្យាបាលរបស់ខ្លួន អនុវត្តមុខងារឲ្យបានពេញលេញ និងស្របតាមបញ្ញត្តិច្បាប់ ព្រមទាំងដើម្បីទទួលបានតម្លៃតបស្នងក្នុងនាមជាអ្នកអាណាព្យាបាលតាមការព្រមព្រៀង ភាគីទាំងពីរត្រូវបង្កើតកិច្ចសន្យា ហើយជាកិច្ចសន្យាដែលត្រូវចុះហត្ថលេខាដោយភាគីទាំងពីរក្នុងនាមជាលិខិតឯកជន និង បញ្ជាក់ពីភាពត្រឹមត្រូវដោយសារការី។ បើមិនដូច្នេះទេ កិច្ចសន្យានោះនឹងមិនមានអនុភាពគតិយុត្តឡើយ។

### ១.២.១.២.សកម្មភាពឯកតោភាគី (単独行為に関する公正証書)

សកម្មភាពឯកតោភាគី ឬ កិច្ចឯកតោភាគី សំដៅទៅលើសកម្មភាពដែលបង្កើត កែប្រែ ឬ រំលត់នូវសិទ្ធិ ឬកាតព្វកិច្ច ដោយការបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យដោយភាគីតែម្ខាង ដោយអនុវត្តសិទ្ធិដែលបានទទួលតាមកិច្ចសន្យា ឬ តាមបញ្ញត្តិនៃច្បាប់[61]។ កិច្ចឯកតោភាគីខុសអំពីកិច្ចសន្យាត្រង់ថា កិច្ចសន្យាចាំបាច់នូវការបង្ហាញឆន្ទៈតាមការព្រមព្រៀងរវាងគូភាគី រីឯកិច្ចឯកតោភាគីជាលិខិតដែលមានការបង្ហាញឆន្ទៈតែភាគីតែម្ខាង។ សារការី ក៏មានតួនាទីក្នុងការធ្វើលិខិតដែលមានទម្រង់ជាកិច្ចឯកតោភាគីផងដែរ។ ឧទាហរណ៍៖ មតកសាសន៍ ។

មតកសាសន៍ សំដៅទៅលើលិខិតបណ្តាំដែលបុគ្គលម្នាក់ បានធ្វើឡើងតាមទម្រង់ដែលកំណត់ដោយច្បាប់ ដើម្បីសំដែងឆន្ទៈចុងក្រោយអំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួន ជាអាទិ៍បន្ទាប់ពីមរណភាព[62]។ ទម្រង់នៃមតកសាសន៍ភាគច្រើនដែលមតកជនតែងតែធ្វើនោះគឺ មតកសាសន៍ដែលសរសេរដោយខ្លួនឯង និងមតកសាសន៍ដែលធ្វើឡើងដោយសារការី។ ចំពោះទម្រង់មតកសាសន៍ដែលសរសេរដោយខ្លួនឯង គឺតម្រូវឲ្យខ្លឹមសារនៃមតកសាសន៍នោះអនុលោមទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។ នៅប្រទេសជប៉ុន ភាគច្រើននៃមតកសាសន៍ដែលសរសេរដោយខ្លួនឯងតែងតែជួបផលវិបាកដោយមូលហេតុដូចជា ត្រូវបានមោឃភាពដោយមូលហេតុមិនស្របតាមទម្រង់ ឬភាពពិតរបស់មតកសាសន៍ ជាដើម។ ផលវិបាកទាំងនេះ ជាហេតុធ្វើឲ្យសន្តតិជនបាត់បង់ផលប្រយោជន៍ និងកើតមានវិវាទរវាងសន្តតិជន និងសន្តតិជន។ បើសិនជាមានមូលហេតុ

[61]លេខ១៩១ នៃសន្ទានុក្រមផ្នែករដ្ឋប្បវេណី ដកស្រង់ពី«សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី» ដែលត្រូវបានរៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រីនៅឆ្នាំ២០០៧។

[62]លេខ១១១៨ នៃសន្ទានុក្រមផ្នែករដ្ឋប្បវេណី ដកស្រង់ពី«សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី» ដែលត្រូវបានរៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រីនៅឆ្នាំ២០០៧។

ណាមួយដូចបានរៀបរាប់ខាងលើ ចាំបាច់ត្រូវតែឆ្លងកាត់នីតិវិធីរបស់តុលាការគ្រួសារ ដើម្បីឲ្យតុលាការនេះបញ្ជាក់ពីភាពពិត ឬ ភាពត្រឹមត្រូវនៃទម្រង់របស់មតកសាសន៍នោះ។ ផ្ទុយទៅវិញ បើសិនជាមតកសាសន៍នោះត្រូវបានធ្វើឡើងដោយសារការី ភាគរយតិចបំផុតដែលនឹងកើតមានបញ្ហាខាងលើ ព្រោះលិខិតនោះជាលិខិតដែលធ្វើឡើងតាមទម្រង់ច្បាប់ ដោយតតិយជនដែលមានភាពអព្យាក្រឹត្យ និងយុត្តិធម៌ ហើយវាជាលិខិតដែលមានសុវត្ថិភាពគតិយុត្ត និងភាពដែលអាចជឿទុកចិត្តបាន ខ្លាំងជាងមតកសាសន៍ដែលសរសេរដោយខ្លួនឯង ជាពិសេសមិនចាំបាច់ឆ្លងកាត់នីតិវិធីត្រួតពិនិត្យពីសំណាក់តុលាការគ្រួសារនោះទេ។

នៅប្រទេសជប៉ុន វិវាទដែលទាក់ទងនឹងការស្នងមតិក មានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ បើយើងមើលទៅលើចំនួនករណី ដែលអាជ្ញាកណ្តាលដោះស្រាយវិវាទ ពាក់ព័ន្ធនឹងការបែងចែកមតិកដែលមិនបានសម្រេច នឹងត្រូវបញ្ជូនមកតុលាការគ្រួសារ ឃើញថា ក្នុងដើមឆ្នាំ២០០៥ មានចំនួន ៧០៤៧ (ប្រាំពីរពាន់សែសិបប្រាំពីរ) ករណី ក្នុងចុងឆ្នាំ២០០៥ មានចំនួន ១០.១៣០(មួយម៉ឺនមួយរយសាមសិប)ករណី។ ដែលនេះ មានការកើនឡើងប្រមាណ៣០ភាគរយក្នុង១ឆ្នាំ២០០៥។ ដោយឡែកពីនេះ នៅប្រទេសជប៉ុននាពេលអនាគត បានពិចារណាដល់ជនពិបាកដែលមិនអាចស្តាប់ឮ ឬនិយាយបាន(ជនថ្លង់ និង គ) ដែលមិនអាចធ្វើមតកសាសន៍បាន។ ផលវិបាកចំពោះជនទាំងពីរប្រភេទនេះគឺ ពិបាកក្នុងការធ្វើមតកសាសន៍ដែលធ្វើឡើងដោយសារការី ដោយនៅពេលធ្វើមតកសាសន៍តម្រូវឲ្យសារការីទំនាក់ទំនងជាមួយបុគ្គលនោះតាមរយៈការនិយាយ រួចយកពាក្យពេចន៍ទាំងនោះមកសរសេរជាឃ្លាប្រយោគនីមួយៗ ទើបបង្កើតបានជាមតកសាសន៍មួយដែលស្របតាមទម្រង់ និងមានអានុភាពគតិយុត្ត។ បន្ទាប់ពីធ្វើហើយសារការីត្រូវអានអត្ថន័យដែលបានសរសេររួចដើម្បីបញ្ជាក់ឲ្យបានច្បាស់អំពីគោលបំណងនីមួយៗ របស់មតកជនមុនទទួលមរណភាព។ ដើម្បីដោះស្រាយបញ្ហាខាងលើនេះ នាយកដ្ឋានរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ក៏បានសម្រេចធ្វើវិសោធនកម្មក្រមរដ្ឋប្បវេណី ហើយប្រកាសឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី០៨ ខែមករា ឆ្នាំ១៩៩៩។ មាត្រា ៩៦៩ និងមាត្រា៩៧២នៃក្រមរដ្ឋប្បវេណីប្រទេសជប៉ុនត្រូវធ្វើវិសោធនកម្ម ដោយត្រូវបន្ថែមអ្នកបកប្រែភាសាកាយវិការចំពោះជនពិការសរីរាង្គណាមួយដែលមានបំណងធ្វើមតកសាសន៍ដែលមានការបញ្ជាក់ពីសារការី[63]។

[63]法務省民事局,*民法の一部を改正する法律などの概要*, [សង្ខេបអំពីផ្នែកដែលត្រូវបានធ្វើវិសោធនកម្មក្នុងក្រមរដ្ឋប្បវេណី], （法務省,១៩៩៩）, ៤៦, (http://www.ipss.go.jppublicationjshiryouno.13datashiryousyakaifukushi782.pdf) (ចូលទស្សនាថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦) ។

#### ១.២.១.៣.លិខិតដែលត្រូវត្រួតពិនិត្យភាពពិត (事実実験公正証書)

លិខិតដែលពិពណ៌នាអំពីលទ្ធផល នៃការត្រួតពិនិត្យពីសំណាក់សារការីទៅលើភាពពិតដែលចាំបាច់ ទាក់ទងនឹងសិទ្ធិ ឬករណីយកិច្ចណាមួយ តាមកំណត់ច្បាប់គេហៅថា **លិខិតដែលត្រូវត្រួតពិនិត្យភាពពិតដោយសារការី**។ ការត្រួតពិនិត្យពីសំណាក់សារការី គឺជាទំនួលខុសត្រូវដែលសារការីត្រូវប្រុងប្រយ័ត្នជាងគេក្នុងការបំពេញមុខងារ រហូតដល់មានទស្សនៈមួយលើកឡើងថា "**សារការីត្រូវប្រើវិញ្ញាណទាំង៥ដើម្បីរកឲ្យឃើញនូវលទ្ធផល**" ។

ជាឧទាហរណ៍៖ ចំពោះការត្រួតពិនិត្យអំពីលក្ខខណ្ឌរបស់ដីកន្លែងណាមួយ ដែលតម្រូវឲ្យពិនិត្យមើលអំពីព្រំប្រទល់នៃដីឲ្យបានច្បាស់លាស់ ហេតុនេះសារការីត្រូវទៅដល់ទីតាំងដីជាក់ស្តែងដើម្បីធ្វើការត្រួតពិនិត្យ និងចេញជាលិខិតដែលមានអានុភាពគតិយុត្ត ក្នុងគោលដៅអាចឲ្យកម្មសិទ្ធិករយកដីនោះទៅចាត់ចែង ប្រកបដោយជំនឿទុកចិត្ត។ ដូចនេះលិខិតដែលធ្វើឡើងដោយសារការីអាចនិយាយបានថាជាលិខិតដែលមានអត្ថន័យ បញ្ញត្តិនូវគោលបំណងបង្ការវិវាទនាពេលអនាគត និងជាមធ្យោបាយរក្សាទុកភស្តុតាងមួយដ៏មាន សុវត្ថិភាពផងដែរ។

### ១.២.២. ការបញ្ជាក់ពីសារការី

**ការបញ្ជាក់** សំដៅទៅលើការផ្តល់ភស្តុតាងពីស្ថាប័នសាធារណៈ ទៅលើសកម្មភាព ឬ លិខិតណាមួយថាធ្វើឡើងដោយស្របទៅតាមទម្រង់ ឬ នីតិវិធីច្បាប់។ ចំពោះសារការីធ្វើការបញ្ជាក់លើលិខិតចំនួន២ប្រភេទដូចគឺ ការបញ្ជាក់លើលក្ខន្តិកៈក្រុមហ៊ុន(១.២.២.១) និង ការបញ្ជាក់លើលិខិតឯកជន (១.២.២.២)។

#### ១.២.២.១.ការបញ្ជាក់លើលក្ខន្តិកៈក្រុមហ៊ុន

នៅពេលបង្កើតក្រុមហ៊ុនមូលធន ឬ ក្រុមហ៊ុនសហកម្មសិទ្ធជាដើម ក្រុមហ៊ុនត្រូវមានលក្ខន្តិកៈរបស់ក្រុមហ៊ុន ដោយលក្ខន្តិកៈទាំងនោះ ដាច់ខាតត្រូវតែមានការបញ្ជាក់ពីសារការី។ ចំពោះមន្ទីរសារការីដែលមានសមត្ថកិច្ចផ្តល់ការបញ្ជាក់នេះ គឺត្រូវធ្វើទៅតាមទីតាំងនៃការិយាល័យកណ្តាល ឬ សាខាកណ្តាលនៃក្រុមហ៊ុន ឬ នីតិបុគ្គលណាមួយនោះ នៅក្នុងតំបន់រដ្ឋបាលនីមួយៗ។

**<u>ឧទាហរណ៍</u>**៖ ក្រុមហ៊ុនមូលធន **ក** មានគម្រោងដំណើរការនៅក្នុងតំបន់ក្យូតុ ដូចនេះក្រុមហ៊ុននោះត្រូវតែបង្កើតនូវលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងដោយមានការបញ្ជាក់ពីមន្ទីរសារការីស្ថិតក្នុងតំបន់ក្យូតុ។

#### **១.២.២.២.ការបញ្ជាក់លើលិខិតឯកជន**

ការបញ្ជាក់លើលិខិតឯកជន គឺជាការបញ្ជាក់លើឈ្មោះ ហត្ថលេខា ឬ ត្រា របស់ភាគីក្នុងកិច្ចសន្យា។ សារការី មានតួនាទីធានាថាកិច្ចសន្យាដែលគ្រប់ភាគីបានសរសេរឈ្មោះ ចុះហត្ថលេខា ឬ បោះត្រា គឺជាឈ្មោះ ហត្ថលេខា និងជាត្រារបស់ភាគីនោះយ៉ាងពិតប្រាកដ។ ដើម្បីឲ្យលិខិតឯកជនក្លាយជាលិខិតដែលមានការបញ្ជាក់ពីសារការី លុះត្រាតែលិខិតនោះ ត្រូវបានធ្វើឡើងដោយមានការសរសេរឈ្មោះ ចុះហត្ថលេខ ឬ បោះត្រា ពីសំណាក់គូភាគីក្នុងកិច្ចសន្យាដោយឆន្ទៈរបស់ខ្លួនផ្ទាល់ និងទទួលស្គាល់ពីអត្ថិភាពនៃឈ្មោះ ហត្ថលេខា ព្រមទាំងត្រានោះផងដែរ។ ជាពិសេសលិខិតនោះដាច់ខាតត្រូវតែធ្វើនៅចំពោះមុខសារការី។ ប៉ុន្តែសារការីក៏មានតួនាទីផ្តល់ការបញ្ជាក់ពីភាពពិតនៃឈ្មោះ ហត្ថលេខា ឬ ត្រា ទៅលើកិច្ចសន្យាណាមួយផងដែរ បើសិនជាមានការស្នើសុំឲ្យត្រួតពិនិត្យពីសំណាក់គូភាគីនៃកិច្ចសន្យា។ នៅពេលដែលលិខិតនោះត្រូវបានផ្តល់ការបញ្ជាក់ពីសារការីថា ឈ្មោះ ហត្ថលេខា ឬ ត្រា ជារបស់គូភាគីនៃកិច្ចសន្យាពិតប្រាកដមែន ជំនឿជាក់ក្នុងការប្រើប្រាស់លិខិតនោះក៏កាន់តែខ្ពស់ឡើង ជាពិសេសគឺធានាដល់សុវត្ថិភាពជំនួញ។ លិខិតឯកជនដែលសារការីធ្វើការបញ្ជាក់ អាចធ្វើលើលិខិតជាភាសាជប៉ុន និងជាភាសាបរទេសផងដែរ។ នៅប្រទេសជប៉ុន ត្រាឈ្មោះរបស់រូបវន្តបុគ្គល និងនីតិបុគ្គលទាមទារឲ្យមានការចុះបញ្ជីជាចាំបាច់ ដែលត្រូវបានគេហៅថា **ការចុះបញ្ជីត្រាជាផ្លូវការ** (印鑑登録証明/ **Certification of official registration of a seal**) ។ ប៉ុន្តែ ជនបរទេសដែលរស់នៅក្នុងប្រទេសជប៉ុន គឺមិនមានត្រាឈ្មោះនោះទេ ក្នុងករណីនេះបើសិនជាជនបរទេសនោះមានបំណងបើកក្រុមហ៊ុន សហគ្រាស ក្នុងគោលបំណងអាជីវកម្មណាមួយ ចាំបាច់ត្រូវតែមានការបញ្ជាក់ឲ្យបានច្បាស់លាស់ ពីប្រវត្តិរូបរបស់បុគ្គលនោះដើម្បីចុះកិច្ចសន្យា ឬ អនុវត្តសកម្មភាពគតិយុត្តផ្សេងៗ។ ដូចនេះ ការបញ្ជាក់លើលិខិតឯកជនដោយសារការី ជាតួនាទីសំខាន់បំផុត ក្នុងគោលដៅនៃការធានាជំនឿជាក់ជាសាធារណៈ ដល់ប្រជាពលរដ្ឋជប៉ុនទាំងមូល និងដើម្បីសុវត្ថិភាពជំនួញ។

### **១.២.៣.តម្លៃសេវារបស់សារការី**

ក្នុងផ្នែកនេះយើងនឹងសិក្សាចំនួន៤ចំនុចគឺសញ្ញាណទូទៅនៃប្រព័ន្ធកម្រៃជើងសារ (១.២.៣.១) ប្រភេទនៃកម្រៃជើងសារ(១.២.៣.២) ប្រាក់កម្រៃជើងសារមូលដ្ឋានក្នុងការធ្វើលិខិតពាក់ព័ន្ធនឹងកិច្ចសន្យា(១.២.៣.៣) និងវិធីគណនាប្រាក់កម្រៃជើងសារចំពោះកិច្ចសន្យា ឬ កិច្ចឯកតោភាគី (១.២.៣.៤)។

### ១.២.៣.១.សញ្ញាណទូទៅនៃប្រព័ន្ធកម្រៃជើងសារ

ប្រាក់ចំណូល ឬ សេវារបស់សារការី គឺជាកម្រៃជើងសារដែលទទួលបាននៅពេលធ្វើការបញ្ជាក់ និងផ្តល់យថាភូតភាពលើលិខិតឯកជនណាមួយឲ្យមានអនុភាពគតិយុត្ត។ កម្រៃជើងសាររបស់សារការីមានកំណត់ក្នុង**អនុក្រឹត្យស្តីអំពីកម្រៃជើងសាររបស់សារការី**(公証人手数料令) ដោយនៅក្នុងអនុក្រឹត្យនេះមានកំណត់អំពីកម្រៃជើងសារ ការចំណាយថ្លៃធ្វើដំណើរ ធនលាភរបស់សារការីជាដើម។ អនុលោមតាមច្បាប់ស្តីពីពន្ធលើតែម ចំពោះកិច្ចសន្យាខ្ចីបរិភោគ ភតិសន្យាលើអចលនវត្ថុ(ដីធ្លី) កិច្ចសន្យាលក់-ទិញអចលនវត្ថុ(ដីធ្លី) ដែលនឹងផ្តល់យថាភូតភាព ចាំបាច់ត្រូវតែមានបិទតែមភ្ជាប់លើលិខិតទាំងអស់នោះ ប៉ុន្តែចំពោះប្រាក់កម្រៃជើងសាររបស់សារការី មិនត្រូវបានកាត់ពន្ធនោះទេ។ ចំណែកឯការពិភាក្សាជាមួយសារការីពាក់ព័ន្ធនឹងកិច្ចការផ្សេងៗ គឺមិនយកកម្រៃអ្វីទាំងអស់[64]។

### ១.២.៣.២.ប្រភេទនៃកម្រៃជើងសារ

នៅក្នុងអនុក្រឹត្យស្តីអំពីកម្រៃជើងសាររបស់សារការី បានបញ្ញត្តិយ៉ាងលម្អិតអំពីកម្រៃជើងសារព្រមទាំងបានបែងចែកកម្រៃជា៤ប្រភេទគឺ ទី១ៈកម្រៃជើងសារក្នុងការធ្វើលិខិតពាក់ព័ន្ធនឹងកិច្ចសន្យា ទី២ៈកម្រៃជើងសារក្នុងការធ្វើលិខិតមិនមែនជាកិច្ចសន្យា ទី៣ៈកម្រៃជើងសារក្នុងការទទួលស្គាល់លើលិខិតណាមួយ និងទី៤ៈកម្រៃជើងសារក្នុងការបំពេញការងារផ្សេងៗទៀត។

នៅក្នុងអនុក្រឹត្យដដែល ក៏បានបញ្ញត្តិអំពីវិធីគណនាកម្រៃជើងសារផងដែរ គឺដោយបានបែងចែកជា៣គឺ ទី១ៈការគណនាដោយយោងលើតម្លៃនៃគោលបំណង ទី២ៈការគណនាដោយយោងលើពេលវេលាដែលចាំបាច់ និងទី៣ៈការគណនាដោយយោងលើចំនួនក្រដាសនៃលិខិតដែលត្រូវ ផ្តល់ការបញ្ជាក់ ឬ ផ្តល់យថាភូតភាព ជាដើម[65]។

### ១.២.៣.៣.ប្រាក់កម្រៃជើងសារមូលដ្ឋានក្នុងការធ្វើលិខិតពាក់ព័ន្ធនឹងកិច្ចសន្យា

កម្រៃជើងសារក្នុងការធ្វើលិខិតពាក់ព័ន្ធនឹងកិច្ចសន្យា និងសកម្មភាពគតិយុត្តដទៃទៀត។ ជាគោលការណ៍ គឺកំណត់ទៅតាមតម្លៃនៃគោលបំណង[66]។ តម្លៃនៃគោលបំណង សំដៅទៅលើតម្លៃដែលមានកំណត់ក្នុងកិច្ចសន្យា ឬ សកម្មភាពគតិយុត្ត ដែលសារការីផ្តល់ការបញ្ជាក់ ឬ ផ្តល់យថាភូត

[64] 日本公証人連合会、*手数料* [កម្រៃជើងសារ], http://www.kouseishousho.jp/tesuuryou.html (ចូលទស្សនាថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៦)។

[65] 公証人, *手数料* [កម្រៃជើងសារ], http://www.koshonin.com/tesuuryou.html(ចូលទស្សនាថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៦)។

[66] មាត្រា៩នៃអនុក្រឹត្យស្តីអំពីប្រាក់កម្រៃជើងសាររបស់សារការីនៃប្រទេសជប៉ុន។

ភាព ហើយតម្លៃនៃគោលបំណងនេះផងដែរ ត្រូវគណនាពីពេលដែលសារកាវីចាប់ផ្តើមកិច្ចការរបស់ខ្លួនលើលិខិតទាំងនោះ។

| តម្លៃនៃគោលបំណង | ប្រាក់កម្រៃជើងសារ |
|---|---|
| ក្រោម១០០.០០០.០០(មួយរយម៉ឺន)យ៉េន | ៥០០០(ប្រាំពាន់)យ៉េន |
| លើស១០០.០០០.០០(មួយរយម៉ឺន)យ៉េន ក្រោម២០០.០០០.០០(ពីររយម៉ឺន)យ៉េន | ៧០០០(ប្រាំពីរពាន់)យ៉េន |
| លើស២០០.០០០.០០(ពីររយម៉ឺន)យ៉េន ក្រោម៥០០.០០០.០០(ប្រាំរយម៉ឺន)យ៉េន | ១១.០០០(មួយម៉ឺនមួយពាន់)យ៉េន |
| លើស៥០០.០០០.០០(ប្រាំរយម៉ឺន)យ៉េន ក្រោម១០០០.០០០.០០(មួយពាន់ម៉ឺន)យ៉េន | ១៧.០០០(មួយម៉ឺនប្រាំពីរពាន់)យ៉េន |
| លើស១០០០.០០០.០០(មួយពាន់ម៉ឺន)យ៉េន ក្រោម៣០០០.០០០.០០(បីពាន់ម៉ឺន)យ៉េន | ២៣.០០០(ពីរម៉ឺនបីពាន់)យ៉េន |
| លើស៣០០០.០០០.០០(បីពាន់ម៉ឺន)យ៉េន ក្រោម៥០០០.០០០.០០(ប្រាំពាន់ម៉ឺន)យ៉េន | ២៩.០០០(ពីរម៉ឺនប្រាំបួនពាន់)យ៉េន |
| លើស៥០០០.០០០.០០(ប្រាំពាន់ម៉ឺន)យ៉េន ក្រោម១០០.០០០.០០០(មួយរយលាន)យ៉េន | ៤៣.០០០(បួនម៉ឺនបីពាន់)យ៉េន |
| លើស១០០.០០០.០០០(មួយរយលាន)យ៉េន ក្រោម៣០០.០០០.០០០(បីរយលាន)យ៉េន | ៤៣.០០០(បួនម៉ឺនបីពាន់)យ៉េន ប៉ុន្តែបើតម្លៃនៃគោលបំណងបន្ថែម៥០០០.០០០.០០(ប្រាំពាន់ម៉ឺន)យ៉េន នោះកម្រៃជើងសារត្រូវបូកបន្ថែម១៣.០០០(មួយម៉ឺនបីពាន់)យ៉េន |
| លើស៣០០.០០០.០០០(បីរយលាន)យ៉េន ក្រោម១០០០.០០០.០០០(មួយពាន់លាន)យ៉េន | ៩៥.០០០(ប្រាំបួនម៉ឺនប្រាំពាន់)យ៉េន ប៉ុន្តែបើតម្លៃនៃគោលបំណងបន្ថែម៥០០០.០០០.០០(ប្រាំពាន់ម៉ឺន)យ៉េន នោះកម្រៃជើងសារត្រូវបូកបន្ថែម១១.០០០(មួយម៉ឺនមួយពាន់)យ៉េន |
| លើស១០០០.០០០.០០០(មួយពាន់លាន)យ៉េន | ២៤៩.០០០(ម្ភៃបួនម៉ឺនប្រាំបួនពាន់)យ៉េន ប៉ុន្តែបើតម្លៃនៃគោលបំណងបន្ថែម៥០០០.០០០.០០(ប្រាំពាន់ម៉ឺន)យ៉េន នោះកម្រៃជើងសារត្រូវបូកបន្ថែម៨.០០០(ប្រាំបីពាន់)យ៉េន |

- ចំពោះកិច្ចសន្យាដែលមានភាគីតែម្ខាងត្រូវអនុវត្តកាតព្វកិច្ច ដូចជា ប្រទានកម្មជាដើម ភាគីតែម្ខាងនោះ ជាអ្នកទទួលបន្ទុកលើតម្លៃនៃគោលបំណង។ ចំណែកឯកិច្ចសន្យា ដែលមានភាគីចាប់ពី

ពីរនាក់ឡើងទៅត្រូវអនុវត្តកាតព្វកិច្ច ដូចជា កិច្ចសន្យាលក់-ទិញ ឬ ភតិសន្យាជាដើម ភាគីទាំងសងខាងជាអ្នកទទួលបន្ទុកលើតម្លៃនៃគោលបំណង។

- ចំពោះសកម្មភាពគតិយុត្តច្រើន ដែលត្រូវកំណត់ក្នុងលិខិតតែមួយ ប្រាក់កម្រៃជើងសារត្រូវគណនាដោយធ្វើការបែងចែកទៅតាមសកម្មភាពគតិយុត្តនីមួយៗ ទើបបូកបញ្ចូលគ្នាហើយក្លាយជាប្រាក់កម្រៃជើងសារសរុបក្នុងលិខិតនោះ។ ប៉ុន្តែ ក្នុងករណីដែលសកម្មភាពគតិយុត្តនោះមានទំនាក់ទំនងគ្នា **<u>ឧទាហរណ៍៖</u>** ករណីដែលភតិសន្យាមានភ្ជាប់ជាមួយនឹងកិច្ចសន្យាធានា ហើយបានសរសេរនៅក្នុងលិខិតតែមួយ ចំពោះកម្រៃជើងសារនៃកិច្ចសន្យាធានានោះមិនត្រូវបានគណនាទេ ពោលគឺគណនាតែតម្លៃនៃកម្រៃជើងសាររបស់ភតិសន្យា ដែលជាកិច្ចសន្យាគោលតែប៉ុណ្ណោះ[67]។
- ចំពោះកិច្ចសន្យាដែលមិនអាចគណនាតម្លៃនៃគោលបំណង ដូចជាកិច្ចសន្យាធ្វើជាអាណាព្យាបាលសម្រាប់អនីតិជន ជាករណីលើកលែង គឺគេកំណត់កម្រៃជើងសារចំនួន៥០០(ប្រាំរយ)យ៉េន[68]។
- ការគណនាកម្រៃជើងសារ ដោយយោងលើចំនួនក្រដាសនៃលិខិតដែលត្រូវធ្វើការបញ្ជាក់ ឬ ការផ្តល់យថាភូតភាព ៖ វិធីគណនាចំនួនក្រដាសនេះ ត្រូវបានកំណត់ដោយអនុក្រឹត្យរបស់ក្រសួងយុត្តិធម៌។ ដោយមិនគិតកម្រៃជើងសារទេ ក្នុងករណីដែលក្រដានមានត្រឹម៤សន្លឹក ករណីលើស៤សន្លឹក គឺត្រូវគណនាក្នុង១សន្លឹក២៥០(ពីររយហាសិប)យ៉េន[69]។

### ១.២.៣.៤.វិធីគណនាប្រាក់កម្រៃជើងសារលើកិច្ចសន្យាមួយចំនួន

ដើម្បីស្វែងយល់កាន់តែច្បាស់ អំពីវិធីគណនាកម្រៃជើងសារសារការីរបស់ប្រទេសជប៉ុន យើងខ្ញុំសូមលើកយកប្រភេទនៃកិច្ចសន្យាមួយចំនួន មកបង្ហាញដោយភ្ជាប់ជាមួយនឹងឧទាហរណ៍មកបង្ហាញ។ ក្នុងនោះមានដូចជា កិច្ចសន្យាលក់-ទិញ (១.២.៣.៤.១) ភតិសន្យាលើអាគារ (១.២.៣.៤.២) កិច្ចសន្យាខ្ចីបរិភោគ(១.២.៣.៤.៣) កិច្ចសន្យាលែងលះ(១.២.៣.៤.៤) និងមតកសាសន៍ (១.២.៣.៤.៥)។

#### ១.២.៣.៤.១.កិច្ចសន្យាលក់-ទិញ

ការលក់-ទិញ សំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាងហៅថា អ្នកលក់មានករណីយកិច្ចត្រូវផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិ ឲ្យទៅភាគីម្ខាងទៀតហៅថាអ្នកទិញ ហើយអ្នក

[67]មាត្រា២៣ នៃអនុក្រឹត្យស្តីអំពីកម្រៃជើងសាររបស់សារការីនៃប្រទេសជប៉ុន។
[68]មាត្រា១៦ នៃអនុក្រឹត្យស្តីអំពីកម្រៃជើងសាររបស់សារការីនៃប្រទេសជប៉ុន
[69]មាត្រា២៥ នៃអនុក្រឹត្យស្តីអំពីកម្រៃជើងសាររបស់សារការីនៃប្រទេសជប៉ុន

ទិញមានករណីយកិច្ចត្រូវចេញថ្លៃជាប្រាក់ឲ្យអ្នកលក់ [70] ។ ក្នុងករណីនេះតម្លៃនៃគោលបំណងត្រូវគណនាពីរដងនៃថ្លៃលក់-ទិញ [71] ។ មូលហេតុដែលតម្លៃនៃគោលបំណងត្រូវគណនាពីរដងនៃថ្លៃលក់-ទិញ ពីព្រោះវាជាប្រភេទនៃកិច្ចសន្យាអញ្ញមញ្ញ ដែលភាគីទាំងសងខាងនៃកិច្ចសន្យាត្រូវមានកាតព្វកិច្ចគតិយុត្តចំពោះគ្នាទៅវិញទៅមក។

**<u>ឧទាហរណ៍៖</u> ក** បានធ្វើកិច្ចសន្យាលក់ទិញដីដែលមានតម្លៃ ៥០០០.០០០.០០ (ប្រាំពាន់ម៉ឺន) យ៉េន ពី **ខ**។ ក្នុងករណីនេះ ៥០០០.០០០.០០ (ប្រាំពាន់ម៉ឺន) យ៉េន ជាតម្លៃនៃគោលបំណងដែលត្រូវក្លាយជាកម្មវត្ថុនៃការគណនាប្រាក់កម្រៃជើងសារ បើសិនជា ក និង ខ បានព្រមព្រៀងធ្វើកិច្ចសន្យាលក់-ទិញជាលិខិតយថាភូតដោយមានការបញ្ជាក់ពីសារការី។ ដូចនេះ តម្លៃនៃគោលបំណង គឺត្រូវយក ៥០០០.០០០.០០ x ២= ១០០.០០០.០០០(មួយរយលាន)យ៉េន ហើយដោយយោងតាមតារាងខាងលើ ករណីដែលតម្លៃនៃគោលបំណងមានចំនួន១០០.០០០.០០០(មួយរយលាន)យ៉េន នោះប្រាក់កម្រៃជើងសារមានចំនួន ៤៣.០០០(បួនម៉ឺនបីពាន់)យ៉េន។

### ១.២.៣.៤.២.ភតិសន្យាលើអគារ

ភតិសន្យា [72] សំដៅលើកិច្ចសន្យាមួយដែលភាគីម្ខាងឲ្យភាគីម្ខាងទៀតប្រើប្រាស់ និងអាស្រ័យផលពីវត្ថុណាមួយដោយយកថ្លៃ ហើយវត្ថុដែលជាកម្មវត្ថុនៃភតិសន្យាមានចលនវត្ថុ និងអចលនវត្ថុ[73]។

---

[70]មាត្រា៥១៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជានៃប្រទេសជប៉ុន

[71]មាត្រា១១ វាក្យខណ្ឌ១ នៃអនុក្រឹត្យស្តីអំពីកម្រៃជើងសាររបស់សារការីនៃប្រទេសជប៉ុន

[72]មាត្រា៥៩៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

[73]យើងខ្ញុំសូមលើកយកនិយមន័យនៃចលនវត្ថុ(Movable Estate) និងអចលនវត្ថុ(Immovable/Real Estate) ដែលមានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណី និងច្បាប់ភូមិបាលឆ្នាំ២០០១មកបង្ហាញ៖ **ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧** មាត្រា១២០-ចលនវត្ថុ និងអចលនវត្ថុ៖ ១.វត្ថុត្រូវបានចែកជាចលនវត្ថុ និងអចលនវត្ថុ។ ២.អចលនវត្ថុសំដៅទៅលើ ដីធ្លី វត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជាអាគារ សំណង់ ដំណាំ រុក្ខជាតិ ជាអាទ៍។ ៣. ចលនវត្ថុ សំដៅទៅលើវត្ថុក្រៅពីអចលនវត្ថុ។៤. ........។ **ច្បាប់ភូមិបាលឆ្នាំ២០០១** មាត្រា២៖ ចាត់ទុកជាអចលនវត្ថុ តាមន័យនៃច្បាប់នេះមានអចលនវត្ថុពីកំណើរ អចលនវត្ថុពីភ័ព្វវាសនា និងអចលនវត្ថុតាមការកំណត់របស់ច្បាប់។ អចលនវត្ថុពីកំណើតមានដីធម្មជាតិដូចជា ដីព្រៃឈើ ដីកាប់រាន ដីដាំដុះ ដីទុកទំនេរ ឬ មិនអាចដាំដុះ ដីលិចទឹកដោយទឹកនៅនឹងឬទឹកហូរ និងសំណង់ ឬការរៀបចំទាំងឡាយដែលស្ថិតនៅជាប់មួយកន្លែង កើតឡើងដោយអំពើរបស់មនុស្ស ហើយមិនអាចរំកិល ឬ ផ្លាស់ប្តូរកន្លែងបាន។ អចលនវត្ថុពីភ័ព្វវាសនាមាន វត្ថុដែលជាប់នឹងដី ឬ បញ្ចូលជាមួយសំណង់ទាំងឡាយដែលមិនអាចបំបែកចេញបានដោយមិនធ្វើអោយមានការខូចខាត ឬ មិនដូរសភាពដើមដូចជាដើមឈើ ឧបករណ៍តែងលម្អជាដើម។ អចលនវត្ថុតមាការកំណត់របស់ច្បាប់មានសិទ្ធិភណ្ឌិក(សិទ្ធិប្រត្យក្ស ឬ សិទ្ធិភណ្ឌិក(Real Right)សំដៅទៅលើសិទ្ធិគ្រប់គ្រងដោយចំពោះលើវត្ថុ ដែលអាចអះអាងចំពោះបុគ្គលដទៃទៀតបាន)ទាំងឡាយលើអចលនវត្ថុ និងចលនវត្ថុទាំងឡាយដែលបានកំណត់ដោយច្បាប់ជាអចលនវត្ថុ។

ចំពោះភតិសន្យាលើអាគារ គឺជាកិច្ចសន្យាដែលភាគីម្ខាងមានកាតព្វកិច្ចប្រគល់អាគារ ដែលជាកម្មវត្ថុនៃកិច្ចសន្យាទៅអោយភាគីម្ខាងទៀតប្រើប្រាស់ ហើយភាគីដែលបានទទួលវត្ថុមានកាតព្វកិច្ចបង់ប្រាក់ថ្លៃឈ្នួល។ ក្នុងករណីនេះ តម្លៃនៃគោលបំណងត្រូវគណនាដោយយក**ថ្លៃឈ្នួលប្រចាំខែ x រយៈពេលនៃការជួល** x 2។ ការដែលគុណនឹងពីរបែបនេះ ដោយសារតែភតិសន្យាក៏ជាប្រភេទនៃកិច្ចសន្យាអញ្ញមញ្ញដែលភាគីទាំងសងខាង ត្រូវមានកាតព្វកិច្ចតិយុត្តចំពោះគ្នាទៅវិញទៅមក ដូចនេះត្រូវយកតម្លៃនៃគោលបំណងត្រូវគណនាពីរដងនៃថ្លៃឈ្នួលប្រចាំខែ[74]។

**<u>ឧទាហរណ៍</u>៖ ក** បានចុះកិច្ចសន្យាជួលអាគារកំពស់៥ជាន់ពី **ខ** ដើម្បីយកទៅបើកដំណើរការផ្សារទំនើប ដោយបានកំណត់តម្លៃឈ្នួល២០០.០០០(ម្ភៃម៉ឺន)យ៉េនក្នុង១ខែ ហើយរយៈពេលនៃការជួលគឺ៣ឆ្នាំ។ ដូចនេះ តម្លៃនៃគោលបំណងគឺត្រូវយក ថ្លៃឈ្នួលក្នុងរយៈពេល៣ឆ្នាំx២ => ៧២.០០០.០០(ចិតសិបពីរម៉ឺន)យ៉េន x ២ = ១៤៤០.០០០.០០(មួយពាន់បួនរយសែសិបម៉ឺនយ៉េន) ហើយដោយយោងតាមតារាងខាងលើករណីដែលតម្លៃនៃគោលបំណងមានចំនួន១៤៤០.០០០.០០ (មួយពាន់បួនរយសែសិបម៉ឺនយ៉េន នោះប្រាក់កម្រៃជើងសារមានចំនួន២៣.០០០(ពីរម៉ឺនបីពាន់) យ៉េន។

ប៉ុន្តែចំពោះភតិសន្យាលើដីក្នុងករណីរយៈពេលនៃការជួលដីលើស១០ឆ្នាំ នោះតម្លៃនៃគោលបំណងត្រូវស្មើនឹង២ដងនៃថ្លៃឈ្នួលក្នុងរយៈពេល១០ឆ្នាំ[75] បានន័យថាទោះបីជារយៈពេលនៃភតិសន្យាលើសពី១០ឆ្នាំក៏ដោយ ក៏តម្លៃនៃគោលបំណងត្រូវគណនាត្រឹមតែក្នុងរយៈពេល១០ឆ្នាំតែប៉ុណ្ណោះ។

**<u>ឧទាហរណ៍</u>៖** ភតិសន្យាមួយធ្វើឡើងក្នុងរយៈពេល៣០ឆ្នាំ ដូចនេះតម្លៃនៃគោលបំណងគឺគណនាត្រឹមតែរយៈពេល១០ឆ្នាំតែប៉ុណ្ណោះ ដោយយកតម្លៃនៃគោលបំណងគុណនឹង២ (កិច្ចសន្យាអញ្ញមញ្ញ) រួចគុណនឹងរយៈពេល១០ឆ្នាំ នោះយើងនឹងអាចឃើញប្រាក់កម្រៃជើងសារដែលត្រូវបង់ចំពោះកិច្ចសន្យាខាងលើ[76]។

### ១.២.៣.៤.៣.កិច្ចសន្យាខ្ចីបរិភោគ

ភាគីនៃកិច្ចសន្យាតែម្ខាងជាអ្នកអនុវត្តកាតព្វកិច្ច ដែលវាជាប្រភេទកិច្ចសន្យាឯកតោភាគីពោលគឺភាគីតែម្ខាងនោះមានកាតព្វកិច្ចបង់ប្រាក់កម្ចី ហើយតម្លៃនៃគោលបំណងគឺជាតម្លៃនៃប្រាក់កម្ចីនោះ។ចំណែកឯ កិច្ចសន្យាសងនូវបំណុលក៏ដូចជាកិច្ចសន្យាខ្ចីបរិភោគដែរ ដោយសារតែវាជាកិច្ចសន្យាដែលកំណត់នូវរបៀបក្នុងការសងដែលកើតមានឡើងតាមរយៈកិច្ចសន្យា ហេតុដូចនេះ

[74]មាត្រា១១ វាក្យខណ្ឌ១ នៃអនុក្រឹត្យស្តីអំពីកម្រៃជើងសាររបស់សារការីនៃប្រទេសជប៉ុន។
[75]មាត្រា១៣ នៃអនុក្រឹត្យស្តីអំពីកម្រៃជើងសាររបស់សារការីប្រទេសជប៉ុន។
[76]公証人, *手数料* [កម្រៃជើងសារ], http://www.koshonin.com/tesuuryou.html(ចូលទស្សនាថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៦)។

ហើយ គឺត្រូវគណនាតែតម្លៃនៃគោលបំណងដែលត្រូវសងតែប៉ុណ្ណោះ ពោលគឺមិនយកទៅគុណនឹងពីរទេ។

### ១.២.៣.៤.៤.កិច្ចសន្យាលែងលះ

ក្នុងករណីដែលសហព័ទ្ធទាំងពីរព្រមព្រៀងគ្នាលែងលះ ហើយបានព្រមព្រៀងគ្នាលើលិខិតលែងលះនោះ ដោយកំណត់អំពីថ្លៃសំណងជម្ងឺចិត្ត ការបែងចែកទ្រព្យ និងចំណាយសោហ៊ុយចិញ្ចឹមកូនដែលជាអនីតិជនរបស់សហព័ទ្ធណាម្ខាង ដោយយកលិខិតនោះទៅឲ្យសារការីផ្តល់យថាភូតភាពនោះប្រាក់កម្រៃជើងសារត្រូវគណនានូវសកម្មភាពគតិយុត្តនីមួយៗ ពោលគឺត្រូវគណនាប្រាក់កម្រៃជើងសារចំពោះសំណងជម្ងឺចិត្ត ប្រាក់កម្រៃជើងសារចំពោះទ្រព្យដែលត្រូវធ្វើការបែងចែក ព្រមទាំងប្រាក់កម្រៃជើងសារចំពោះសោហ៊ុយចិញ្ចឹមកូន។

**បញ្ជាក់:** ចំពោះចំណាយសោហ៊ុយចិញ្ចឹមកូន គឺត្រូវគណនាដោយយោងទៅលើរយៈពេលក្នុងការផ្តល់អោយ ដូចភតិសន្យាដែរ។

### ១.២.៣.៤.៥.មតកសាសន៍

ក្នុងករណីមានទាំងសន្តតិជន និងអច្ច័យលាភី សកម្មភាពគតិយុត្តត្រូវបែងចែកជាពីរហើយចំពោះប្រាក់កម្រៃជើងសារ ត្រូវគណនាដោយបូកបញ្ចូលតម្លៃនៃទ្រព្យសម្បត្តិដែលសន្តតិជន និងអច្ច័យលាភីទទួលបាន។ ចំពោះសន្តតិកម្ម មានភាពខុសពីសកម្មភាពគតិយុត្តដទៃដោយក្នុងករណីដែលមតកសាសន៍ ជាលិខិតដែលនឹងត្រូវផ្តល់យថាភូតភាពមានតម្លៃសរុបត្រឹម១០០.០០០.០០០(មួយរយលានយ៉េន) នោះប្រាក់កម្រៃជើងសារត្រូវបូកបន្ថែមចំនួន១១០.០០(មួយម៉ឺនមួយពាន់យ៉េន)។ ផ្ទុយទៅវិញ ក្នុងករណីដូចខាងលើ ប៉ុន្តែជាមតកសាសន៍ធម្មតា ពោលគឺមិនមានការផ្តល់យថាភូតភាពពីសារការី នោះ មិនត្រូវបូកប្រាក់ចំនួន១១០.០០(មួយម៉ឺនមួយពាន់រៀល) បន្ថែមលើប្រាក់កម្រៃជើងសារទេ។ ម្យ៉ាងវិញទៀត ក្នុងករណីដែលតម្រូវអោយសារការីទៅកន្លែងណាមួយ ក្រៅពីមន្ទីរសារការី ដូចជា មតកជនមុននឹងទទួលមរណភាព ត្រូវការធ្វើមតកសាសន៍ដោយមានការបញ្ជាក់ពីសារការី ប៉ុន្តែដោយមូលហេតុជម្ងឺទើបតម្រូវអោយសារការីទៅកាន់ផ្ទះរបស់មតកជន ដូចនេះប្រាក់កម្រៃជើងសារត្រូវគណនាដោយបូកបញ្ចូលនូវប្រាក់ថ្លៃធ្វើដំណើរ និងប្រាក់ថ្លៃបន្ថែមម៉ោង។ ការបន្ថែមម៉ោង ត្រឹម៤ម៉ោងត្រូវបង់ចំនួន១០.០០០(មួយម៉ឺន)យ៉េន ហើយបើលើស៤ម៉ោងក្នុងមួយថ្ងៃត្រូវបង់ចំនួន២០.០០០(ពីរម៉ឺន)យ៉េន។ ករណីមតកសាសន៍ណាដែលត្រូវធ្វើជាលិខិតសំងាត់ ដោយមិនមានការពិនិត្យលើអត្ថន័យនៃលិខិត នោះប្រាក់កម្រៃជើងសារត្រូវជា១១០.០០(មួយម៉ឺនមួយពាន់)យ៉េន។

## ផ្នែកទី២ នីតិវិធីជ្រើសតាំងសារការី និងបែបបទបង្កើតមន្ទីរសារការី

ផ្នែកនេះនឹងបង្ហាញអំពីលក្ខខណ្ឌដើម្បីក្លាយជាសារការី(២.១) និងលក្ខខណ្ឌដើម្បីបង្កើតមន្ទីរសារការីក្នុងប្រទេសជប៉ុន(២.២)។

### ២.១.លក្ខខណ្ឌដើម្បីក្លាយជាសារការី

សារការី ត្រូវតែជានីតិជន[77] ដែលត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ពីក្នុងចំណោមបុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ខាងផ្នែកច្បាប់[78] ។ នៅក្នុងច្បាប់ស្តីពីសារការី បានកំណត់អំពីលក្ខខណ្ឌដែលអាចក្លាយជាសារការី ដោយយោងតាមមធ្យោបាយចំនួន៣គឺ ឆ្លងកាត់ការប្រឡងប្រជែង(២.១.១) ឬ តាមរយៈការជ្រើសតាំងពីក្នុងចំណោមអ្នកច្បាប់(២.១.២) ឬ ជ្រើសតាំងពីក្នុងចំណោមបុគ្គលដែលមានបទពិសោធន៍ផ្នែកច្បាប់(២.១.៣) ៖

#### ២.១.១. ការប្រឡងប្រជែង

នៅក្នុងមាត្រា១២នៃច្បាប់ស្តីពីសារការី បានបញ្ញាតិអំពីលក្ខខណ្ឌដែលអាចក្លាយជាសារការីតាមរយៈការប្រឡងប្រជែង ដែលជាគោលការណ៍ ដើម្បីក្លាយជាសារការី ដាច់ខាតត្រូវតែទទួលការប្រឡងប្រជែង ហើយបន្ទាប់ជាប់ការប្រឡងប្រជែងនោះ បេក្ខភាពនោះត្រូវទទួលចុះកម្មសិក្សាជាក់ស្តែងចំនួន៦ខែ។ ដែលនេះ ត្រូវបានចាត់ទុកថាជាការទទួលបានការបណ្តុះបណ្តាល។

ចំពោះការរៀបចំការប្រឡងប្រជែងជាក់ស្តែង ដោយអនុលោមតាមច្បាប់ស្តីពីសារការីមិនត្រូវបានរៀបចំឡើងទេ ពោលគឺបុគ្គលដែលបានក្លាយជាសារការី តាមមាត្រា១២គឺមិនមានឡើយ។ ដូចដែលបានលើកឡើងខាងលើ នៅពេលដែលសារការីត្រូវបានគ្រប់គ្រងដោយបទវិន័យរបស់សារការី ការប្រឡងប្រជែងត្រូវបានរៀបចំឡើង ប៉ុន្តែបន្ទាប់ពីមានការអនុម័តច្បាប់ស្តីពីសារការី និងវិសោធនកម្មច្បាប់ស្តីពីសារការីនោះ ការប្រឡងប្រជែងមិនត្រូវបានរៀបចំឲ្យមានទេ។ ម្យ៉ាងវិញទៀត បើមើលទៅលើច្បាប់ស្តីពីសារការីរបស់ប្រទេសជប៉ុនទាំងមូល មិនបានបញ្ញត្តិថាតើ "**ត្រូវរៀបចំការប្រឡងប្រជែងជ្រើសរើសសារការី ប៉ុន្មានដងក្នុងមួយឆ្នាំ**" នោះទេ។ ដែលនេះ គឺជាមូលហេតុដែលនាំឲ្យមានការជ្រើសតាំងពីក្នុងចំណោមអ្នកច្បាប់ (២.១.២) និង ការជ្រើសតាំងពីក្នុងចំណោមអ្នកមានបទពិសោធន៍ផ្នែកច្បាប់ (២.១.៣) ពោល គឺអាចក្លាយជាសារការីតាមរយៈអតីតភាពការងារជាអ្នកច្បាប់ ឬជាបុគ្គលដែលមានបទពិសោធន៍យ៉ាងច្រើនទាក់ទងនឹងផ្នែកច្បាប់ ដែល

[77]មាត្រា ១២ នៃច្បាប់ស្តីពីសារការីប្រទេសជប៉ុន។

[78]មាត្រា ១១ នៃច្បាប់ស្តីពីសារការីប្រទេសជប៉ុន។

លក្ខខណ្ឌទាំងពីរនេះ អាចនិយាយបានថាស្ទើរតែ១០០%នៃសារការីក្នុងប្រទេសជប៉ុន កើតចេញពីលក្ខខណ្ឌណាមួយពីក្នុងចំណោមលក្ខខណ្ឌទាំងពីរនេះ។

### ២.១.២. ការជ្រើសតាំងពីក្នុងចំណោមអ្នកច្បាប់

លក្ខខណ្ឌទី២នេះ ជាលក្ខខណ្ឌដែលផ្តល់ឱកាសដល់អ្នកវិជ្ជាជីវៈច្បាប់ ឬអ្នកច្បាប់[79]មានដូចជា ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី ដែលមានបំណងចង់ក្លាយជាសារការី។ នៅប្រទេសកម្ពុជា ដើម្បីក្លាយជាចៅក្រម ព្រះរាជអាជ្ញា ឬមេធាវី បុគ្គលទាំងអស់ត្រូវតែឆ្លងកាត់ការប្រឡងប្រជែង[80]។ ដូចគ្នាផងដែរ ដើម្បីក្លាយជាអ្នកច្បាប់នៅប្រទេសជប៉ុន ដាច់ខាតត្រូវតែជាបេក្ខជនដែលប្រឡងជាប់ **ការប្រឡងផ្នែកច្បាប់**（司法試験/**Bar Examination**） និងឆ្លងកាត់ការចុះកម្មសិក្សាជាក់ស្តែង។ បន្ទាប់ពីបានបំពេញលក្ខខណ្ឌនេះហើយ បុគ្គលនោះនឹងក្លាយជាអ្នកច្បាប់។ ដោយឡែក ចំពោះអ្នកច្បាប់ដែលមានបំណងក្លាយជាសារការី ត្រូវបំពេញលក្ខខណ្ឌដូចតទៅ[81]៖

[79]ក្នុងប្រទេសជប៉ុន នៅពេលដែលគេចង់លើកឡើងពីបុគ្គលចំនួន៣គឺ ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី គេប្រើពាក្យថា «អ្នកច្បាប់ （法曹・法曹三者/Legal Profession）»។ដោយឡែក ក្នុងប្រទេសជប៉ុនគេធ្វើការបែងចែកបុគ្គលមួយប្រភេទផ្សេងទៀតដែលគេប្រើពាក្យថា «អ្នកជំនាញច្បាប់（法律家/ Jurist）» បើយើងបកប្រែជាភាសាខ្មែរ វាមានអន្តន័យប្រហាក់ប្រហែលគ្នា ប៉ុន្តែចំណុចដែលខុសគ្នានោះគឺចំពោះ«អ្នកជំនាញច្បាប់（法律家/ Jurist）»សំដៅទៅលើបុគ្គលដែលមានចំណេះដឹងយ៉ាងជំនាញទាក់ទងនឹងច្បាប់ ជាឧទាហរណ៍ សារការី ។ **បញ្ជាក់៖** ការបែងចែកការហៅបែបនេះគឺផ្អែកទៅលើស្ថានភាពនៃវិស័យច្បាប់ក្នុងប្រទេសនីមួយៗ។

[80] ចំពោះការស្បថដើម្បីទទួលងារជាមេធាវីដោយអនុលោមតាមមាត្រា៣២នៃច្បាប់ស្តីពីលក្ខន្តិកៈឆ្នាំ១៩៩៥នៃប្រទេសកម្ពុជា មិនត្រូវបានលើកយកមកសិក្សាទេ ពីព្រោះនៅក្នុងប្រទេសជប៉ុនមិនមានបញ្ញត្តិណាមួយដែលកំណត់ពីលក្ខខណ្ឌចូលប្រកបវិជ្ជាជីវៈមេធាវី តាមបទពិសោធន៍ធ្លាប់ជាអ្នកច្បាប់ ឬធ្លាប់បទពិសោធន៍បម្រើមុខងារទាក់ទងនឹងកិច្ចការច្បាប់នោះទេ។ ប៉ុន្តែ នៅប្រទេសជប៉ុនមានប្រព័ន្ធនៃការតែងតាំងមេធាវីឲ្យក្លាយជាចៅក្រម ដែលប្រព័ន្ធនេះមានតាំងពីសម័យមុនសង្គ្រាម ដោយគណៈមេធាវីនៃប្រទេសជប៉ុនជាស្ថាប័នមានអំណាចក្នុងការជ្រើសរើសមេធាវីរូបណាដែលមានបំណងចង់ក្លាយជាចៅក្រម ដោយមានការដាក់ពាក្យស្នើសុំ និងដែលមានបទពិសោធន៍ការងារច្រើនឆ្នាំ បន្ទាប់មកគណៈមេធាវីនឹងដាក់សំណើរនេះទៅកាន់ក្រសួងយុត្តិធម៌។

[81]មាត្រា១២ នៃច្បាប់ស្តីពីសារការីប្រទេសជប៉ុន។

- ចំពោះចៅក្រម[82](លើកលែងចៅក្រមនៃតុលាការរឿងក្តីតូចតាច[83]（簡易裁判所/ Summary Court）) ត្រូវមានបទពិសោធន៍ជាក់ស្តែង ពាក់ព័ន្ធនឹងការងាររបស់ខ្លួនចាប់ពី៣០ឆ្នាំឡើងទៅ
- ចំពោះព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញា (លើកលែងជំនួយការព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញា) ត្រូវមានបទពិសោធន៍ជាក់ស្តែង ពាក់ព័ន្ធនឹងការងាររបស់ខ្លួនចាប់ពី៣០ឆ្នាំឡើងទៅ
- ចំពោះមេធាវី ក៏ត្រូវមានបទពិសោធន៍ជាក់ស្តែង ពាក់ព័ន្ធនឹងការងាររបស់ខ្លួនចាប់ពី៣០ឆ្នាំឡើងទៅ

នៅមានបុគ្គលមួយរូបទៀតដែលអាចក្លាយជាសារការីតាមលក្ខខណ្ឌផងដែរ នោះគឺ៖

- បុគ្គលដែលធ្លាប់ធ្វើជាប្រធានការិយាល័យកិច្ចការច្បាប់ក្នុងតំបន់（法務局長/Regional Legal Affairs Bureau）មានបទពិសោធន៍ជាក់ស្តែង ពាក់ព័ន្ធនឹងការងាររបស់ខ្លួនចាប់ពី៣០ឆ្នាំឡើងទៅ។

ក្រោយពីពិនិត្យមើលលក្ខខណ្ឌ នៃបុគ្គលដែលបានដាក់ពាក្យស្នើសុំធ្វើរួចរាល់ហើយ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវចេញលិខិតតែងតាំងពួកគេទាំងនោះធ្វើជាសារការី។ ចំពោះបុគ្គលដែលបានរៀបរាប់ខាងលើនេះ មិនចាំបាច់ឆ្លងកាត់ការប្រឡងប្រជែង និងការចុះកម្មសិក្សានោះទេ។

---

[82] ចៅក្រម គឺជាអ្នកច្បាប់ដែលអនុវត្តមុខងាររបស់ខ្លួនក្នុងឋានៈជាមន្ត្រីរាជការសាធារណៈ មានតួនាទីកាត់សេចក្តី និងគ្រប់គ្រងកិច្ចការមួយចំនួនទាក់ទងនឹងការសម្រេចសេចក្តីនោះ។ ក្នុងប្រទេសជប៉ុនដើម្បីជានាតុល្យភាពនៃអំណាចទាំង៣ គឺ អំណាចនីតិបញ្ញត្តិ(រដ្ឋសភា・ព្រឹទ្ធសភា) អំណាចនីតិប្រតិបត្តិ(រាជរដ្ឋាភិបាល) និងអំណាចតុលាការ(អង្គការតុលាការ) ប្រធាននៃតុលាការកំពូលត្រូវបានជ្រើសតាំងដោយអំណាចនីតិប្រតិបត្តិ ក្រោយពីជ្រើសតាំងរួចរាល់ទើបអធិរាជនៃប្រទេសជប៉ុនជាអ្នកចេញរាជសារតែងតាំងឲ្យបំពេញមុខងារជាចៅក្រម(មាត្រា៦ កថាខណ្ឌទី២ នៃច្បាប់ស្តីពីអង្គការតុលាការនៃប្រទេសជប៉ុន) ចំណែកឯចៅក្រមនៃតុលាការកំពូលដទៃទៀតត្រូវបានតែងតាំងដោយស្ថាប័ននីតិប្រតិបត្តិផ្ទាល់តែម្តង។ ចំពោះចៅក្រមនៃសាលាដម្រះក្តីជាន់ទាប（下級裁判所/First Instance Court）ត្រូវបានតែងតាំងដោយស្ថាប័ននីតិប្រតិបត្តិឲ្យបំពេញមុខងាររបស់ខ្លួនក្នុងអាណត្តិ១០ឆ្នាំ ដោយយោងទៅតាមបញ្ជីឈ្មោះដែលចៅក្រមតុលាការកំពូលបានជ្រើសរើសរួច។ ក្នុងករណីដែលចៅក្រមប្រព្រឹត្តកំហុសក្នុងពេលបំពេញមុខងាររបស់ខ្លួន ក្នុងប្រទេសជប៉ុនគឺមានតុលាការចោទប្រកាន់ចៅក្រម ដោយតុលាការនេះត្រូវបានបង្កើតឡើងរួមគ្នារវាងសមាជិកសភាទាំងពីរ ដើម្បីសម្រេចសេចក្តីលើករណីខាងលើ។ សភាទាំងពីរទទួលបានសិទ្ធិអំណាចនេះ ដោយយោងទៅតាមច្បាប់ស្តីអំពីការចោទប្រកាន់ចៅក្រម។

[83] តុលាការរឿងក្តីតូចតាច（簡易裁判所/Summary Court）ជាតុលាការជាន់ទាបដែលដោះស្រាយរឿងព្រហ្មទណ្ឌ រឿងរដ្ឋប្បវេណីដែលមានលក្ខណៈស្រាលៗ។

យោងតាមមាត្រា៥០នៃច្បាប់ស្តីពីតុលាការនៃប្រទេសជប៉ុន អាយុចូលនិវត្តន៍របស់ចៅក្រមនៃតុលាការគ្រួសារ[84]（家庭裁判所/Family Court） តុលាការតាមតំបន់[85]（地方裁判所/Local Court） និងតុលាការជាន់ខ្ពស់[86]（高等裁判所/High Court） គឺ៦៥ឆ្នាំ។ ហេតុដូចនេះហើយទើបភាគច្រើននៃអ្នកច្បាប់ដែលចូលនិវត្តន៍ទាំងនោះ មកចាប់យកវិជ្ជាជីវៈសារការី ពីព្រោះអាយុចូលនិវត្តន៍របស់សារការីគឺ៧០ឆ្នាំ។ បើយើងក្រឡេកមកមើល ចំនួនសារការីទូទាំងប្រទេសជប៉ុនក្នុងឆ្នាំ១៩៨៩ គឺមានចំនួន៥៣១នាក់ ដោយ១៥០នាក់ជាអតីតចៅក្រម ២៤០នាក់ជាអតីតព្រះរាជអាជ្ញា ១៤០នាក់ជាអតីតប្រធានការិយាល័យកិច្ចការច្បាប់ក្នុងតំបន់ ដែលជាមន្ត្រីក្រសួងយុត្តិធម៌ និង១នាក់ជាអតីតមេធាវី។

### ២.១.៣.ការជ្រើសតាំងពីក្នុងចំណោមអ្នកមានបទពិសោធន៍ផ្នែកច្បាប់

យោងតាមមាត្រា១៣ កថាខណ្ឌទី២ នៃច្បាប់សារការីប្រទេសជប៉ុន បានបញ្ញត្តិអំពីលក្ខខណ្ឌទី២ ចំពោះបុគ្គលដែលមានបទពិសោធន៍ផ្នែកច្បាប់ ហើយមានបំណងចង់ក្លាយជាសារការី។ មាត្រានេះ បានកំណត់ថាបុគ្គលដែលមានបទពិសោធន៍ច្រើនឆ្នាំ ជាពិសេសមានចំណេះដឹងជ្រៅជ្រះខាងផ្នែកច្បាប់ នឹងត្រូវបានតែងតាំងជាសារការី ក្រោយទទួលការជ្រើសរើសដោយគណកម្មការត្រួតពិនិត្យសារការី（公証人審査会）។ ប៉ុន្តែអាចអនុវត្តលក្ខខណ្ឌនេះបាន លុះត្រាតែមិនមានវត្តមានសារការី ដែលអនុវត្តមុខងាររបស់ខ្លួនក្នុងការិយាល័យកិច្ចការច្បាប់ក្នុងតំបន់ណាមួយនោះ។ បេក្ខភាពដែលទទួលបានការជ្រើសរើសដោយគណៈកម្មការត្រួតពិនិត្យសារការី មិនចាំបាច់ទទួលការប្រឡង ឬ ចុះកម្មសិក្សាជាក់ស្តែងនោះទេ ប៉ុន្តែបើសិនជាមានការដាក់ពាក្យស្នើសុំតាមរយៈលក្ខខណ្ឌនេះច្រើនជាងចំនួនដែលបានកំណត់បេក្ខភាពទាំងអស់នឹងត្រូវទទួលការប្រឡងចំនួនពីរ គឺ

---

[84]តុលាការគ្រួសារ （家庭裁判所/Family Court）ជាតុលាការជាន់ទាបដែលដោះស្រាយរឿងក្តីទាក់ទងនឹងគ្រួសារ អាណាព្យាបាលលើអនីតិជនជាដើម។ តុលាការនេះមានឋានៈស្មើតុលាការតាមតំបន់（地方裁判所/Local Court）ហើយនៅទូទាំងប្រទេសជប៉ុនមានចំនួន៥០កន្លែង។（名古屋大学日本法教育研究センター、*『日本史・公民』*（名古屋、2009年）។ មជ្ឈមណ្ឌលស្រាវជ្រាវ និងអប់រំអំពីច្បាប់ជប៉ុននៃសាកលវិទ្យាល័យណាហ្គោយ៉ា, *[ប្រវត្តិសាស្ត្រជប៉ុន និងប្រជាជន]*, (ណាហ្គោយ៉ា,២០០៩),៧២។

[85]តុលាការគ្រួសារ （地方裁判所/Local Court）ជាតុលាការជាន់ទាប(សាលាដំបូង) ហើយនៅទូទាំងប្រទេសជប៉ុនមានចំនួន៥០កន្លែង។

[86]តុលាការជាន់ខ្ពស់ （高等裁判所/High Court）ស្មើនឹងសាលាឧទ្ធរណ៍នៃប្រទេសកម្ពុជា ហើយនៅទូទាំងប្រទេសជប៉ុនមានចំនួន៨ទីតាំងគឺ តូក្យូ(東京/Tokyo) អូសាកា（大阪/Osaka） ណាហ្គោយ៉ា（名古屋/Nagoya） ហ៊ីរ៉ូស៊ីម៉ា（広島/Hiroshima） ហ៊្វឹគឹអូកា（福岡/Fukuoka） សេនដៃ（仙台/Sendai） សាប់ប៉ូរ៉ូ（札幌/Sapporo） និងតាកាម៉ាឡឹ（高松/Takamastu）។

ប្រឡងសរសេរនូវសំណួរ-ចម្លើយខ្លីៗ និងការប្រលងដោយសម្ភាសន៍ផ្ទាល់មាត់។ ចំពោះបេក្ខជនដែលប្រឡងជាប់វិញ្ញាសារប្រឡងទាំងពីរនេះនឹងក្លាយជាសារការី។

## ២.២. លក្ខខណ្ឌក្នុងការបង្កើតមន្ទីរសារការី

សារការីអនុវត្តមុខងាររបស់ខ្លួនក្នុងកន្លែងដែលមានឈ្មោះថា"មន្ទីរ" ហើយដើម្បីបើកដំណើរការមន្ទីរសារការីនេះបាន បុគ្គលនោះដាច់ខាតត្រូវតែមានលក្ខណៈសម្បត្តិជាសារការី(២.២.១) និងមានការអនុញ្ញាតឲ្យបង្កើតជាមន្ទីរសារការីដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌(២.២.២)។

### ២.២.១. លក្ខណៈសម្បត្តិជាសារការី

ដូចដែលបានរៀបរាប់ក្នុងផ្នែកទី២ បុគ្គលដែលបានបំពេញលក្ខខណ្ឌណាមួយនៃលក្ខខណ្ឌទាំង៣នៃខាងលើនឹងត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ហើយក្លាយជាសារការី។ ការទទួលបានមុខងារជាសារការី មិនតំណាងថាអាចអនុវត្តមុខងាររបស់ខ្លួនបាននៅឡើយទេ ពោលគឺសារការីរូបនោះ ត្រូវទទួលការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាថ្មីម្តងទៀតទើបអាចបើកដំណើរការមន្ទីរសារការីរបស់ខ្លួនបាន ហើយចំណុចនេះនឹងត្រូវលម្អិតនៅក្នុងចំណុច(២.២.២)ខាងក្រោម។

### ២.២.២. តែងតាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

នៅក្នុងប្រទេសជប៉ុន ចំពោះលិខិតបទដ្ឋានស្តីអំពីនីតិវិធីក្នុងការបើកដំណើរការមន្ទីរសារការី និងលក្ខខណ្ឌដោយឡែកផ្សេងទៀតពាក់ព័ន្ធនឹងសារការី គឺមានបញ្ញត្តិនៅក្នុងបទប្បញ្ញត្តិស្តីពីការអនុវត្តច្បាប់សារការី ដែលបទបញ្ញត្តិនេះ ចេញដោយអនុក្រឹត្យលេខ៩របស់ក្រសួងយុត្តិធម៌ នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ១៩៤៩ ហើយត្រូវបានធ្វើវិសោធនកម្មលើកចុងក្រោយនៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០០៧។ ដូចដែលបានលើកឡើងខាងលើ សារការីជាបុគ្គលដែលត្រូវបានជ្រើសតាំង ដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ហើយអនុវត្តមុខងាររបស់ខ្លួនក្នុងស្ថាប័ន ដែលមានឈ្មោះថា "**មន្ទីរ**"។ ដើម្បីអាចបើកមន្ទីរសារការីបាន ជាដំបូង សារការីនោះត្រូវដាក់ពាក្យសុំទៅការិយាល័យកិច្ចការច្បាប់ក្នុងតំបន់ （法務局/ Regional Legal Affair Bureau)ឬ ដាក់ពាក្យសុំទៅការិយាល័យកិច្ចការច្បាប់តាមខេត្ត （地方法務局/ Province Legal Affair Bureau）នីមួយៗ ដែលសារការីនោះស្ថិតនៅ។ នៅក្នុងសំណុំលិខិតដាក់ពាក្យស្នើសុំ ត្រូវបញ្ជាក់ឲ្យច្បាស់នូវចំណុចចំនួន៤ ៖

១.អំពីទីតាំងដែលនឹងបង្កើតជាមន្ទីរសារការី

២.ទម្រង់នៃអាគារ

៣.ស្ថានភាពទាំងមូលនៃអាគារ

៤.លិខិតដែលមានការតែងតាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

រួចដាក់ពាក្យសុំទៅស្ថាប័នខាងលើដែលមានសមត្ថកិច្ច បន្ទាប់មកត្រូវទទួលបានការអនុញ្ញាតពីប្រធានការិយាល័យកិច្ចការច្បាប់តាមខេត្ត ឬ ការិយាល័យកិច្ចការច្បាប់តាមតំបន់ ទើបសារការីនោះអាចអនុវត្តមុខងាររបស់ខ្លួនដោយពេញច្បាប់បាន។ នៅពេលដែលសារការីបានបង្កើតមន្ទីរសារការីរបស់ខ្លួនរួចរាល់ហើយ ដាច់ខាតត្រូវតែផ្តល់ដំណឹងទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ហើយក្នុងករណីដែលមានការផ្លាស់ប្តូរទីតាំងនៃមន្ទីរសារការី ក៏ត្រូវជូនដំណឹងទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ផងដែរ[87]។ ក្រោយពេលទទួលបានការអនុញ្ញាតឲ្យដំណើរការមន្ទីរសារការីហើយ សារការីនោះត្រូវរៀបចំទីតាំងរបស់ខ្លួនដោយមានបង្ហាញពីទីតាំងឲ្យបានច្បាស់លាស់ និងនាមករណ៍ដោយលើកជាស្លាក ឬផ្សព្វផ្សាយដល់សាធារណជនតាមរយៈមធ្យោបាយផ្សេងៗ[88]។

ចំពោះត្រាផ្លូវការរបស់សារការី ត្រូវបានកម្រិតនូវទំហំយ៉ាងជាក់លាក់ ដោយត្រានីមួយៗ ត្រូវមានទំហំត្រឹម១៨មីលីម៉ែត្រ និងត្រូវឆ្លាក់ឈ្មោះ ព្រមទាំងអត្តសញ្ញាណផ្សេងទៀតរបស់សារការីផងដែរ[89]។ រីឯម៉ោងធ្វើការរបស់សារការី គឺត្រូវអនុលោមតាមម៉ោងការងាររបស់មន្ត្រីរាជការ ដែលបម្រើការក្នុងក្រសួងយុត្តិធម៌ ប៉ុន្តែបើករណីដែលត្រូវបំពេញមុខងារបន្ទាន់ណាមួយ ដែលតម្រូវឲ្យធ្វើនៅថ្ងៃឈប់សម្រាក ឬ ក្រៅម៉ោងធ្វើការ សារការីនោះនៅតែអាចអនុវត្តរបស់ខ្លួនបាន ប៉ុន្តែត្រូវតែជាកិច្ចការដែលជាប់ទាក់ទងនឹងមុខងាររបស់ខ្លួន[90]។

ករណីដែលសារការី មិនអាចអនុវត្តមុខងាររបស់ខ្លួនដោយមូលហេតុជម្ងឺ ឬ មូលហេតុដទៃទៀតដែលមិនអាចជៀសវាងបាន ដោយមិនអាចផ្ទេរកិច្ចការនោះ ឬ មិនបានផ្ទេរកិច្ចការនោះទៅឲ្យសារការីផ្សេងទៀត ត្រូវជូនដំណឹងទៅការិយាល័យកិច្ចការច្បាប់ក្នុងតំបន់ឬ ការិយាល័យកិច្ចការច្បាប់តាមខេត្តដែលមានសមត្ថកិច្ច ហើយបើអាចបំពេញមុខងាររបស់ខ្លួនឡើងវិញ ក៏ត្រូវជូនដំណឹងទៅការិយាល័យកិច្ចការច្បាប់ក្នុងតំបន់ ឬ ការិយាល័យកិច្ចការច្បាប់តាមខេត្ត ដែលមានសមត្ថកិច្ចនោះផងដែរ[91]។ ករណីដែលសារការីបានផ្លាស់ប្តូរឈ្មោះ ឬ អត្តសញ្ញាណ ឬ អាស័យដ្ឋានរបស់ខ្លួន ឬ

[87]មាត្រា ១ នៃបទប្បញ្ញត្តិស្តីពីការអនុវត្តច្បាប់សារការីនៃប្រទេសជប៉ុន។
[88]មាត្រា ២ នៃបទប្បញ្ញត្តិស្តីពីការអនុវត្តច្បាប់សារការីនៃប្រទេសជប៉ុន។
[89]មាត្រា ៣ នៃបទប្បញ្ញត្តិស្តីពីការអនុវត្តច្បាប់សារការីនៃប្រទេសជប៉ុន។
[90]មាត្រា ៩ នៃបទប្បញ្ញត្តិស្តីពីការអនុវត្តច្បាប់សារការីនៃប្រទេសជប៉ុន។
[91]មាត្រា ៣៣ នៃបទប្បញ្ញត្តិស្តីពីការអនុវត្តច្បាប់សារការីនៃប្រទេសជប៉ុន។

លាឈប់ពីមុខងារសារការី ក៏ត្រូវជូនដំណឹងទៅការិយាល័យកិច្ចការច្បាប់ក្នុងតំបន់ ឬការិយាល័យ ការិយាល័យកិច្ចការច្បាប់តាមខេត្តដែលមានសមត្ថកិច្ចដែរ ហើយក្នុងករណីដែលសារការីនោះទទួលមរណភាព ញាតិក្នុងបួនថ្នាក់ត្រូវជូនដំណឹងអំពីមរណភាពនេះទៅការិយាល័យកិច្ចការច្បាប់ក្នុងតំបន់ ឬ ការិយាល័យកិច្ចការច្បាប់តាមខេត្តដែលមានសមត្ថកិច្ច [92] ។ ករណីដែលសារការីមានភាពមិនច្បាស់លាស់ ឬ មានចម្ងល់ពាក់ព័ន្ធនឹងកិច្ចការដែលខ្លួនកំពុងបំពេញ សារការីនោះត្រូវសុំការណែនាំពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌បាន[93] ហើយក្នុងករណីដែលសារការីត្រូវដាក់ឯកសារណាមួយ ទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដាច់ខាតត្រូវតែដាក់ជូនទៅប្រធានការិយាល័យកិច្ចការច្បាប់ក្នុងតំបន់ឬ ប្រធានការិយាល័យកិច្ចការច្បាប់តាមខេត្តជាមុនសិន ប៉ុន្តែអាចដាក់ទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដោយផ្ទាល់បានករណីជាកិច្ចការបន្ទាន់[94]។

ដើម្បីកំណត់ឲ្យបានច្បាស់លាស់នូវអត្តសញ្ញាណ និង ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងសារការីតាមតំបន់ និង ខេត្តនីមួយៗ ប្រធានការិយាល័យកិច្ចការច្បាប់ក្នុងតំបន់ ឬ ប្រធានការិយាល័យកិច្ចការច្បាប់តាមខេត្តត្រូវរៀបចំឲ្យបានលម្អិត នូវបញ្ជីឈ្មោះសារការីក្នុងតំបន់ ឬ ខេត្តនីមួយៗ ដោយភ្ជាប់នឹងទីតាំងនៃមន្ទីរសារការី អាសយដ្ឋានផ្ទាល់ខ្លួន និងថ្ងៃខែឆ្នាំកំណើតរបស់សារការីទាំងនោះ[95]។ ប្រធានការិយាល័យកិច្ចការច្បាប់ក្នុងតំបន់ ឬ ប្រធានការិយាល័យកិច្ចការច្បាប់តាមខេត្ត ត្រូវចុះទៅជួបមន្ទីរសារការីដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនដោយផ្ទាល់ យ៉ាងហោចណាស់មួយឆ្នាំម្តង ដើម្បីពិនិត្យមើលស្ថានភាពនៃការអនុវត្តមុខងាររបស់សារការី និងពិនិត្យមើលសុវត្ថិភាពនៃការរក្សាទុកឯកសាររបស់អតិថិជន រួចរាយការណ៍ពីលទ្ធផលនៃការត្រួតពិនិត្យនេះឲ្យបានលឿនបំផុតទៅកាន់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប៉ុន្តែប្រធានការិយាល័យកិច្ចការច្បាប់ក្នុងតំបន់ ឬ ប្រធានការិយាល័យកិច្ចការច្បាប់តាមខេត្ត ក៏អាចចាត់តាំងមន្ត្រីច្បាប់ដែលធ្វើការក្នុងការិយាល័យរបស់ខ្លួនទៅត្រួតពិនិត្យជំនួសខ្លួនផងដែរ [96] ។ នៅពេលដែលមានករណីចាំបាច់ពិសេសណាមួយ និងដោយមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្រៅពីប្រធានការិយាល័យច្បាប់តាមតំបន់ និងតាមខេត្តនីមួយៗ មន្ត្រីរាជការដែលបម្រើការនៅក្រសួងយុត្តិធម៌ ក៏អាចត្រួតពិនិត្យកិច្ចការមួយចំនួនរបស់សារការីបានផងដែរ[97]។ សារការី អាចបង្កើតសមាគមសារការីនៅតាមតំបន់ និងខេត្តនីមួយៗរបស់

[92]មាត្រា ៣៤ នៃបទប្បញ្ញត្តិស្តីពីការអនុវត្តច្បាប់សារការីនៃប្រទេសជប៉ុន។
[93]មាត្រា ៣៥ នៃបទប្បញ្ញត្តិស្តីពីការអនុវត្តច្បាប់សារការីនៃប្រទេសជប៉ុន។
[94]មាត្រា ៣៦ នៃបទប្បញ្ញត្តិស្តីពីការអនុវត្តច្បាប់សារការីនៃប្រទេសជប៉ុន។
[95]មាត្រា ៣៧ នៃបទប្បញ្ញត្តិស្តីពីការអនុវត្តច្បាប់សារការីនៃប្រទេសជប៉ុន។
[96]មាត្រា ៣៩ នៃបទប្បញ្ញត្តិស្តីពីការអនុវត្តច្បាប់សារការីនៃប្រទេសជប៉ុន។
[97]មាត្រា ៤១ នៃបទប្បញ្ញត្តិស្តីពីការអនុវត្តច្បាប់សារការីនៃប្រទេសជប៉ុន។

ខ្លួន ដោយត្រូវស្ថិតក្រោមដែនសមត្ថកិច្ចគ្រប់គ្រង ដោយការិយាល័យច្បាប់តាមតំបន់ និងតាមខេត្ត។ សមាគមនោះ ត្រូវដឹកនាំសារការីទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានានូវគុណភាពការងាររបស់សារការីឲ្យកាន់តែមានប្រសិទ្ធិភាព ក៏ដូចជាដើម្បីបង្រួបបង្រួមសារការីក្នុងតំបន់ និងខេត្តនីមួយៗ ឲ្យមានទំនាក់ទំនងគ្នាកាន់តែល្អប្រសើរ[98]។ សារការីណាក៏ដោយ ត្រូវចាត់ទុកថាជាសមាជិកនៃសមាគមសារការី ដែលបានបង្កើតឡើងក្នុងតំបន់ ឬ ខេត្តនោះដោយស្វ័យប្រវត្តិ។ ការធ្វើបែបនេះ គឺដើម្បីឲ្យសមាគមនោះមានភាពរឹងមាំ និងជាមធ្យោបាយមួយក្នុងការគ្រប់គ្រងសារការីផងដែរ[99]។

ជារួម ចំពោះនីតិវិធីនៃការបើកដំណើរការមន្ទីរសារការីនៅប្រទេសជប៉ុន មិនសូវមានលក្ខណៈស្មុគស្មាញ តឹងរឹង ឬ លក្ខខណ្ឌផ្នែកសេដ្ឋកិច្ចអ្វីនោះទេ គឺបើកដំណើរដោយអនុលោមតាមលក្ខខណ្ឌទូទៅដូចនីតិបុគ្គលធម្មតា ដោយមានគោលបំណងក្នុងការបង្កើត មានទីតាំងច្បាស់លាស់ មាននាមករណ៍ និងមុខងារជាសារការី។ ការអនុវត្តមុខងាររបស់សារការីនៃប្រទេសជប៉ុន ស្ទើរតែ១០០%ត្រូវបានគ្រប់គ្រងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ តាមរយៈការិយាល័យច្បាប់តាមតំបន់ និងតាមខេត្តនីមួយៗ។ បើយើងពិនិត្យមើល លើនីតិវិធីបើកដំណើរមន្ទីរសារការីនៃប្រទេសជប៉ុន គឺមានភាពងាយស្រួលជាងនីតិវិធីបើកដំណើរការមន្ទីរសារការី នៃប្រទេសកម្ពុជាត្រង់ចំណុចមួយ គឺមិនតម្រូវឲ្យសារការីត្រូវតម្កល់លុយ៦០០(ប្រាំមួយរយ)លានរៀលក្នុងធនាគារជាតិនោះទេ។

ដូចនេះនឹងមានសំណួរចោទឡើងថា តើសារការីនៃប្រទេសជប៉ុនត្រូវទទួលខុសត្រូវដោយរបៀបណា ក្នុងករណីដែលមានកំហុសកើតឡើងក្នុងពេលអនុវត្តមុខងាររបស់ខ្លួន? ដើម្បីឆ្លើយនឹងសំណួរនេះបាន យើងត្រូវពិចារណាទៅលើឋានៈដោយផ្អែកលើច្បាប់របស់សារការីនៅប្រទេសជប៉ុន។ ក្នុងន័យចង្អៀត សារការីមិនមែនជាមន្ត្រីរាជការទេ ប៉ុន្តែ សារការីជាមន្ត្រីរាជការក្នុងន័យទូលាយ។ សារការីមិនមែនជាមន្ត្រីរាជការ ដោយសារតែសារការីមិនទទួលប្រាក់ខែពីរដ្ឋាភិបាលជប៉ុននោះទេ គឺទទួលបានតម្លៃតបស្នងពីការបំពេញមុខងាររបស់ខ្លួនដែលគេហៅកម្រៃជើងសារ។ ចំពោះការកំណត់កម្រិតតម្លៃជើងសារ នៃការបំពេញមុខងាររបស់សារការី គឺត្រូវបានកម្រិតដោយច្បាប់ និងស្ថិតក្រោមការគ្រប់គ្រងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដូចនេះយើងអាចសន្និដ្ឋានបានថា ទោះបីជាមិនមាននីតិវិធីតម្រូវឲ្យសារការីតម្កល់ប្រាក់ក្នុងស្ថាប័នណាមួយ ដើម្បីធានាដល់ការទទួលខុសត្រូវក៏ដោយ ក៏មុខងារមួយនេះត្រូវបានចងភ្ជាប់ដោយរដ្ឋ ហើយក្នុងករណីដែលមានកំហុសក្នុងការអនុវត្តមុខងាររបស់ខ្លួន សារការីត្រូវទទួលខុសត្រូវក្នុងនាមជាមន្ត្រីរាជការ។ និយាយម្យ៉ាងទៀត បើបុគ្គលណាម្នាក់បាន

[98]មាត្រា ៤៣ នៃបទប្បញ្ញត្តិស្តីពីការអនុវត្តច្បាប់សារការីនៃប្រទេសជប៉ុន។

[99]មាត្រា ៤៤ នៃបទប្បញ្ញត្តិស្តីពីការអនុវត្តច្បាប់សារការីនៃប្រទេសជប៉ុន។

បាត់បង់ផលប្រយោជន៍ ដោយសារតែកំហុសរបស់សារការី បុគ្គលនោះអាចប្តឹងទៅតុលាការ ដើម្បីឲ្យសារការីទទួលខុសត្រូវក្នុងនាមបុគ្គលផ្ទាល់ខ្លួន ឬ ប្តឹងទៅរដ្ឋ ឲ្យទទួលខុសត្រូវក្នុងនាមស្ថាប័ន។

## ផ្នែកទី៣ បច្ចុប្បន្នភាពនៃវិជ្ជាជីវៈសារការី( ឆ្នាំ២០១៦ )

នៅក្នុងផ្នែកនេះនឹងបង្ហាញអំពីចំនួនសារការី និងចំនួនមន្ទីរសារការីនាពេលបច្ចុប្បន្នក្នុងប្រទេសជប៉ុន(៣.១) ព្រមទាំងបង្ហាញអំពីស្ថាប័នដើម្បីពង្រឹងប្រព័ន្ធសារការីនៅក្នុងប្រទេសជប៉ុនផងដែរ(៣.២)។

### ៣.១.ចំនួនសារការី និងចំនួនមន្ទីរសារការី

យោងតាមទិន្នន័យដែលសហគមជាតិសារការីនៃប្រទេសជប៉ុនបានបង្ហាញជាផ្លូវការតាមរយៈគេហទំព័ររបស់ខ្លួន ចំនួនសារការីនៅខែកញ្ញា ឆ្នាំ២០០៩ គឺមានចំនួន៥៤៣នាក់ និងមាន២៩៩មន្ទីរសារការី ប៉ុន្តែគិតមកត្រឹមឆ្នាំខែកក្កដា ឆ្នាំ២០១៦ សារការីមានចំនួន៥២០នាក់[100] និងមាន២៨៦មន្ទីរសារការី[101](អាចរកមើលបានក្នុងឧបសម្ព័ន្ធទី៤ និងទី៥)។

### ៣.២.ស្ថាប័នពង្រឹងប្រព័ន្ធសារការី

ក្នុងប្រទេសជប៉ុន ដើម្បីពង្រឹងប្រព័ន្ធសារការីឲ្យកាន់តែមានការវិវត្តន៍ និងមានជំនឿទុកចិត្តក្នុងការប្រើប្រាស់ពីសំណាក់ប្រជាពលរដ្ឋ រាជរដ្ឋាភិបាលនៃប្រទេសជប៉ុនបានបង្កើតនូវសមាគមសារការីតាមតំបន់ និងតាមខេត្ត（公証人会）(៣.២.១) និងសមាគមន៍សារការីជាតិនៃប្រទេសជប៉ុន（日本公証人連合会 / The Japan National Notaries Association)(៣.២.២) សមាគមន៍នេះជាស្ថាប័នជាតិមានតួនាទីចម្បងក្នុងការពង្រឹងជម្រុញផ្សព្វផ្សាយ និងរៀបចំប្រព័ន្ធសារការីឱ្យមានភាពរឹងមាំនិងកាន់តែទូលំទូលាយ[102]។

---

[100] 法務省, 指定公証人一覧 [តារាងស្តីពីសារការីដែលត្រូវបានតែងតាំង], http://www.moj.go.jp/MINJI/DENSHIKOSHO/denshikosho2.html (ចូលទស្សនាថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦)។

[101] 法務省, *全国公証役場所在地一覧* [តារាងស្តីពីទីតាំងនៃមន្ទីរសារការីទូទាំងប្រទេស], http://www.koshonin.gr.jp/sho.html (ចូលទស្សនាថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦)។

[102] Japan National Notaries Association, *How to make good use of Japanese Notaries* [វិធីដើម្បីឲ្យការប្រើប្រាស់ប្រព័ន្ធសារការីជប៉ុនកាន់តែល្អ], ទំព័រទី២។

### ៣.២.១.សមាគមសារការីតាមតំបន់ និងតាមខេត្ត

សារការីអាចបង្កើតសមាគមសារការីនៅតាមតំបន់ និងខេត្តនីមួយៗរបស់ខ្លួនដោយត្រូវស្ថិតក្រោមដែនសមត្ថកិច្ចគ្រប់គ្រងដោយការិយាល័យច្បាប់តាមតំបន់ និងតាមខេត្ត ហើយសមាគមនោះត្រូវដឹកនាំសារការីទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានានូវគុណភាពការងាររបស់សារការីឲ្យកាន់តែមានប្រសិទ្ធិភាព ក៏ដូចជាដើម្បីបង្រួបបង្រួមសារការីក្នុងតំបន់ និងខេត្តនីមួយៗឲ្យមានទំនាក់ទំនងគ្នាកាន់តែល្អប្រសើរ[103]។ សារការីណាក៏ដោយ ត្រូវចាត់ទុកថាជាសមាជិកនៃសមាគមសារការីដែលបានបង្កើតឡើងក្នុងតំបន់ ឬ ខេត្តនោះដោយស្វ័យប្រវត្តិ ការធ្វើបែបនេះគឺដើម្បីឲ្យសមាគមនោះមានភាពរឹងមាំ និងជាមធ្យោបាយមួយក្នុងការគ្រប់គ្រងសារការីផងដែរ[104]។

### ៣.២.២.សមាគមជាតិសារការីនៃប្រទេសជប៉ុន

សមាគមន៍សារការីជាតិនៃប្រទេសជប៉ុន កំពុងមានបេសកកម្មជំរុញឱ្យមានការប្រើប្រាស់ប្រព័ន្ធបញ្ជាក់ ឬការផ្តល់យថាភូតភាពលើលិខិតផ្សេងៗ តាមរយៈប្រព័ន្ធអេឡិចត្រូនិចដែលគេហៅថា "e-Notarization"។ ការបង្កើតឱ្យមានប្រព័ន្ធបែបនេះ មិនមែនត្រឹមតែមានគោលបំណងធ្វើទំនើបកម្មនៃប្រព័ន្ធសារការីនោះទេ ប៉ុន្តែគោលដៅចម្បង គឺការធានាឱ្យបាននូវនិរន្តរភាព និងសុវត្ថិភាពនៃលិខិតទាំងអស់ដែលសារការីបានផ្តល់ការបញ្ជាក់ឬផ្តល់យថាភូតភាពរួច។

ដូចដែលយើងបានដឹងជាទូទៅថាប្រទេសជប៉ុនជាប្រទេសដែលតែងតែកើតមាននូវគ្រោះធម្មជាតិជាញឹកញាប់ មានដូចជាគ្រោះរញ្ជួយដី រលកយក្សស៊ូណាមីជាដើម។ ជាក់ស្តែងនៅឆ្នាំ២០០៨ ប្រទេសជប៉ុនបានកើតឡើងនូវគ្រោះរញ្ជួយដីដ៏ធំមួយ ដែលធ្វើអោយបាត់បង់នូវឯកសារមួយចំនួនក្នុងមន្ទីរសារការីត្រង់កន្លែងដែលរញ្ជួយដីបានកើតឡើង។ ជាមេរៀនដែលប្រទេសជប៉ុនបានទទួលពីគ្រោះធម្មជាតិខាងលើ ទើបរាជរដ្ឋាភិបាលបានបង្កើតនូវប្រព័ន្ធ e-Notarization ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រជាតិរបស់ខ្លួន ដើម្បីធានារក្សាទុកយ៉ាងមានសុវត្ថិភាពនូវអត្ថិភាពរបស់លិខិតទាំងឡាយដែលសំខាន់ៗ ដែលគេហៅថាជា "**ការរក្សាទុកពីរជាន់ (Double Savings)**" ការរក្សាទុកពីរជាន់នៃប្រព័ន្ធ e-Notarization គឺជាមធ្យោបាយធានាអភិវឌ្ឍន៍ និងពង្រឹងប្រព័ន្ធសារការីដើម្បីរក្សានូវលិខិតដើម (ច្បាប់ដើម) របស់សារការី ដែលលិខិតទាំងនោះដើរតួនាទីយ៉ាងសំខាន់ ក្នុងការការពារសិទ្ធិ

[103]មាត្រា៨៣ នៃបទប្បញ្ញត្តិស្តីពីការអនុវត្តច្បាប់សារការីនៃប្រទេសជប៉ុន។

[104]មាត្រា៨៤ នៃបទប្បញ្ញត្តិស្តីពីការអនុវត្តច្បាប់សារការីនៃប្រទេសជប៉ុន។

របស់ប្រជាពលរដ្ឋ ជាពិសេសដើម្បីបង្ការវិវាទរបស់បុគ្គលឯកជន និងឯកជន ក្នុងគោលដៅធានាឲ្យបាននូវជំនឿទុកចិត្តរបស់លិខិតសារការី[105]។

ចំពោះប្រព័ន្ធe-Notarizationនេះ កំពុងត្រូវបានអនុវត្តក្នុងតំបន់មួយចំនួននៃប្រទេសជប៉ុនតាមរយៈការជំរុញពីសមាគមន៍សារការីតាមតំបន់ ដែលក្នុងនោះមានដូចជាសមាគមន៍សារការីតូក្យូ (Tokyo Notaries Association) បានចាប់ផ្តើមអនុវត្តប្រព័ន្ធនេះនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៣ហើយក៏មានការចាប់ផ្តើមអនុវត្តន៍ជាបន្តបន្ទាប់ពី សំណាក់សមាគមន៍សារការីអូសាកា (Osaka Notaries Association) មន្ទីរសារការីទាំងអស់ដែលស្ថិតក្នុងទីក្រុងណាហ្គូយ៉ា (The notary public's office in Nagoya) និងនៅថ្ងៃទី០១ខែមេសាឆ្នាំ២០១៤ មន្ទីរសារការីជាតិព្រមទាំងសមាគមន៍សារការីក៏ចាប់ផ្តើមអនុវត្តន៍ប្រព័ន្ធe-Notarizationនេះដែរ[106]។

ដោយឡែកនៅក្នុងប្រទេសជប៉ុន សមាគមន៍សារការីមានប្រមាណ៥០០ ដែលមានសមាគមន៍សារការីចំនួន១នៅក្នុងការិយាល័យកិច្ចការច្បាប់ក្នុងតំបន់(法務局/The Legal Affairs Bureau) ឬការិយាល័យកិច្ចការច្បាប់តាមខេត្ត(地方法務局/The District Legal Affairs Bureau)នីមួយៗ[107]។ បន្ថែមលើតួនាទីដែលបានលើកឡើងខាងលើ សមាគមន៍សារការីជាតិជប៉ុនមានគោលដៅអភិវឌ្ឍន៍ប្រព័ន្ធសារការី ធ្វើឱ្យសេវាសារការី និងគុណភាពការងាររបស់សារការីកាន់តែមានភាពរីកចម្រើនតាមរយៈការផ្តល់ការណែនាំ និងទំនាក់ទំនងយ៉ាងជាប់លាប់ជាមួយសមាគមន៍សារការីក្នុងតំបន់នីមួយៗ ក៏ដូចជាសារការីឯករាជ្យនីមួយៗផងដែរ។ សមាគមន៍នេះ មានប្រធានមួយរូប អនុប្រធាន៦រូប ប្រធានផ្នែកចំនួន២៥រូប និងសវនករចំនួន២រូប ហើយកិច្ចប្រជុំសមញ្ញធ្វើឡើង១ដងក្នុងមួយឆ្នាំ។ ចំណែកកិច្ចប្រជុំរវាងប្រធាននៃផ្នែកនីមួយៗ ធ្វើឡើង៣ដងក្នុង១ឆ្នាំ។ សមាគមន៍សារការីជាតិនៃប្រទេសជប៉ុន មានគណកម្មាការចំនួន៨ ដែលជាសេនាធិការក្នុងការអនុវត្តតួនាទីរបស់ខ្លួនគឺៈ

១.គណកម្មាការវិន័យ (Regulation Committee)

២.គណកម្មការរៀបចំផែនការ (Planning Committee)

៣.គណកម្មការទំនាក់ទំនងសាធារណៈ (Public Relations Committee)

៤.គណកម្មការកិច្ចការបរទេស (Foreign Affair Committee)

៥.គណកម្មការរៀបចំគម្រូលិខិត (Document Form Committee)

[105]Japan National Notaries Association, *How to make good use of Japanese Notaries* [វិធីដើម្បីឲ្យការប្រើប្រាស់ប្រព័ន្ធសារការីជប៉ុនកាន់តែល្អ], ទំព័រទី១។

[106]ដូច៩៦។

[107]Japan National Notaries Association, *How to make good use of Japanese Notaries* [វិធីដើម្បីឲ្យការប្រើប្រាស់ប្រព័ន្ធសារការីជប៉ុនកាន់តែល្អ], ទំព័រទី៣។

៦.គណកម្មការកែសម្រួល និងបំពេញបន្ថែម (Editing Committee)

៧. គណកម្មការផ្តល់ការបញ្ជាក់ ឬ ផ្តល់យថាភូតភាពលើលិខិតតាមប្រព័ន្ធអេឡិចត្រូនិច (Electronic Notarization Committee)

៨.គណកម្មការទទួលបន្ទុកប្រព័ន្ធសារការី (Notarial System's Committee)។

ក្នុងនោះគណកម្មការនីមួយៗត្រូវបំពេញតួនាទីស្របតាមទិសដៅការងាររបស់ខ្លួន។ សមាគមន៍សារការីជាតិនៃប្រទេសជប៉ុនបានចូលជាសមាជិកនៃសហព័ន្ធសារការីអន្តរជាតិ [108] (The International Union of Notaries)ក្នុងឆ្នាំ១៩៧៧ លើសពីនេះសមាជិកនៃសមាគមន៍នេះធ្លាប់ត្រូវបានជ្រើសអោយបម្រើការងារក្នុងសហព័ន្ធសារការីផងដែរ ដែល៣នាក់ធ្លាប់ធ្វើជាអនុប្រធានសហព័ន្ធ និង២ ឬ ៣នាក់ផ្សេងទៀតធ្លាប់ធ្វើជាសមាជិកក្រុមប្រឹក្សានៃសហព័ន្ធ[109]។

[108] សហព័ន្ធសារការីអន្តរជាតិ(International Union of Notaries, Union Internationale du Notariat)ហៅកាត់**UINL**គឺជាអង្គការក្រៅរដ្ឋាភិបាល ដែលបង្កើតឡើងក្នុងគោលបំណងលើកកម្ពស់ រួមបញ្ចូលគ្នា និងអភិវឌ្ឍន៍តួនាទីព្រមទាំងសកម្មភាពការងាររបស់សារការីទូទាំងពិភពលោក ហើយធានានូវគោលជំហរឯករាជ្យមួយដែលប្រសើរចំពោះសេវាសារការីដែលនឹងផ្តល់អោយចំពោះបុគ្គលឯកជន និងសង្គមទាំងមូលតាមរយៈកិច្ចសហការជាមួយសមាជសារការី(Chambers of Notaries)។ សហព័ន្ធនេះបានបង្កើតឡើងនៅឆ្នាំ១៩៤៨ ដោយចូលរួមពីប្រទេសចំនួន១៩ ក្នុងនោះមានដូចជា៖ អាហ្សង់ទីន(Argentina) បែលជឹម(Belgium) បូលីវៀ(Bolivia) ប្រេស៊ីល(Brazil) កាណាដា(Canada) កូឡុំប៊ី(Colombia) កូសស្តារីកា(Costa Rica) គុយបា(Cuba)ឈីលី(Chile) អេក្វាដ័រ(Ecuador) បារាំង(France) អ៊ីតាលី(Italy) ម៉ិចស៊ិច(Mexico) ប៉ារ៉ាហ្គាយ(Paraguay) ប៉េរូ(Peru) ផូតូរីកូ(Puerto Rico) អេស្ប៉ាញ(Spain) ស្វីស(Switzerland) និងអ៊ុយរ៉ាហ្គាយ(Uruguay)។ នៅឆ្នាំ១៩៤៨ដដែល សេចក្តីព្រៀងធម្មនុញ្ញនៃសហព័ន្ធសារការីអន្តរជាតិត្រូវបានធ្វើឡើងដោយមានការជម្រុញយ៉ាងខ្លាំងពីសារការីសញ្ជាតិ អាហ្សង់ទីនឈ្មោះJosé Negri ហើយក៏មានការជួយពីសារការីសញ្ជាតិអេស្ប៉ាញឈ្មោះ Rafael Nuñez Lagosផងដែរ ជាលទ្ធផលធម្មនុញ្ញនៃសហព័ន្ធសារការីអន្តរជាតិត្រូវបានអនុម័តជាផ្លូវការដោយសភាសារការីនៅក្នុងទីក្រុងម៉ាទ្រីត ប្រទេសអេស្ប៉ាញ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៥០។ http://www.notaiodidomenico.it/NOTAIO/UINL.htm(កាលបរិច្ឆេទចូលទស្សនា៖ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦)

នាពេលបច្ចុប្បន្នបើគិតមកដល់ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ សហព័ន្ធនេះមានសមាជិកចំនួន៨៦ ក្នុងតំបន់អាស៊ីមានចំនួន៦ប្រទេសគឺ **ប្រទេសជប៉ុន**ចូលជាសមាជិកក្នុងឆ្នាំ១៩៧៧ **ឥណ្ឌូនេស៊ី**ចូលជាសមាជិកក្នុងឆ្នាំ១៩៩២ **ចិន**ចូលជាសមាជិកក្នុងឆ្នាំ២០០៣ **កូរ៉េខាងត្បូង**ចូលជាសមាជិកក្នុងឆ្នាំ២០១០ **ម៉ុងហ្គោលី**ចូលជាសមាជិកក្នុងឆ្នាំ២០១២ **វៀតណាម**ចូលជាសមាជិកក្នុងឆ្នាំ២០១៣។ http://www.uinl.org/1/home-page(កាលបរិច្ឆេទចូលទស្សនា៖ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៦)

[109] ដូច១០៧។

# សេចក្តីសន្និដ្ឋាន

សារការី ជាអ្នកវិជ្ជាជីវៈច្បាប់ដែលត្រូវអនុវត្តមុខងាររបស់ខ្លួនក្នុងជំហរអព្យាក្រឹត្យដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់បុគ្គលឯកជន ព្រមទាំងការពារនូវវិវាទដែលនឹងអាចកើតមានឡើងនាពេលអនាគតតាមរយៈការផ្តល់យថាភូតភាព និងផ្តល់ការបញ្ជាក់លើលិខិតឯកជនណាមួយ ដែលនេះត្រូវបានគេហៅថាជាប្រព័ន្ធគតិយុត្តមានលក្ខណៈការពារទុកជាមុន។ ជាគោលការណ៍សារការីមានតួនាទី៣ធំៗគឺ ទី១៖ផ្តល់យថាភូតភាពលើលិខិតណាមួយដើម្បីឲ្យក្លាយជាលិខិតយថាភូត ទី២៖ផ្តល់ការបញ្ជាក់លើលិខិតឯកជន ឬ លក្ខន្តិកៈក្រុមហ៊ុន និងទី៣៖ផ្តល់ការបញ្ជាក់ពីអត្ថិភាពនៃលិខិតឯកជនណាមួយ ដើម្បីឲ្យច្បាស់ថាលិខិតនោះពិតជាបានបង្កើតឡើងដូចមានក្នុងថ្ងៃខែចុះក្នុងកាលបរិច្ឆេទពិតប្រាកដមែន។ ក្នុងនាមជាអ្នកជំនាញច្បាប់ សារការីត្រូវត្រួតពិនិត្យ ទៅលើនីតិវិធី ឬ អត្ថន័យដែលមានកំណត់ក្នុងលិខិតទាំងនោះ ថាតើមានភាពត្រឹមត្រូវតាមទម្រង់ច្បាប់ឬយ៉ាងណា? ជាពិសេសគឺការជៀសវាងឲ្យបាននូវវិវាទនាពេលអនាគត។ លិខិតដែលបានធ្វើឡើងដោយសារការីជាលិខិតដែលមានអានុភាពគតិយុត្តខ្ពស់ជាងលិខិតធម្មតា ឬ មានអានុភាពខ្ពស់ជាងលិខិតដែលធ្វើឡើងដោយមេធាវី ជាក់ស្តែងគឺអានុភាពនៃការអនុវត្តដោយបង្ខំ ក្នុងករណីដែលមានបញ្ញត្តិអំពីចំណុចនេះ ក្នុងកិច្ចសន្យាដែលធ្វើឡើងដោយមានការបញ្ជាក់ដោយសារការី។

ចំពោះមូលហេតុដែលលក្ខន្តិកៈក្រុមហ៊ុន ត្រូវតែទទួលបានការបញ្ជាក់របស់សារការីនោះគឺដោយសារតែការបង្កើតនីតិបុគ្គលមួយសំខាន់បំផុតគឺលក្ខន្តិកៈនៃនីតិបុគ្គល ដោយសារតែវាជាបទវិន័យគ្រឹះដែលបង្ហាញអំពីគោលបំណងការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័ននោះ ដូចនេះសារការីត្រូវតែពិនិត្យលើអនុភាពផ្នែកច្បាប់រាល់គ្រប់ចំណុចទាំងអស់ដែលមានកំណត់ក្នុងលក្ខន្តិកៈ បើមិនដូច្នោះទេនីតិបុគ្គលនោះមិនអាចបង្កើតបានឡើយ។ ជារួមយើងអាចសន្និដ្ឋានបានថា សារការីជាបុគ្គលដែលមានតួនាទីការពារវិវាទកុំឲ្យកើតមានឡើង ស្របពេលដែលតុលាការជាស្ថាប័នដោះស្រាយវិវាទដែលបានកើតមានឡើងរួចទៅហើយ ដូចនេះសារការីដើរតួនាទីសំខាន់បំផុតក្នុងទំនាក់ទំនងរវាងបុគ្គលឯកជន និងឯកជន។

ដោយសារតែសារការីមានតួនាទីដ៏សំខាន់បែបនេះហើយ ទើបទាមទារឲ្យមានចំណេះដឹងផ្នែកច្បាប់ឲ្យបានទូលំទូលាយ ។ ត្រង់ចំណុចនេះបើយើងក្រឡេកមើលទៅរបបសារការីក្នុងប្រទេសកម្ពុជា គឺមានមធ្យោបាយចំនួនពីរដើម្បីក្លាយជាសារការី។ មធ្យោបាយទី១គឺមានចែងក្នុងសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈសារការី ដែលវាជាលក្ខខណ្ឌដ៏តឹងរឹងមួយ។ ពោលគឺត្រូវឆ្លងកាត់ការបណ្តុះបណ្តាល ហើយដើម្បីទទួលបានការបណ្តុះបណ្តាល បុគ្គលនោះត្រូវតែទទួលការប្រឡងប្រជែង។ ក្រោយជាប់ការប្រឡងប្រជែងជាស្ថាពរ បេក្ខភាពសារការីត្រូវទទួលការបណ្តុះបណ្តាលឆ្លាស់សម្រាប់

រយៈពេល១ឆ្នាំ និងកម្មសិក្សា និងការបណ្តុះបណ្តាលឆ្លាស់ សម្រាប់ការចុះកម្មសិក្សាគឺមានរយៈពេល៦ខែ រីឯការបណ្តុះបណ្តាលឆ្លាស់គឺមានរយៈពេល៩ខែ។ បន្ទាប់ពីប្រឡងបញ្ចប់រួចរាល់ជាស្ថាពរ សិស្សសារការីត្រូវតាក់តែងរបាយការណ៍កម្មសិក្សាដាក់ជូនសាលាភូមិន្ទវិជ្ជាជីវៈសារការី ហើយក្រោយពីទទួលបានការតែងតាំងជាសារការីដោយក្រសួងយុត្តិធម៌ សិស្សសារការីទាំងអស់នោះនឹងទទួលមុខងារជាសារការីដែលអាចអនុវត្តមុខងាររបស់ខ្លួនបាន។ ចំណែកឯមធ្យោបាយទី២វិញនោះគឺការតែងតាំងដោយប្រកាស ឬ អនុក្រឹត្យ ដោយមិនមានឆ្លងកាត់ការប្រឡងប្រជែងនោះទេ។ ចំពោះសារការីដែលតែងតាំងដោយប្រកាស គឺដោយមូលហេតុរាជរដ្ឋាភិបាលត្រូវការចាំបាច់ឲ្យមានវត្តមាននៅតាមបណ្តាខេត្តទាំងអស់ក្នុងប្រទេស ទើបមានការតែងតាំងបុគ្គលដែលកំពុងមានមុខងារជាមន្ត្រីរាជការ ឲ្យទទួលបានមុខងារមួយថ្មីបន្ថែមទៀត រីឯសារការីដែលតែងតាំងដោយអនុក្រឹត្យវិញ ក៏ដោយសារមូលហេតុតម្រូវការចាំបាច់នៃវត្តមានរបស់សារការី ដើម្បីជួយសម្រួលដល់ដំណើរការជំនួញ ក៏ដូចជាសម្រួលដល់បញ្ហាមួយចំនួនទាក់ទងនឹងទំនាក់ទំនងរវាងបុគ្គលឯកជន។

ផ្ទុយទៅវិញ ចំពោះសារការីនៃប្រទេសជប៉ុន ច្បាប់ស្តីពីសារការីឆ្នាំ១៩០៨ បានកំណត់នូវមធ្យោបាយ៣ដើម្បីអាចក្លាយជាសារការីគឺ ទី១៖ឆ្លងកាត់ប្រឡងប្រជែង ទី២៖តាមរយៈការជ្រើសតាំងពីក្នុងចំណោមអ្នកច្បាប់ និងទី៣៖តាមរយៈការជ្រើសតាំងពីក្នុងចំណោមបុគ្គលដែលមានបទពិសោធន៍ផ្នែកច្បាប់។ ចំពោះមធ្យោបាយទី១ ត្រូវបានអនុវត្តតែនៅក្នុងសម័យមេជីតែប៉ុណ្ណោះ ពោលគឺនៅក្នុងពេលដែលរបបសារការីនៃប្រទេសជប៉ុន ត្រូវបានគ្រប់គ្រងដោយបទប្បញ្ញត្តិស្តីពីសារការី ព្រោះក្រោយការអនុម័ត និងបានធ្វើវិសោធនកម្មច្បាប់ស្តីពីសារការីមក ការប្រឡងប្រជែងមិនត្រូវបានរៀបចំឡើងនោះទេ។ ចំណែកឯមធ្យោបាយទី២វិញ គឺបុគ្គលដែលត្រូវបានជ្រើសតាំងនោះភាគច្រើនជាអ្នកច្បាប់ដែលមានជាអាទិ៍ អតីតចៅក្រម ព្រះរាជអាជ្ញា ឬ មេធាវីជាដើម។ រីឯមធ្យោបាយទី៣វិញ គឺបុគ្គលដែលត្រូវបានជ្រើសតាំងនោះភាគច្រើនជាអតីតប្រធានការិយាល័យច្បាប់តាមតំបន់ ឬ តាមខេត្ត។ បន្ទាប់មកត្រូវដាក់ពាក្យសុំពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ តាមរយៈការិយាល័យច្បាប់តាមតំបន់ ឬ តាមខេត្ត ហើយក្រោយពីទទួលបានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ហើយ បុគ្គលនោះនឹងទទួលបានមុខងារជាសារការី។

ចំពោះទីកន្លែងដែលសារការីនៃប្រទេសទាំងពីរត្រូវអនុវត្តមុខងារ ក៏មិនសូវជាខុសគ្នានោះដែរ ព្រោះពួកគេត្រូវអនុវត្តមុខងាររបស់ខ្លួននៅទីកន្លែងមួយដែលហៅថា "មន្ទីរ" ប៉ុន្តែនីតិវិធីក្នុងការបង្កើតមន្ទីរសារការីនេះគឺមានភាពខុសគ្នា ដោយនៅក្នុងប្រទេសកម្ពុជា ដើម្បីអាចបង្កើតមន្ទីរសារការីបាន ដាច់ខាតត្រូវតែតម្កល់លុយចំនួន៦០០លានរៀលនៅក្នុងធនាគារជាតិនៃកម្ពុជា ដើម្បីធានាក្នុងការអនុវត្តមុខងាររបស់ខ្លួន ហើយនេះជាលក្ខខណ្ឌដាច់ខាតមួយដែលសារការីត្រូវតែបំពេញ។

ត្រង់ចំណុចនេះ អ្វីដែលយើងគួរឲ្យកត់សម្គាល់នោះគឺ នៅក្នុងប្រកាសដែលចែងអំពីការតែងតាំងសារការី គឺមិនបានបញ្ញត្តិឲ្យបានច្បាស់អំពីទីកន្លែងដែលពួកគាត់ត្រូវអនុវត្តមុខងារនោះទេ ប៉ុន្តែបើយើងក្រឡេកមើលក្នុងអនុក្រឹត្យដែលតែងតាំងសារការីវិញ គឺគ្រប់អនុក្រឹត្យទាំងអស់មានបញ្ញត្តិអំពីទីកន្លែងដែលសារការីត្រូវអនុវត្តមុខងារ ដែលគេហៅថា "មន្ទីរ" ដោយភ្ជាប់ទៅនឹងឈ្មោះសម្រាប់សម្គាល់មន្ទីរសារការីនីមួយៗ។ ចំណែកឯនៅក្នុងប្រទេសជប៉ុនវិញ នីតិវិធីក្នុងការបង្កើតសារការីហាក់មានភាពងាយស្រួលជាងប្រទេសកម្ពុជា គឺមិនតម្រូវឲ្យមានការតម្កល់ប្រាក់ធានានោះទេ ប៉ុន្តែតម្រូវឲ្យមានការដាក់ពាក្យស្នើសុំបង្កើតទៅកាន់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌តាមរយៈការិយាល័យច្បាប់តាមតំបន់ ឬ តាមខេត្ត ដោយភ្ជាប់ទៅជាមួយនូវឯកសារចំនួន៤ទាក់ទងនឹងមន្ទីរសារការីដែលខ្លួនបម្រុងនឹងបង្កើត ដែលមានដូចជា ទី១៖ទីតាំងដែលនឹងបង្កើតជាមន្ទីរសារការី ទី២៖ទម្រង់នៃអាគារ ទី៣៖ស្ថានភាពទាំងមូលនៃអាគារ ទី៤៖លិខិតដែលមានការតែងតាំងខ្លួនជាសារការី ហើយបន្ទាប់ពីពិនិត្យចប់សព្វគ្រប់ថាបានបំពេញគ្រប់លក្ខខណ្ឌទាំងអស់ហើយ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌នឹងផ្តល់ការអនុញ្ញាញឲ្យដំណើរការមន្ទីរសារការីនោះ។

# អនុសាសន៍

ក្រោយពីបានសិក្សា និងស្រាវជ្រាវអំពីលក្ខខណ្ឌនៃការជ្រើសតាំងសារការី និងនីតិវិធីនៃការបង្កើតមន្ទីរសារការីនៃប្រទេសកម្ពុជា និងប្រទេសជប៉ុនរួចមក យើងអាចទទួលបាននូវមតិយោបល់ដើម្បីផ្ដល់ជាអនុសាសន៍សំខាន់ៗ សម្រាប់ជាប្រយោជន៍ដល់ប្រព័ន្ធសារការីរបស់ប្រទេសទាំងពីរដូចខាងក្រោម៖

## ❖ ចំពោះប្រទេសកម្ពុជា

- **ទី១៖** លក្ខខណ្ឌក្នុងការជ្រើសតាំងសារការី។ ចំពោះលក្ខខណ្ឌនៃការជ្រើសតាំងសារការីនៃប្រទេសកម្ពុជា បើមើលទៅលក្ខខណ្ឌនៃការទទួលមុខងារជាសារការីហាក់មានភាពលំបាក និងតឹងរ៉ឹងខ្លាំង សម្រាប់សារការីដែលជ្រើសរើសមធ្យោបាយតាមរយៈការបណ្ដុះបណ្ដាល ស្របពេលនឹងបុគ្គលមួយចំនួនទៀតទទួលបានមុខងារជាសារការី ត្រឹមតែតាមរយៈការតែងតាំងដោយអនុក្រឹត្យដោយមិនចាំបាច់មានការប្រឡងប្រជែង។ ចំណុចនេះហាក់មិនមានភាពយុត្តិធម៌ចំពោះសារការីដែលទទួលបានការបណ្ដុះបណ្ដាល ព្រោះថាបើយើងមើលទៅលើមុខវិជ្ជាដែលសិស្សសារការីត្រូវប្រឡងដើម្បីចូលរៀនក្នុងសាលាភូមិន្ទវិជ្ជាជីវៈសារការី ហាក់ដូចជាមានភាពលំបាកជាងវិជ្ជាជីវៈដទៃទៀត (ក្រឡាបញ្ជី មេធាវី.....) ដែលនេះសបញ្ជាក់ឲ្យឃើញពីភាពចាំបាច់នៃសារការីដែលតម្រូវនូវការឆ្លងកាត់វគ្គបណ្ដុះបណ្ដាលណាមួយឲ្យបានត្រឹមត្រូវ មិនមែនកើតឡើងដោយងាយស្រួល ពោលគឺត្រឹមតែការតែងតាំងប៉ុណ្ណោះនោះទេ។ ចំពោះចំណុចនេះ យើងក៏បានពិចារណាលើវត្តមានរបស់សារការីដែលសង្គមកម្ពុជាកំពុងត្រូវការជាចាំបាច់ ដែលវាជាមូលហេតុដែលបណ្ដាលឲ្យសារការីត្រូវបានតែងតាំងជាបន្តបន្ទាប់ដោយមិនចាំបាច់ឆ្លងកាត់ការបណ្ដុះបណ្ដាល ប៉ុន្តែចំពោះសិស្សសារការីជំនាន់ទី១ ដែលទើបតែបញ្ចប់ការប្រឡងរបស់ខ្លួនក្នុងខែមេសា ឆ្នាំ២០១៦ថ្មីៗនេះ បន្ទាប់ពីបានទទួលបានការតែងតាំងជាសារការីដោយក្រសួងយុត្តិធម៌ហើយ ហាក់មានចំនួនតិចតួចនៅឡើយដែលកំពុងអនុវត្តមុខងាររបស់ខ្លួនក្នុងមន្ទីរសារការី។ ដូចនេះដោយសារតែមានសារការីដែលទទួលការបណ្ដុះបណ្ដាលរួចជាស្រេចគឺសារការីជំនាន់ទី១ រាជរដ្ឋាភិបាលកម្ពុជាជាពិសេសក្រសួងយុត្តិធម៌គួរពិចារណាជំរុញឲ្យសារការីដែលទទួលបានការបណ្ដុះបណ្ដាលទាំងនោះ អាចអនុវត្តការងាររបស់ខ្លួនក្នុងទីកន្លែងណាមួយត្រឹមត្រូវ និងពិចារណាឲ្យបានលម្អិត ដោយគួរតែកុំមើលរំលងនូវសិស្សសារការីជំនាញដែលមានស្រាប់ មុននឹងតែងតាំងបុគ្គលផ្សេងទៀតដែលមិនបានទទួលបានការបណ្ដុះបណ្ដាល។ វាគឺមធ្យោបាយមួយក្នុងជម្រុញ និងលើកទឹកចិត្តឲ្យសិស្សសារការីជំនាន់ទី១ផង ហើយក៏ជាដំណើរការវិវត្តន៍មួយដ៏មានប្រសិទ្ធិភាពដើម្បីលើកកម្ពស់ប្រព័ន្ធសារការីក្នុងប្រទេសកម្ពុជាផងដែរ។

- **ទី២៖** លក្ខខណ្ឌក្នុងការបង្កើតមន្ទីរសារការី។ ចំពោះលក្ខខណ្ឌក្នុងការបង្កើតមន្ទីរសារការីនៅក្នុងប្រទេសកម្ពុជាហាក់មានភាពតឹងរឹងជាងនៅក្នុងប្រទេសជប៉ុន ដូចដែលបានរៀបរាប់ខាងលើ ដើម្បីបង្កើតមន្ទីរសារការី គឺតម្រូវឲ្យតម្កល់ប្រាក់ចំនួន៦០០លានរៀល ក្នុងធនាគាជាតិនៃកម្ពុជា។ មូលហេតុនៃការតម្រូវឲ្យតម្កល់ប្រាក់នោះ គឺដើម្បីធានាការទទួលខុសត្រូវរបស់ខ្លួនក្នុងពេលអនុវត្តមុខងាររបស់សារការីករណីកើតមាននូវកំហុសដោយចេតនា ឬ ដោយអចេតនាណាមួយ។ ត្រង់ចំណុចនេះយើងគួរចោទជាសំណួរថា តើសិស្សសារការីដែលទទួលបានការបណ្ដុះបណ្ដាល សុទ្ធតែមានលទ្ធភាពតម្កល់ប្រាក់ធានា៦០០លានរៀលនោះដែរឬទេ? ដែលនេះគឺជាផលលំបាកចំពោះសិស្សសារការីដែលក្រោយពីបញ្ចប់ការបណ្ដុះបណ្ដាលហើយ មិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបើកមន្ទីរសារការីដើម្បីអនុវត្តមុខងាររបស់ខ្លួន។ ហើយនេះគឺជាមូលហេតុដែលធ្វើឲ្យដំណើរវិវត្តន៍នៃប្រព័ន្ធសារការីមានការរាំងស្ទះ ជាពិសេសសារការីដែលទទួលបានមុខងារតាមរយៈការបណ្ដុះបណ្ដាលមិនអាចអនុវត្តមុខងាររបស់ខ្លួនបានដោយងាយស្រួល ពោលគឺទោះបីជាបានទទួលបានមុខងារជាសារការីក៏ដោយ បើសិនជាគាត់មិនមានប្រាក់តម្កល់ចំនួន៦០០លានរៀលទេ គាត់មិនអាចបង្កើតមន្ទីរសារការីបានទេ។ ជាការកត់សម្គាល់ នៅក្នុងអនុក្រឹត្យស្ដីពីការបង្កើតមន្ទីរសារការី មានតែសារការីដែលទទួលបានការបណ្ដុះបណ្ដាលចំនួន៥នាក់តែប៉ុណ្ណោះ ដែលកំពុងអនុវត្តមុខងាររបស់ខ្លួនក្នុងមន្ទីរសារការីគិតត្រឹម ខែកក្កដា ឆ្នាំ២០១៦ ដែលមានដូចជា៖ ១.សារការី បូន សារៈមុនី ២.សារការី សែន សេងថៃ ៣.សារការី អេង គឹមសូត ៤.សារការី កាន់ សុទ្ធប៉ូលីន ៥.សារការី ហ៊ី ថុនា។ ចំណុចមួយទៀត គឺត្រង់ថាតើគួរតែបន្ថយប្រាក់តម្កល់ធានាដែរឬក៏អត់? បើសិនជាយើងធ្វើការសម្រេចបន្ថយប្រាក់តម្កល់នោះ ទំហំនៃភាពទទួលខុសត្រូវរបស់សារការីនៃការអនុវត្តមុខងារក៏បន្ថយទៅតាមនោះដែរ។ ចំពោះបញ្ហាទាំងនេះគួរតែស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងយុត្តិធម៌ស្វែងរកដំណោះស្រាយដ៏សមស្របមួយដើម្បីសម្របសម្រួលឲ្យមានអព្យាក្រឹត្យភាព ទាំងចំពោះសិស្សសារការីដែលបញ្ចប់ការបណ្ដុះបណ្ដាល និងអតិថិជនដែលមកទទួលយកសេវារបស់សារការី ដើម្បីឲ្យពួកគាត់មានជំនឿជាក់លើកិច្ចគតិយុត្តដែលសារការីបានបំពេញ។

- **ទី៣៖** ការផ្ដល់មុខងារបន្ថែមដល់បុគ្គលណាម្នាក់ឲ្យក្លាយជាសារការី។ បើក្រឡេកទៅមើលអនុក្រឹត្យស្ដីពីការបង្កើតមន្ទីរសារការីទាំង១១នោះ យើងឃើញថាបុគ្គលដែលត្រូវទទួលបានមុខងារជាសារការីនោះមិនមែនសុទ្ធតែជាសារការីដែលបានបណ្ដុះបណ្ដាលនោះទេ គឺមានដូចជាមេធាវី និងមន្ត្រីរបស់រាជរដ្ឋាភិបាល ជាដើម។ ជាក់ស្ដែង លោក បែន សុនសម័យ (មន្ទីរសារការីបែនសុន សម័យ) និងលោក ទូត លុច (មន្ទីរសារការី លុច ស៊ីអេចឌី) គឺមានមុខងារជាមេធាវីរួចស្រេចទៅហើយ បន្ថែមពីលើមុខងារដែលអនុក្រឹត្យផ្ដល់ឲ្យនោះ គឺគាត់ក្លាយជាមេធាវីសារការី។ លោក ស៊ុក ស៊ីផាន់ណា

មានមុខងារដើមជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងលោក ផូវ សំភី មានមុខងារដើមជាប្រធានអគ្គនាយកស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌ របស់ក្រសួងយុត្តិធម៌ ។ ចំពោះការតែងតាំងមេធាវីជាសារការី ហាក់មិនសូវមានភាពត្រឹមត្រូវក្នុងការអនុវត្តនូវវិជ្ជាជីវៈច្បាប់ក្នុងប្រទេសកម្ពុជា ដោយមូលហេតុថាសារការី និងមេធាវី គឺជាវិជ្ជាជីវៈដែលចែកដាច់ចេញពីគ្នា មិនអាចមានបុគ្គលម្នាក់ជាមេធាវីផង ជាសារការីផងក្នុងពេលតែមួយនោះបានទេ។ ដោយសារមុខងាររបស់មេធាវី គឺជាតំណាងឲ្យកូនក្តីក្នុងរឿងរដ្ឋប្បវេណី និងការពារឲ្យកូនក្តីក្នុងរឿងព្រហ្មទណ្ឌ រីឯមុខងាររបស់សារការីវិញ គឺប្រឹក្សាយោបល់ តាក់តែង និងផ្តល់យថាភូតភាព ឬ ការបញ្ជាក់លើលិខិតណាមួយ ដើម្បីឲ្យលិខិតនោះមានយថាភូតភាព។ ដូចនេះ បើសម្រចឲ្យបុគ្គលមួយរូបមានមុខងារជាមេធាវីផង ជាសារការីផង វាអាចបណ្តាលឲ្យបុគ្គលម្នាក់នោះបែងចែកមិនដាច់អំពីមុខងាររបស់ខ្លួន និងជាមូលហេតុដែលអាចធ្វើឲ្យប៉ះពាល់ដល់មុខងាររបស់បុគ្គលដែលមានងារជាសារការីតែមួយផងដែរ។

យើងទទួលស្គាល់ពីភាពចាំបាច់តម្រូវឲ្យបន្ថែមមុខងារដល់មេធាវីឲ្យក្លាយជាមេធាវីសារការីក្នុងបរិបទឆ្នាំ២០០១ ដែលនៅមិនទាន់មានវត្តមានសារការីណាម្នាក់នៅឡើយ ប៉ុន្តែនាពេលបច្ចុប្បន្នមានសារការីជំនាញដែលបានទទួលការបណ្តុះបណ្តាលយ៉ាងត្រឹមត្រូវហើយនោះ រាជរដ្ឋាភិបាលគួរលើកកម្ពស់ និង ជំរុញ ឲ្យពួកគាត់បានទទួលនូវភាពងាយស្រួលក្នុងការអនុវត្តមុខងាររបស់ខ្លួន ជៀសវាងការភ័យខ្លាចនូវកង្វះទីផ្សារការងារ។ ចំណែកឯការផ្តល់មុខងារជាសារការីឲ្យដល់មន្ត្រីរាជការសាធារណៈវិញ ត្រូវបានគេលើកឡើងថា "តើអាចមានវិសមិតភាពរវាងមុខងារដើមរបស់បុគ្គលនោះដែរឬទេ?" ចំពោះចំណុចនេះ បើក្រឡេកទៅមើលច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃ ព្រះរាជាណាចក្រកម្ពុជា យើងឃើញថាមន្ត្រីរាជការសាធារណៈមិនមានវិសមិតភាពជាមួយនឹងមុខងារសារការីនោះទេ ព្រោះមិនមានបញ្ញត្តិណាមួយបានចែងអំពីបញ្ហានេះ។ ម្យ៉ាងវិញទៀត ដោយសារតែប្រទេសកម្ពុជា នាពេលបច្ចុប្បន្នមិនទាន់មានច្បាប់ស្តីពីលក្ខន្តិកៈសារការី ទើបយើងមិនទាន់ដឹងច្បាស់ថាតើមុខងារជាមន្ត្រីរាជការសាធារណៈអាចមានវិសមិតភាពជាមួយមុខងារសារការីដែរឬទេ?។

- **ទី៤៖** ការអនុវត្តមុខងារសារការីពីរក្នុងពេលតែមួយ។ ដោយសារកត្តាចាំបាច់ និងតម្រូវនូវវត្តមានរបស់សារការីជាបន្ទាន់ រាជរដ្ឋាភិបាលក៏បានចេញប្រកាសស្តីពីការតែងតាំងមន្ត្រីទទួលបន្ទុកសារការី។ ក្នុងចំណុចនេះ ករណីដែលក្នុងអំឡុងពេលអនុវត្តមុខងារមន្ត្រីទទួលបន្ទុកសារការី នោះត្រូវបានអនុក្រឹត្យតែងតាំងខ្លួនលើមុខងារបច្ចុប្បន្នជាសារការីដែលអនុវត្តមុខងារក្នុងនាមមន្ទីរ តើបុគ្គលនោះអនុវត្តមុខងាររបស់ខ្លួនក្នុងនាមមន្ត្រីទទួលបន្ទុកសារការី ឬ ក្នុងនាមសារការីដែលតំណាងឲ្យមន្ទីររបស់ខ្លួន?។ ជាក់ស្តែងនៅក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌លេខ ៣២ កយ.ប្រក/ ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០១២ ស្តីពីការតែងតាំងមន្ត្រីទទួលបន្ទុកសារការី បានតែងតាំងឯកឧត្តម ផូវ សំភី ជា

មន្រ្តីទទួលបន្ទុកសារការីក្នុងរាជធានីភ្នំពេញ ហើយនាថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៣២ ស្តីពីការបង្កើតមន្ទីរសារការី ខេមរា ដោយមាន ឯកឧត្តម ផូវ សំភី ជាសហប្រធាន។ ត្រង់ចំណុចនេះ យើងគួរពិចារណាថាបើសិនជាគាត់មានបំណងអនុវត្តក្នុងនាមមន្រ្តីទទួលបន្ទុកកិច្ចការសារការី គាត់មិនចាំបាច់តម្កល់ប្រាក់ធានាចំនួន៦០០លានរៀល ដើម្បីបង្កើតមន្ទីរសារការីនោះដែរ។ ដែលនេះជាការបង្ហាញឲ្យឃើញថា ប្រកាសរបស់ក្រសួងយុត្តិធមិហាក់មិនមានប្រសិទ្ធិភាពអនុវត្តចំពោះមន្រ្តីដែលបានតែងតាំងឲ្យទទួលបន្ទុកកិច្ចការសារការី។

### ❖ ចំពោះប្រទេសជប៉ុន

- **ទី១៖** លក្ខខណ្ឌដើម្បីក្លាយជាសារការីក្នុងប្រទេសជប៉ុន ផ្តោតជាចម្បងទៅលើបទពិសោធន៍ផ្នែកច្បាប់ ជាងការបណ្តុះបណ្តាល។ ដូចដែលបានរៀបរាប់នៅក្នុងផ្នែកទី២នៃជំពូកទី២ខាងលើនេះច្បាប់ស្តីពីសារការីបានបញ្ញត្តិអំពីលក្ខខណ្ឌអាចក្លាយជាសារការីតាមរយៈការប្រឡងប្រជែងដើម្បីទទួលបានការបណ្តុះបណ្តាល ប៉ុន្តែការប្រឡងប្រជែងមិនត្រូវបានរៀបចំឲ្យមានឡើយ។ ផ្ទុយទៅវិញនៅក្នុងច្បាប់ដដែលនេះ បានអនុញ្ញាតដល់បុគ្គលទាំងឡាយណាដែលមានបទពិសោធន៍ទាក់ទងនឹងច្បាប់ស្របតាមរយៈពេលដែលបានកំណត់ បុគ្គលនោះដនឹងអាចក្លាយជាសារការីបានតាមរយៈការតែងតាំងដោយរដ្ឋមន្រ្តីក្រសួងយុត្តិធមិ។ ចំណុចដែលគួរឲ្យកត់សម្គាល់នៅក្នុងលក្ខខណ្ឌដើម្បីក្លាយជាសារការីនៃប្រទេសជប៉ុននោះគឺការមិនតែងតាំងបន្ថែមលើមុខងារបច្ចុប្បន្នរបស់បុគ្គលដែលដាក់ពាក្យស្នើសុំនោះ ពោលគឺបុគ្គលនោះត្រូវមានមុខងារតែមួយគត់គឺសារការី។ នេះគឺជាចំណុចដែលបង្ហាញអំពីភាពច្បាស់លាស់នៃការអនុវត្តមុខងារសារការីក្នុងប្រទេសជប៉ុន។
- **ទី២៖** ចំពោះលក្ខខណ្ឌនៃការបង្កើតមន្ទីរសារការីនៃប្រទេសជប៉ុន គឺមិនតម្រូវឲ្យមានការតម្កល់ប្រាក់អ្វីនោះឡើយគ្រាន់ត្រូវជូនដំណឹងពាក់ព័ន្ធនឹងមន្ទីរដែលខ្លួនបម្រុងនឹងដំណើរការមួយចំនួនទៅកាន់ការិយាល័យកិច្ចការច្បាប់នៅតាមខេត្ត និង តាមតំបន់តែប៉ុណ្ណោះ។ នេះគឺជាការសម្រួលដល់ការអនុវត្តវិជ្ជាជីវៈសារការី។ លើសពីនេះទៅទៀត ប្រទេសជប៉ុនបានបង្កើតឲ្យមានគណៈសារការីតាមតំបន់និងគណៈសារការីជាតិ ដើម្បីពង្រឹងប្រព័ន្ធសារការីរបស់គេផងដែរ។

បើយើងក្រឡេកមើលពីដំណើរវិវត្តន៍នៃប្រព័ន្ធសារការីនៃប្រទេសទាំងពីរ ប្រព័ន្ធសារការីនៃប្រទេសកម្ពុជាហាក់នៅមានភាពទន់ខ្សោយជាង និងមានភាពខ្វះចន្លោះច្រើនជាប្រព័ន្ធសារការីនៃប្រទេសជប៉ុនទាំងលិខិតបទដ្ឋានសម្រាប់គ្រប់គ្រងសារការី និងចំនួនសារការីដែលកំពុងអនុវត្តមុខងារនាពេលបច្ចុប្បន្ន។ យោងតាមការស្រាវជ្រាវខាងលើ ប្រព័ន្ធសារការីនៃប្រទេសជប៉ុនមានការ

រៀបចំគ្រប់គ្រងរឹងមាំ និងច្បាស់លាស់ទាំងសារការីតាមខេត្ត ក៏ដូចជាតាមតំបន់នីមួយៗ លើសពីនេះគេមានស្ថាប័នសម្រាប់ពង្រឹង និងអភិវឌ្ឍន៍ប្រព័ន្ធសារការីទូទាំងប្រទេសផងដែរ ដែលចំណុចទាំងអស់នេះបានបង្ហាញអំពីវឌ្ឍនភាព និង ការរីកចម្រើននៃប្រព័ន្ធសារការីរបស់ប្រទេសជប៉ុន។ ចំពោះប្រព័ន្ធសារការីនៃប្រទេសកម្ពុជា ចាំបាច់ត្រូវតែមានការយកចិត្តទុកដាក់ ក៏ដូចជាពង្រឹងបន្ថែមទៀត ដើម្បីរៀបចំវិជ្ជាជីវៈមួយនេះឲ្យមានការអភិវឌ្ឍដូចជាវិជ្ជាជីវៈច្បាប់ដទៃទៀត ព្រោះសារការីជាតួអង្គសំខាន់បំផុតក្នុងការទប់ស្កាត់វិវាទរវាងបុគ្គល និង បុគ្គល ព្រមទាំងធានានូវសុវត្ថិភាពនៃប្រតិបត្តិការជំនួញ ដើម្បីជួយអភិវឌ្ឍន៍សេដ្ឋកិច្ចនៃប្រទេសកម្ពុជាឲ្យមានការរីកចម្រើន៕

## ឯកសារយោង

### ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាតិ

- ព្រះរាជក្រមលេខ៩១០នស ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ ១៩៥៤។
- ព្រះរាជក្រឹត្យលេខ នស/រកត/០១០៥/០១៩ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥។
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧។
- ក្រមនីតិវិធីរដ្ឋប្បវេណី នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។
- ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥។
- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧,៣១ ឧសភា ២០០១។
- ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤,៣០ សីហា ២០០១។
- អនុក្រឹត្យលេខ ៥០៥ អនក្រ.តត. ស្តីពីការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, ០៤ ធ្នូ ២០០១។
- អនុក្រឹត្យលេខ ១៤៤ អនក្រ.បក ស្តីពីការទទួលស្គាល់មន្ទីសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា, ២៣ កញ្ញា ២០០៨។
- អនុក្រឹត្យលេខ២៦១អនក្រ.បក ស្តីពីការបង្កើតមន្ទីសារការី សេដ្ឋាវិទូ នៃព្រះរាជាណាចក្រកម្ពុជា, ២៥ កញ្ញា ២០១៤។
- អនុក្រឹត្យលេខ ២២៤ អនក្រ.បក ស្តីពីការបង្កើតមន្ទីសារការី វាណិជ្ជ និងសហភាតា នៃព្រះរាជាណាចក្រកម្ពុជា, ០១ សីហា ២០១៤។
- អនុក្រឹត្យលេខ ៣២ អនក្រ.បក ស្តីពីការបង្កើតមន្ទីសារការី ខេមរា នៃព្រះរាជាណាចក្រកម្ពុជា, ១២ មីនា ២០១៥។
- អនុក្រឹត្យលេខ ៣៣ អនក្រ.បក ស្តីពីការបង្កើតមន្ទីសារការី នីតិនិវន្តរ៍ នៃព្រះរាជាណាចក្រកម្ពុជា, ១២ មីនា ២០១៥។
- អនុក្រឹត្យលេខ ១១៨ អនក្រ.បក ស្តីពីការបង្កើតមន្ទីសារការី សុក ស៊ីផាន់ណា នៃព្រះរាជាណាចក្រកម្ពុជា, ១១ កញ្ញា ២០១៥។
- អនុក្រឹត្យលេខ ៣៣ អនក្រ.បក ស្តីពីការបង្កើតមន្ទីសារការី នីតិនិវន្តរ៍ នៃព្រះរាជាណាចក្រកម្ពុជា, ១២ មីនា ២០១៥។
- អនុក្រឹត្យលេខ ០៩ អនក្រ.បក ស្តីពីការបង្កើតមន្ទីសារការី អេស ខេ វ៉ាយ នៃព្រះរាជាណាចក្រកម្ពុជា, ១៨ មករា ២០១៦។
- អនុក្រឹត្យលេខ ១៨ អនក្រ.បក ស្តីពីការបង្កើតមន្ទីសារការី លុច ស៊ីអេចឌី, ០២ កុម្ភៈ ២០១៦។
- អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការបង្កើតមន្ទីសារការី អង្គរ នៃព្រះរាជាណាចក្រកម្ពុជា, ១០ មីនា ២០១៦។
- ប្រកាសរបស់ក្រសួងយុត្តិធម៌, លេខ៤៧ កយ.ប្រក/១២, ១៦ កុម្ភៈ ២០១២។
- ប្រកាសរបស់ក្រសួងយុត្តិធម៌, លេខ៣២ កយ.ប្រក/១២, ២៣ ឧសភា ២០១២។

- ប្រកាសរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី, លេខ១៧ ប្រក , ២៨ កុម្ភៈ ២០១៣។

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តអន្តរជាតិ

- ច្បាប់ស្ដីពីសារការីនៃប្រទេសជប៉ុន, ១៣ មេសា ១៩០៨។
- ច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីសារការីនៃប្រទេសជប៉ុន, ០១ មិថុនា ១៩៤៩។
- បទបញ្ញត្តិស្ដីពីការអនុវត្តច្បាប់សារការីនៃប្រទេសជប៉ុន, ០១ មិថុនា ១៩៤៩។
- អនុក្រឹត្យស្ដីអំពីកម្រៃជើងសាររបស់សារការីនៃប្រទេសជប៉ុន, ០១ សីហា ១៩៩៣។

## សៀវភៅ និងអត្ថបទផ្សេងៗ

- សម្ដេចសង្ឃរាជជូនណាត,"វចនានុក្រមខ្មែរ",បោះពុម្ពលើកទី១(ភ្នំពេញ៖ពុទ្ធសាសនបណ្ឌិត ,១៩៦៧)។
- "សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី" ដែលត្រូវបានរៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះពុម្ពដោយទីស្ដីការគណៈរដ្ឋមន្ត្រីនៅឆ្នាំ២០០៧។
- ជុំ អ៊ឹម ,"ស្ថាប័ននយោបាយព្រះរាជាណាចក្រកម្ពុជា",បោះពុម្ពលើកទី១(ភ្នំពេញ៖ជោគជ័យ ,២០១២),១០៧។
- ក្រុមការងារនៃអនាគតគ្រូបង្គោលនៅសាលាភូមិន្ទថៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, "សេចក្ដីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១", កែសម្រួលលើការបោះពុម្ពលើកទី១, ២០១៣។
- （名古屋大学日本法教育研究センター、*『日本の法システム-３年生用教材』*（名古屋、2009 年）,មជ្ឈមណ្ឌលស្រាវជ្រាវ និងអប់រំអំពីច្បាប់ជប៉ុននៃសាកលវិទ្យាល័យណាហ្គោយ៉ា,*[សៀវភៅសិក្សាសម្រាប់ឆ្នាំទី៣-អំពីប្រព័ន្ធច្បាប់នៃប្រទេសជប៉ុន]*,(ណាហ្គោយ៉ា,២០០៩)។
- （名古屋大学日本法教育研究センター、*『日本史・公民』*（名古屋、2009 年）។ មជ្ឈមណ្ឌលស្រាវជ្រាវ និងអប់រំអំពីច្បាប់ជប៉ុននៃសាកលវិទ្យាល័យណាហ្គោយ៉ា, *[ប្រវត្តិសាស្ត្រជប៉ុន និងប្រជាជន]*,(ណាហ្គោយ៉ា,២០០៩)។
- វគ្គបណ្ដុះបណ្ដាលសម្រាប់កម្ពុជាស្ដីពីរបបសារការីជប៉ុន, រៀបរៀងដោយប្រធានគណកម្មការកិច្ចការបរទេសនៃសហព័ន្ធសារការីជប៉ុន Mr. TAKAI Shinji, ធ្វើនៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ ២០១៦, សិក្សានៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៦។
- បទបង្ហាញស្ដីពី "វិជ្ជាជីវៈសារការី" ដោយកញ្ញា ជឹង ស្រីទូច, សិស្សសារការីជំនាន់ទី១ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៦។

## គេហទំព័រ

- រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ,សាលាភូមិន្ទសារការី, http://rajp.gov.kh/Notary.html ។

- 日本公証人連合会, *公証制度百年史* [ប្រវត្តិមួយរយឆ្នាំនៃប្រព័ន្ធសារការី], http://yuigon.usdatashohisha_a_7.pdf ។
- 日本公証人連合会,*日本公証人制度の概要と問題点* [សង្ខេបអំពីប្រព័ន្ធសារការីជប៉ុននិងចំនុចបញ្ហា] , http://yuigon.usdatashohisha_a_7.pdf ។
- 法務省,*公証関係* [ទំនាក់ទំនងនៃយថាភូតភាព], http://www.moj.go.jp/MINJI/koushou.html
- 法務省民事局,*民法の一部を改正する法律などの概要*, [សង្ខេបអំពីផ្នែកដែលត្រូវបានធ្វើវិសោធនកម្មក្នុងក្រមរដ្ឋប្បវេណី], （法務省,១៩៩៩）
http://www.ipss.go.jppublicationjshiryouno.13datashiryousyakaifukushi782.pdf ។
- 日本公証人連合会、 *手数料* [កម្រៃជើងសារ], http://www.kouseishousho.jp/tesuuryou.html ។
- 公証人, *手数料* [កម្រៃជើងសារ], http://www.koshonin.com/tesuuryou.html ។
- 特許委員会第 4 部会, *知的財産における公証制度の利用について* [អំពីការប្រើប្រាស់ប្រព័ន្ធសារការីទាក់ទងនឹងកម្មសិទ្ធិបញ្ញា], (特許委員会第 4 部会,២០០៣)
http://www.jpaa.or.jpactivitypublicationpatentpatent-librarypatent-lib200309jpaapatent200309_015-024.pdf ។
- 法務省, *全国公証役場所在地一覧* [តារាងស្ដីពីទីតាំងនៃមន្ទីរសារការីទូទាំងប្រទេស], http://www.koshonin.gr.jp/sho.html ។
- 法務省, 指定公証人一覧 [តារាងស្ដីពីសារការីដែលត្រូវបានតែងតាំង], http://www.moj.go.jp/MINJI/DENSHIKOSHO/denshikosho2.html ។
- 法務省, *法務局・地方法務局所在地一覧* [តារាងស្ដីពីទីតាំងនៃការិយាល័យច្បាប់តាមតំបន់],http://www.moj.go.jp/MINJI/minji10.html ។
- 日本公証人連合会, *公証人−未然に防ぐために* [សារការី-ដើម្បីការពារទុកជាមុន], http://www.koshonin.gr.jp/pdf/koushounin20141021.pdf ។
- Ministry of Justice, *Electronic Notarization System based on the Notarization System* [ប្រព័ន្ធផ្ដល់យថាភូតបែបអេឡិចត្រូនិចដោយផ្អែកលើប្រព័ន្ធសារការី], http://www.moj.go.jp/ENGLISH/information/rotlf-11.html ។
- Japan National Notaries Association, *How to make good use of Japanese Notaries* [វិធីដើម្បីឲ្យការប្រើប្រាស់ប្រព័ន្ធសារការីជប៉ុនកាន់តែល្អ], http://www.koshonin.gr.jp/pdf/en20131021.pdf
- International Union of Notaries (UINL), [សហព័ន្ធសារការីអន្តរជាតិ] http://www.notaiodidomenico.it/NOTAIO/UINL.htm ។
- International Union of Notaries(UINL), [សហព័ន្ធសារការីអន្តរជាតិ], http://www.uinl.org/1/home-page ។
- The International Union of Notaries (UINL), *Structure of UINL* [រចនាសម្ព័ន្ធនៃសហព័ន្ធសារការីអន្តរជាតិ], http://npu.in.ua/en/international-notariat/uinl/structure-of-uinl#.V0VuojV97IU ។

- សំណួរ-ចម្លើយទាក់ទងនឹងសារការីប្រទេសជប៉ុន, http://www.tokyokoshonin-kyokai.jp/question.html ។
- សាយ រង្សី "ការវិវត្តន៍នៃវិជ្ជាជីវៈសារការី", http://ann.com.kh/post/044455426522212365582858555.html ។
- វិចិត្រ, "មន្ទីរសារការី ជាកន្លែងដែលមានអ្នកជំនាញច្បាប់ផ្តល់សេវាជូនវិនិយោគិន និងសាធារណជនទូទៅក្នុងការផ្តល់យោបល់ច្បាប់", http://www.cen.com.kh/local/01990765។
- DTN7 "បើកមន្ទីរសារការីនៅកម្ពុជាត្រូវតម្កល់លុយ៦០០លានរៀលនៅធនាគារជាតិ", http://www.dtn7.com/2015/04/22/12608.html/ ។
- ថ្មីៗ, "ពិធីសម្ពោធជាផ្លូវការមន្ទីរសារការីសេដ្ឋាវិទូនៃព្រះរាជាណាចក្រកម្ពុជា", https://www.thmeythmey.com/?page=detail&ctype=article&id=28358&lg=kh។
- វត្តី, "មន្ទីរសារការីភ្នំពេញបើកដំណើរការជាផ្លូវការហើយ", http://kampucheathmey.com/kpt/?p=229571។
- គេហទំព័រផ្លូវការរបស់ក្រសួងយុត្តិធម៌, https://www.facebook.com/%E1%9E%80%E1%9F%92%E1%9E%9A%E1%9E%9F%E1%9E%BD%E1%9E%84%E1%9E%99%E1%9E%BB%E1%9E%8F%E1%9F%92%E1%9E%8F%E1%9E%B7%E1%9E%92%E1%9E%98%E1%9F%8C-Ministry-of-Justice-367835473349148/?fref=ts ។
- ឈាង បុប្ផា, "សារការីខ្មែរជំនាន់ទីមួយបញ្ចប់កម្មសិក្សានៅប្រទេសបារាំង", http://km.rfi.fr/cambodia/notaires-khmers-form%C3%A9s-en-france-20150226 ។
- ហៃ៉ល ចំរើន, "មេធាវី ឬ សារការី", http://km.rfi.fr/chronique-bilingue-sabath-06-11-2014។